# ការសិក្សាស្ដីពីស្ថានភាពសិទ្ធិមនុស្សរបស់សហគមន៍ដែលរស់នៅកន្លែងតាំងទីលំនៅថ្មីក្នុងប្រទេសកម្ពុជា និង សេចក្ដីព្រាងគោលការណ៍ណែនាំអំពីការតាំងទីលំនៅថ្មី

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
ប្រចាំនៅកម្ពុជា



UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER
Cambodia

European Union
Delegation to Cambodia

ស៊ុយអែត
Sverige

# សេចក្តីថ្លែងអំណរគុណ

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ប្រចាំនៅកម្ពុជា សូមថ្លែងអំណរគុណចំពោះការងាររបស់ក្រុមការងារស្រាវជ្រាវរបស់ សហជីពឥណទានមូលនិធិអូស្ត្រាលី (CUFA) ដែលបានធ្វើការស្ទង់មតិចាប់ពីឆ្នាំ២០១៩-២០២០។

ខ្ញុំសូមថ្លែងអំណរគុណជាពិសេសចំពោះអ្នកចូលរួមគ្រប់រូបនៅក្នុងការស្ទង់មតិនេះ ចាប់ពីនិវាសនជននៅកន្លែងតាំងទីលំនៅថ្មីនៃការស្ទង់មតិនេះ អាជ្ញាធរមូលដ្ឋាន ប្រធានសហគមន៍ និង អង្គការមិនមែនរដ្ឋាភិបាល ដែលបានយល់ព្រមទទួលយកការសម្ភាសន៍សម្រាប់ការសិក្សានេះ។

ការិយាល័យ OHCHR ក៏សូមថ្លែងអំណរគុណដល់លោកស្រី Miwa Kubosaki និង លោកស្រី Maia Diokno ផងដែរ ដែលបានរៀបចំសេចក្តីព្រាងរបាយការណ៍នេះ។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

ការិយាល័យប្រចាំប្រទេសកម្ពុជា

រាជធានីភ្នំពេញ ប្រទេសកម្ពុជា

រូបថតក្របមុខ ថតដោយ៖ សហជីពឥណទានមូលនិធិអូស្ត្រាលី (Cufa)

ឯកសារនេះ បោះពុម្ពផ្សាយក្រោមជំនួយថវិការបស់ប្រទេសស៊ុយអែត និងសហភាពអឺរ៉ុប។ មាតិកា ឬខ្លឹមសារនៅក្នុង ឯកសារនេះ គឺជាទំនួលខុសត្រូវទាំងស្រុងរបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈ ឬការយល់ឃើញណាមួយរបស់ប្រទេសស៊ុយអែត និងសហភាពអឺរ៉ុបឡើយ។

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER
Cambodia

European Union
Delegation to Cambodia

ស៊ុយអែត
Sverige

# មាតិកា


សេចក្ដីសង្ខេប ........ ២

ការសង្ខេបអំពីការស្រាវជ្រាវ........ ៣

១. គោលបំណង ........ ៣

២. កន្លែងតាំងទីលំនៅថ្មី ........ ៣

៣. វិធីសាស្ត្រ........ ៦

៤. ទំហំសំណាកនៃការស្ទង់មតិ........ ៦

៥. ភាពខ្វះចន្លោះនៅក្នុងការស្រាវជ្រាវ និង ភស្តុតាង ........ ៨

ជំពូក ១ សេចក្ដីផ្ដើម ........ ១០

១.១ អ្នកឆ្លើយតប ........ ១០

ភ្នំពេញ/ខេត្ត យេនឌ័រ អាយុ ........ ១០

គ្រួសារជនជាតិដើមភាគតិច ........ ១១

ទីតាំងបណ្ដេញចេញ ........ ១១

ទំហំគ្រួសារ និង មុខតំណែងនៅក្នុងគ្រួសារ ........ ១២

ស្ថានភាពគ្រួសារ ........ ១២

ទេសន្តរប្រវេសន៍ ........ ១២

១.២ ក្របខណ្ឌច្បាប់ និង គោលនយោបាយ ........ ១៤

បទដ្ឋានច្បាប់អន្តរជាតិ ........ ១៤

ធុរកិច្ច និងសិទ្ធិមនុស្ស ........ ១៥

ការបណ្ដេញចេញ និង ការតាំងទីលំនៅថ្មីស្របតាមច្បាប់ជាតិនៃប្រទេសកម្ពុជា ........ ១៥

ជំពូក ២ ជីវិតនៅកន្លែងតាំងទីលំនៅថ្មី ........ ១៨

២.១ មុននឹងធ្វើការបណ្ដេញចេញ ........ ១៨

២.១.១ ដំណើរការនៃការសម្រេចចិត្ត ........ ១៨

២.១.២ សេចក្ដីជូនដំណឹងអំពីការបណ្ដេញចេញ ........ ២០

២.២ លក្ខខណ្ឌតម្រូវសម្រាប់កន្លែងតាំងទីលំនៅថ្មី........ ២០

២.៣ បន្ទាប់ពីការបណ្ដេញចេញ........ ២១

២.៣.១ សំណង........ ២១

២.៣.២ ទិដ្ឋភាពទូទៅ៖ ទិដ្ឋភាពវិជ្ជមាន និង អវិជ្ជមាននៃការតាំងទីលំនៅថ្មី ........ ២១

ទិដ្ឋភាពវិជ្ជមាន ........ ២២

ទិដ្ឋភាពអវិជ្ជមាន ........ ២៣

គ្រួសារជនជាតិភាគតិច ........ ២៣

២.៣.៣ សុវត្ថិភាពនៃការកាន់កាប់ ........ ២៥
២.៣.៤ លទ្ធភាពក្នុងការទទួលបានសេវាមូលដ្ឋាន ........ ២៧
២.៣.៤.១ ផ្ទះ ផ្លូវថ្នល់ និង ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបង្ហូរទឹក ........ ២៧
២.៣.៤.២ ការមានស្បៀង និង លទ្ធភាពក្នុងការទទួលបានស្បៀងអាហារ ........ ២៨
២.៣.៤.៣ សេវាសាធារណៈ (ទឹក ថាមពលសម្រាប់បំភ្លឺ អគ្គិសនី ឥន្ធនៈសម្រាប់ចម្អិនម្ហូបអាហារ អនាម័យ) ........ ២៨
២.៣.៤.៤ ការអប់រំ និង សេវាសុខាភិបាល ........ ៣១
២.៣.៥ ជីវភាពរស់នៅ ........ ៣២
២.៣.៦ ផលប៉ះពាល់សង្គម និង បរិស្ថាន ........ ៣៥

**ជំពូក ៣ សេចក្តីសន្និដ្ឋាន និង អនុសាសន៍ ........ ៣៨**

**ប្រេវ៉ាឡង់នៃការបណ្តេញចេញដោយបង្ខំ ........ ៣៨**
ក្របខណ្ឌច្បាប់ ........ ៣៨
ការហាមឃាត់ការបណ្តេញចេញដោយបង្ខំ ........ ៣៨
**មុននឹងធ្វើការបណ្តេញចេញ ........ ៣៨**
ដំណើរការនៃការសម្រេចចិត្ត ........ ៣៨
សេចក្តីជូនដំណឹងអំពីការបណ្តេញចេញ ........ ៣៩
**លក្ខខណ្ឌតម្រូវសម្រាប់កន្លែងតាំងទីលំនៅថ្មី ........ ៣៩**
**ក្រោយពេលបណ្តេញចេញ ........ ៤០**
សំណង ........ ៤០
សុវត្ថិភាពនៃការកាន់កាប់ ........ ៤១
**លទ្ធភាពក្នុងការទទួលបានសេវាមូលដ្ឋាន ........ ៤២**
ផ្ទះ ផ្លូវថ្នល់ និង ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបង្ហូរទឹក ........ ៤២
សិទ្ធិទទួលបានស្បៀងអាហារ ........ ៤២
សេវាសាធារណៈ (ទឹក ថាមពលសម្រាប់បំភ្លឺ/អគ្គិសនី អនាម័យ) ........ ៤២
សិទ្ធិទទួលបានការអប់រំ និង សេវាសុខាភិបាល ........ ៤២
ជីវភាពរស់នៅ និង ឱកាសផ្នែកសេដ្ឋកិច្ច ........ ៤៤
ផលប៉ះពាល់ផ្នែកសង្គម និង បរិស្ថាន ........ ៤៤

**ឧបសម្ព័ន្ធ ........ ៤៦**

ឧបសម្ព័ន្ធទី១៖ ឈ្មោះទីកន្លែង និងអាសយដ្ឋានពេញនៃទីតាំងបណ្តេញចេញ ........ ៤៦
ឧបសម្ព័ន្ធទី២៖ ទីតាំងបណ្តេញចេញ តាមកន្លែងតាំងទីលំនៅថ្មី ........ ៤៨
ឧបសម្ព័ន្ធទី៣៖ ការពិគ្រោះយោបល់ ........ ៤៩
ឧបសម្ព័ន្ធទី៤៖ សេចក្តីព្រាងគោលការណ៍ណែនាំអំពីការតាំងទីលំនៅថ្មី ........ ៥០

# អក្សរកាត់

| | |
|---|---|
| CEDAW | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ |
| CERD | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ |
| CESCR | គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ |
| CMW | អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និង សមាជិកគ្រួសាររបស់ពួកគេ |
| CRC | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| CRPD | អនុសញ្ញាស្តីពីសិទ្ធិជនពិការ |
| CUFA | មូលនិធិសហភាពឥណទានអូស្ត្រាលី |
| HIV/AIDS | មេរោគអេដស៍/ជំងឺអេដស៍ |
| ICCPR | អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| ICESCR | អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ |
| NGOs | អង្គការមិនមែនរដ្ឋាភិបាល |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SDG | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| UN OHCHR | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស |
| UNICEF | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ |
| WHO | អង្គការសុខភាពពិភពលោក |

# សេចក្តីសង្ខេប

ការសិក្សាអំពីស្ថានភាពសិទ្ធិមនុស្សរបស់សហគមន៍ដែលរស់នៅកន្លែងតាំងទីលំនៅថ្មី នៅក្នុងប្រទេសកម្ពុជានេះ គឺជាការសិក្សាតាមដានបន្តពីរបាយការណ៍ "ការបណ្តេញចេញ និង ការតាំងទីលំនៅថ្មីនៅក្នុងកម្ពុជា - តម្លៃនៃផលប៉ះពាល់ជាអវិជ្ជមានចំពោះមនុស្ស ឥទ្ធិពល និង ដំណោះស្រាយ" ដែលត្រូវបានបោះពុម្ពផ្សព្វផ្សាយដោយការិយាល័យ OHCHR នៅក្នុងឆ្នាំ២០១២។ ការសិក្សានេះផ្អែកលើការស្ទង់មតិនៃការស្រាវជ្រាវដែលត្រូវបានធ្វើឡើងនៅកន្លែងតាំងទីលំនៅថ្មី ចំនួន ១៧ កន្លែងនៅទូទាំងប្រទេសកម្ពុជា នៅក្នុងឆ្នាំ២០១៩ រហូតដល់ដើមឆ្នាំ២០២០។

ការសិក្សានេះត្រូវបានបែងចែកជាបីជំពូក។ ជំពូកទីមួយណែនាំអំពីគ្រួសារនៅកន្លែងតាំងទីលំនៅថ្មី និង ក្របខណ្ឌច្បាប់ដែលពាក់ព័ន្ធនឹងការតាំងទីលំនៅថ្មី។ ជំពូកទីពីររៀបរាប់លម្អិតអំពីដំណើរការនៃការបណ្តេញចេញ រួមទាំងការផ្តល់ព័ត៌មានដល់គ្រួសារទាំងឡាយអំពីការបណ្តេញចេញ, លក្ខខណ្ឌនានាបន្ទាប់ពីបានមកដល់កន្លែងតាំងទីលំនៅថ្មី និង សំណង, ស្ថានភាពបច្ចុប្បន្ននៅកន្លែងតាំងទីលំនៅថ្មី, ការផ្តោតលើសេវាមូលដ្ឋានដែលអាចស្វែងរកបានសម្រាប់គ្រួសារដែលបានតាំងទីលំនៅថ្មី។ សេវាដែលត្រូវបានរៀបរាប់នៅក្នុងរបាយការណ៍នេះរួមមាន លំនៅឋាន ផ្លូវថ្នល់ សន្តិសុខស្បៀងអាហារ ទឹក ប្រភពថាមពល អនាម័យ សុខភាព និងការអប់រំ ព្រមទាំងជីវភាពរស់នៅផងដែរ។ សេវាទាំងអស់នេះក៏គ្របដណ្តប់បន្ថែមលើវិស័យ នានា ដូចជាផលប៉ះពាល់ផ្នែកសង្គម និង បរិស្ថាន ជាដើម។ ជំពូកទីបី រួមបញ្ចូល សេចក្តីសន្និដ្ឋាន និង អនុសាសន៍នានាស្តីពីវិធានការនានាដែលរាជរដ្ឋាភិបាលកម្ពុជា (RGC) សង្គមស៊ីវិល និង សហគមន៍អន្តរជាតិគប្បីអនុវត្តដើម្បីធានាថា សិទ្ធិរបស់គ្រួសារដែលបានតាំងទីលំនៅថ្មី ត្រូវបានគោរព ការពារ និង បំពេញបន្ថែម និង បញ្ឈប់សកម្មភាពការបណ្តេញចេញដោយបង្ខំ។

ការសិក្សាបានរកឃើញថា ជាទូទៅ សិទ្ធិមានលំនៅឋានសមរម្យ ដែលជាផ្នែកមួយនៃសិទ្ធិមានកម្រិតជីវភាពរស់នៅសមរម្យ មិនត្រូវបានគោរព ការពារ និង បំពេញតាម នៅក្នុងបរិបទនៃការផ្លាស់ប្តូរទីលំនៅ និង ការដោះស្រាយផលប៉ះពាល់នោះទេ។ ការផ្លាស់ប្តូរទីលំនៅភាគច្រើន ដែលត្រូវបានសម្គាល់ឃើញនៅក្នុងការសិក្សានេះ ត្រូវបានធ្វើឡើងដោយគ្មានការពិគ្រោះយោបល់យ៉ាងត្រឹមត្រូវជាមួយសហគមន៍ដែលរងផលប៉ះពាល់ មុនពេលបណ្តេញចេញនោះទេ និង ដូចបានកត់សម្គាល់នៅក្នុងការសិក្សាឆ្នាំ២០១២ ការបំភិតបំភ័យ និង ការបង្ខិតបង្ខំគ្រួសារទាំងឡាយ ត្រូវបានប្រើប្រាស់ដើម្បីបង្ខំពួកគេឱ្យផ្លាស់ប្តូរទីលំនៅ និង ការប្រើកម្លាំងបាយដោយមិនត្រឹមត្រូវក្នុងអំឡុងពេលនៃដំណើរការបណ្តេញចេញ។[1] អាស្រ័យហេតុនេះ ការផ្លាស់ប្តូរទីលំនៅដែលត្រូវបានគ្របដណ្តប់នៅក្នុងរបាយការណ៍នេះ ត្រូវបានចាត់ទុកថាជាការបណ្តេញចេញដោយបង្ខំ។ កន្លែងតាំងទីលំនៅថ្មីភាគច្រើន មិនត្រូវបានរៀបចំទុកជាមុន មុនពេលបណ្តេញចេញ ហើយសេវាមូលដ្ឋាន ក៏ពុំមានផងដែរនៅពេលដែលគ្រួសារដែលរងផលប៉ះពាល់បានទៅដល់ទីតាំងថ្មីទាំងនោះ។

សំណងត្រូវបានផ្តល់ជូនគ្រួសារជាក់លាក់ ទោះបីជាយ៉ាងណាក៏ដោយ មិនមែនគ្រួសារទាំងអស់ពេញចិត្តនឹងសំណងដែលបានទទួលនោះទេ។ មានគ្រួសារដែលបានតាំងទីលំនៅថ្មី ដែលបច្ចុប្បន្ន ប្រឈមមុខនឹងការលំបាកផ្នែកសុវត្ថិភាពនៃសិទ្ធិកាន់កាប់ ដោយសារពួកគេពុំមានប័ណ្ណកម្មសិទ្ធិ ទោះបីជាពួកគេបានរស់នៅកន្លែងតាំងទីលំនៅថ្មីអស់រយៈពេលជាងប្រាំឆ្នាំមកហើយក្តី។ គ្រួសារដែលបានតាំងទីលំនៅថ្មី បានរាយការណ៍ថា សិទ្ធិទទួលបានកម្រិតជីវភាពរស់នៅសមរម្យ រួមទាំង សិទ្ធិទទួលបានស្បៀងអាហារ ទឹកស្អាត និង អនាម័យ ព្រមទាំងសិទ្ធិទទួលបានមជ្ឈដ្ឋានដែលមានផាសុខភាព ការអប់រំ និង សុខភាពរបស់ពួកគេត្រូវបានសម្របសម្រួល ។ លើសពីនេះទៀត ការតាំងទីលំនៅថ្មីទាំងនេះ បានធ្វើឱ្យសេដ្ឋកិច្ចរបស់គ្រួសារកាន់តែមានការថយចុះ ដោយគ្រួសារទាំងឡាយបានរាយការណ៍អំពីការកើនឡើងនៃបំណុល ប្រាក់ចំណូលមិនទៀងទាត់ ការថយចុះនៃប្រាក់ចំណូល បើធៀបទៅនឹងទីតាំងចាស់របស់ពួកគេ និង ជិតមួយភាគបីនៃគ្រួសារជនជាតិដើមភាគតិចបានរាយការណ៍អំពីការថយចុះនៃឱកាសការងារ។

ការអនុវត្តទាំងនេះហាក់បីដូចជាផ្ទុយនឹងច្បាប់ និង គោលនយោបាយជាតិរបស់ប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា (RGC) គប្បីពង្រឹង និង អនុវត្តច្បាប់ និង គោលនយោបាយជាតិ រួមជាមួយកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួនយ៉ាងម៉ឺងម៉ាត់។ RGC គប្បីអនុម័តគោលការណ៍ណែនាំដែលមានលក្ខណៈទូលំទូលាយស្តីពីការតាំងទីលំនៅថ្មី ដើម្បីធានាថាគ្មានការបណ្តេញចេញដោយបង្ខំបានកើតឡើង ហើយការបណ្តេញចេញដោយមានហេតុផលសមស្រប ត្រូវបានអនុវត្តស្របតាមបទដ្ឋាន និងស្តង់ដារសិទ្ធិមនុស្ស អន្តរជាតិ រួមទាំង បទដ្ឋានស្តីពីសិទ្ធិមានលំនៅឋានសមរម្យ និង កម្រិតជីវភាពរស់នៅសមរម្យ។ RGC និង ភាគីពាក់ព័ន្ធដទៃទៀត រួមទាំង សង្គមស៊ីវិល និង សហគមន៍អន្តរជាតិផងដែរ គប្បីធ្វើការវាយតម្លៃឡើងវិញលើកិច្ចអន្តរាគមន៍របស់ពួកគេនាពេលបច្ចុប្បន្ន និង កិច្ចអន្តរាគមន៍ដែលបានគ្រោងទុក ដើម្បីធានាថាសិទ្ធិរបស់សហគមន៍ដែលបានតាំងទីលំនៅថ្មីត្រូវបានគោរព ការពារ និង បំពេញ។

1 OHCHR កម្ពុជា "ការបណ្តេញចេញ និងការតាំងទីលំនៅថ្មីនៅក្នុងកម្ពុជា - "តម្លៃនៃផលប៉ះពាល់ជាអវិជ្ជមានចំពោះមនុស្ស ឥទ្ធិពល និងដំណោះស្រាយ" ឆ្នាំ២០១២ ជំពូក ៤៖ ដំណើរការមុនពេលបណ្តេញចេញ និង ការអនុវត្តក្នុងអំឡុងពេលបណ្តេញចេញ https://cambodia.ohchr.org/sites/default/files/Thematic-reports/Resettlement_Study-28_Feb_2012_Eng.pdf.

# ការសង្ខេបអំពីការស្រាវជ្រាវ

## ១ គោលបំណង

ការសិក្សានេះត្រូវបានផ្តល់អាណត្តិដោយការិយាល័យ OHCHR នៅកម្ពុជា ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីសហភាពអឺរ៉ុប ក្នុងគោលបំណងពិនិត្យមើលស្ថានភាពសិទ្ធិមនុស្សរបស់សហគមន៍ដែលរស់នៅកន្លែងតាំងទីលំនៅថ្មីនៅក្នុងប្រទេសកម្ពុជា។ ការសិក្សានេះ គឺជាការតាមដានបន្តពីរបាយការណ៍ *"ការបណ្តេញចេញ និង ការតាំងទីលំនៅថ្មីនៅក្នុងកម្ពុជា - តម្លៃផលប៉ះពាល់ជាអវិជ្ជមានចំពោះមនុស្ស ឥទ្ធិពល និង ដំណោះស្រាយ"* ដែលចេញផ្សាយដោយ ការិយាល័យ OHCHR នៅឆ្នាំ២០១២។ ជាផ្នែកមួយនៃកិច្ចសហការផ្នែកបច្ចេកទេសរបស់ខ្លួនជាមួយ RGC, ការិយាល័យ OHCHR បន្តតាមដានករណីនៃការបណ្តេញចេញ និង ការតាំងទីលំនៅថ្មីនៅក្នុងប្រទេសកម្ពុជា ដើម្បីកំណត់ពីការអនុវត្តល្អ និង រាយការណ៍អំពីបញ្ហាជូនទៅរាជរដ្ឋាភិបាលនិង តួអង្គពាក់ព័ន្ធដទៃទៀត សំរាប់សកម្មភាពកែតម្រូវ ដើម្បីគាំទ្រដល់ស្ថាប័នរដ្ឋដែលទទួលខុសត្រូវលើការគោរព និង ការលើកកម្ពស់នូវសិទ្ធិមនុស្ស។

ការសិក្សានេះមានវិសាលភាពទូលំទូលាយជាងការសិក្សាក្នុងឆ្នាំ២០១២ ដែលបានពិនិត្យទៅលើតំបន់តាំងទីលំនៅថ្មីចំនួនប្រាំបី នៅក្នុងរាជធានីភ្នំពេញ ខេត្តកណ្តាល និង ខេត្តព្រះសីហនុ ហើយដែលពាក់ព័ន្ធទៅនឹងការបណ្តេញចេញនៅក្នុងតំបន់ទីក្រុង។ ការសិក្សានេះបានគ្របដណ្តប់លើតំបន់តាំងទីលំនៅថ្មីចំនួន ១៧ កន្លែង ទាំងនៅក្នុងទីក្រុង និង ជនបទ។

ការសិក្សាឆ្នាំ២០១២ បានសន្និដ្ឋានថា ការបណ្តេញចេញ និង ការតាំងទីលំនៅថ្មីនៅប្រទេសកម្ពុជា មានជាប់មកជាមួយនូវហានិភ័យនៃការបង្កើតភាពក្រីក្រ និង ការលំបាកសម្រាប់សហគមន៍ដែលរងផលប៉ះពាល់។ ការសិក្សានោះបានកត់សម្គាល់ នៅក្នុងចំណោមបញ្ហាផ្សេងទៀត... "នៅពេលដែលអាជ្ញាធរ សហគមន៍ អង្គការមិនមែនរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍ធ្វើការរួមគ្នាដើម្បីរៀបចំផែនការតាំងទីលំនៅថ្មី ដោយមានការពិចារណាយ៉ាងពេញលេញអំពីការចូលរួម និង តម្រូវការរបស់សហគមន៍នោះ ផលប៉ះពាល់អវិជ្ជមាននៃការតាំងទីលំនៅថ្មីមិនត្រឹមតែត្រូវបានកាត់បន្ថយប៉ុណ្ណោះទេ ប៉ុន្តែដំណើរការនោះក៏អាចនាំទៅរកជីវភាពរស់នៅកាន់តែល្អប្រសើរឡើង និង មាននិរន្តរភាព"។ ការសិក្សានោះក៏បានចង្អុលបង្ហាញផងដែរ នៅពេលដែលលក្ខខណ្ឌដែលបានលើកឡើងខាងលើមិនបានបំពេញតាម ស្ថានភាពរបស់សហគមន៍ដែលបានតាំងទីលំនៅថ្មី ជាញឹកញាប់ ប្រែជាមានសភាពកាន់តែអាក្រក់ទៅៗ។

គោលបំណងនៃការសិក្សានេះមានភាពប្រហាក់ប្រហែលគ្នានឹងការសិក្សាឆ្នាំ២០១២។ វាបានរួមបញ្ចូលការថ្លឹងថ្លែងអំពីតម្លៃមនុស្ស និង តម្លៃសង្គមនៃការបណ្តេញចេញ និង ការតាំងទីលំនៅថ្មីនៅប្រទេសកម្ពុជា និង ការស្វែងរកដំណោះស្រាយ ដើម្បីដោះស្រាយបញ្ហានានាដែលត្រូវបានកំណត់។ ដូចគ្នានឹងការសិក្សាពីមុនដែរ សង្ឃឹមថា RGC និង ភាគីពាក់ព័ន្ធដទៃទៀត រួមទាំង អង្គការដែលមានជំនាញបច្ចេកទេស និង កម្មវិធីជំនួយ នឹងធ្វើការសិក្សាឆ្ពោះទៅមុខ ដើម្បីវាយតម្លៃទិដ្ឋភាពមួយចំនួននៃការតាំងទីលំនៅថ្មីដែលត្រូវបានគូសបញ្ជាក់នៅក្នុងការសិក្សានេះឱ្យបានស៊ីជម្រៅ និង រៀបចំកម្មវិធីនានាទៅតាមនោះ តាមរយៈកិច្ចពិភាក្សាប្រកបដោយការសហការ ឆ្ពោះទៅរកដំណោះស្រាយចំពោះបញ្ហាការតាំងទីលំនៅថ្មីនៅក្នុងប្រទេសកម្ពុជា។ លើសពីនេះទៀត យើងក៏សង្ឃឹមផងដែរថា RGC តាមរយៈដំណើរការពិគ្រោះយោបល់រួមគ្នាមួយ នឹងបង្កើតគោលការណ៍ណែនាំជាក់លាក់ដែលនឹងគ្រប់គ្រងការអនុវត្តរាល់ការបណ្តេញចេញ និង ការផ្លាស់ប្តូរទីលំនៅនាពេលអនាគត។ គោលការណ៍ទាំងនេះគួរធ្វើឱ្យគ្រួសារដែលទទួលបានការដោះស្រាយផល ប៉ះពាល់ ទទួលបានមធ្យោបាយនានា មិនត្រឹមតែដើម្បីស្តារជីវភាពរស់នៅរបស់ពួកគេឡើងវិញប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យជីវភាពរស់នៅរបស់ពួកគេមានភាពល្អប្រសើរឡើងទៀតផង ដោយប្រៀបធៀបទៅនឹងស្ថានភាពរបស់ពួកគេមុនការតាំងទីលំនៅថ្មី ដូច្នេះនាំឱ្យពួកគេអាចយកឈ្នះលើភាពក្រីក្រ និង ចូលរួមនៅក្នុងការអភិវឌ្ឍជាតិ។

## ២ កន្លែងតាំងទីលំនៅថ្មី

សម្រាប់ការសិក្សានេះ គ្រួសារដែលរងផលប៉ះពាល់ដោយសារការបណ្តេញចេញ ត្រូវបានស្ទង់មតិនៅកន្លែងតាំងទីលំនៅថ្មី ចំនួន ១៧ កន្លែងខុសៗគ្នា។ កន្លែងទាំងនោះស្ថិតនៅ**រាជធានីភ្នំពេញ និង ខេត្តចំនួនប្រាំបី** (ខេត្តបាត់ដំបង ខេត្តកណ្តាល ខេត្តកោះកុង ខេត្តកំពង់ស្ពឺ ខេត្តឧត្តរមានជ័យ ខេត្តសៀមរាប ខេត្តព្រះសីហនុ និង ខេត្តស្ទឹងត្រែង)។ ដូចបានបង្ហាញនៅក្នុងផែនទី១ នៅខាងក្រោម មានទីតាំងចំនួនប្រាំមួយនៅរាជធានីភ្នំពេញ និង ទីតាំងចំនួន ១១ នៅតាមបណ្តាខេត្ត រួមមាន មួយទីតាំងក្នុងមួយខេត្តក្នុងចំណោមប្រាំមួយខេត្ត (ខេត្តបាត់ដំបង ខេត្តកណ្តាល ខេត្តកោះកុង ខេត្តកំពង់ស្ពឺ ខេត្តឧត្តរមានជ័យ និង ខេត្តសៀមរាប) បីទីតាំងនៅខេត្តព្រះសីហនុ និង ពីរទីតាំងនៅខេត្តស្ទឹងត្រែង។

តារាងទី១ ខាងក្រោមរាយនាមទីតាំង និង អាសយដ្ឋានពេញ នៃកន្លែងតាំងទីលំនៅថ្មីនីមួយៗនៅតាមបណ្តាខេត្ត តាមលំដាប់លំដោយតួអក្សរ ហើយឈ្មោះកាត់នៃទីតាំងនីមួយៗត្រូវបានប្រើប្រាស់ឯកសារយោងដល់នៅក្នុងរបាយការណ៍នេះ។

មានកន្លែងតាំងទីលំនៅថ្មីចំនួនប្រាំបួនកន្លែងនៅក្នុងតំបន់ ដែលនៅតែត្រូវបានគេចាត់ទុកថាជាផ្នែកមួយនៃទីប្រជុំជន ឬ ទីក្រុងដ៏សំខាន់មួយ។ ទីតាំងទាំងនេះរួមមាន អណ្តូងចាស់ អណ្តូងថ្មី ដំណាក់ត្រយឹង ស្រែអំពិល ត្រពាំងអញ្ចាញ និង ទួលសំបូរនៅរាជធានីភ្នំពេញ និង ព្រែកកូនសេក នៅខេត្តបាត់ដំបង អភិវឌ្ឍដីថ្មីនៅខេត្តព្រះសីហនុ និង វាលនៅខេត្តសៀមរាប។ ក្នុងចំណោមទីតាំងទាំងនេះ មានទីតាំងតែមួយប៉ុណ្ណោះដែលស្ថិតនៅជិតទីប្រជុំជន គឺ ព្រែកកូនសេក ដែលមានចម្ងាយប្រាំពីរ គម. ពីក្រុងបាត់ដំបង។ ទីតាំងចំនួនប្រាំបីផ្សេងទៀតស្ថិតនៅជាយក្រុង ឬ ទីប្រជុំជន ទីតាំងមួយចំនួនទៀតស្ថិតនៅឆ្ងាយពីទីក្រុង ឬ ទីប្រជុំជន។ កន្លែងតាំងទីលំនៅថ្មីទាំងប្រាំបួននេះត្រូវបានសម្គាល់ដោយសញ្ញាផ្កាយនៅក្នុងតារាង និង តួរលេខត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍នេះ។ គ្រួសារចំនួន ៦៨% រស់នៅកន្លែងតាំងទីលំនៅថ្មី ដែលស្ថិតនៅក្រៅទីក្រុងសំខាន់ៗ និង ៣២ ភាគរយកំពុងតែរស់នៅក្នុងទីក្រុងធំៗទាំងប្រាំបួន។

**ផែនទី ១៖ កន្លែងតាំងទីលំនៅថ្មីចំនួន ១៧ កន្លែង**




**តារាងទី១៖ អាសយដ្ឋានពេញ និង ឈ្មោះយោងសម្រាប់កន្លែងតាំងទីលំនៅថ្មី តាមខេត្ត (តាមលំដាប់លំដោយនៃតួអក្សរ**




| អាសយដ្ឋានពេញ | ឈ្មោះយោង |
|---|---|
| ភូមិព្រែកកូនសេក សង្កាត់អូរចារ ក្រុងបាត់ដំបង* | ព្រែកកូនសេក* |




| អាសយដ្ឋានពេញ | ឈ្មោះយោង |
|---|---|
| ភូមិពីស ឃុំអមលាំង ស្រុកថ្ពង | ពីស |




| អាសយដ្ឋានពេញ | ឈ្មោះយោង |
|---|---|
| ភូមិស្រះពោធិ៍ ឃុំភ្នំបាត ស្រុកពញាឮ | ស្រះពោធិ៍ |




| អាសយដ្ឋានពេញ | ឈ្មោះយោង |
|---|---|
| ភូមិព្រែកស្វាច់ ឃុំកោះស្ដេច ស្រុកគិរីសាគរ | ព្រែកស្វាច់ |




| អាសយដ្ឋានពេញ | ឈ្មោះយោង |
|---|---|
| ភូមិអូរបាត់មាន់ សង្កាត់កូនក្រៀល ក្រុងសំរោង | អូរបាត់មាន់ |




| អាសយដ្ឋានពេញ | ឈ្មោះយោង |
|---|---|
| អណ្ដូងថ្មី ភូមិអណ្ដូង សង្កាត់គោករកា ខណ្ឌព្រែកព្នៅ* | អណ្ដូងថ្មី* |
| អណ្ដូងចាស់ ភូមិអណ្ដូង សង្កាត់គោករកា ខណ្ឌព្រែកព្នៅ* | អណ្ដូងចាស់* |
| ភូមិត្រពាំងអញ្ចាញ សង្កាត់ត្រពាំងក្រសាំង ខណ្ឌពោធិ៍សែនជ័យ* | ត្រពាំងអញ្ចាញ* |
| ភូមិទួលសំបូរ សង្កាត់ព្រៃវែង ខណ្ឌដង្កោ* | ទួលសំបូរ* |
| ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ* | ដំណាក់ត្រយឹង* |
| ភូមិស្រែអំពិល សង្កាត់ស្នោ ខណ្ឌពោធិ៍សែនជ័យ* | ស្រែអំពិល* |




| អាសយដ្ឋានពេញ | ឈ្មោះយោង |
|---|---|
| ភូមិអុង ឃុំរាម ស្រុកព្រៃនប់ | អូរកម្ពុជា+ |
| អូរត្រជាក់ចិត្ត [មិនបានសម្គាល់ឃើញឈ្មោះភូមិ] សង្កាត់ទំនប់រលក ខណ្ឌស្ទឹងហាវ | អូរត្រជាក់ចិត្ត |
| ភូមិមួយ សង្កាត់មួយ ក្រុងព្រះសីហនុ* | អភិវឌ្ឍដីថ្មី*+ |




| អាសយដ្ឋានពេញ | ឈ្មោះយោង |
|---|---|
| ភូមិវាល សង្កាត់សំបួរ ក្រុងសៀមរាប* | វាល* |




| អាសយដ្ឋានពេញ | ឈ្មោះយោង |
|---|---|
| ភូមិស្រែស្រណុកថ្មី ឃុំក្បាលរមាស ស្រុកសេសាន | ស្រែស្រណុកថ្មី |
| ភូមិក្បាលរមាសថ្មី ឃុំក្បាលរមាស ស្រុកសេសាន | ក្បាលរមាសថ្មី |

*ទីតាំងស្ថិតនៅក្នុងទីក្រុងសំខាន់ៗ

+ឈ្មោះដែលអ្នកភូមិតែងតែប្រើប្រាស់ជាឈ្មោះយោង

## ៣ វិធីសាស្ត្រ

ក្នុងឆ្នាំ២០១៩ សហជីពឥណទានមូលនិធិអូស្ត្រាលី (CUFA) ត្រូវបានចុះកិច្ចសន្យាជាមួយ ការិយាល័យ OHCHR ដើម្បីធ្វើការស្រាវជ្រាវ និងប្រមូលទិន្នន័យ។ បន្ទាប់ពី CUFA បានដាក់ជូនទិន្នន័យនៅដើមឆ្នាំ២០២០ ការិយាល័យ OHCHR បានជួលអ្នកប្រឹក្សាយោបល់ឱ្យធ្វើការវិភាគទិន្នន័យ និង រៀបចំរបាយការណ៍ចុងក្រោយស្តីពីស្ថានភាពសិទ្ធិមនុស្សរបស់សហគមន៍នានានៅតាមកន្លែងតាំងទីលំនៅថ្មី ចំនួន ១៧ កន្លែង រួមទាំងផ្តល់អនុសាសន៍ ថាតើការតាំងទីលំនៅថ្មីគួរអនុវត្តដោយរបៀបណា នៅក្នុងបរិបទរបស់ប្រទេសកម្ពុជា និង ស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ ដើម្បីបញ្ចប់ការងារចាត់តាំង អ្នកប្រឹក្សាយោបល់បានអនុវត្តការវិភាគបណ្តុំទិន្នន័យ ការពិនិត្យមើលលើឯកសារសរសេរពាក់ព័ន្ធ និង ការប្រឹក្សាយោបល់ជាមួយភាគីពាក់ព័ន្ធ ដោយប្រើវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស ដូច្នេះទស្សនសិទ្ធិមនុស្សគឺជាធាតុផ្សំជាមូលដ្ឋាននៅក្នុងការស្រាវជ្រាវ និង ការវិភាគទាំងមូល។ ដោយសារតែការដាក់កម្រិតនៃពេលវេលា និង ចំនួនទំព័រ បទសម្ភាសដទៃទៀតជាមួយអង្គការសង្គមស៊ីវិល និងលទ្ធផលនៃកិច្ចពិភាក្សាក្រុមគោលដៅ មិនត្រូវបានដាក់បញ្ចូលនៅក្នុងរបាយការណ៍នេះទេ។ ការស្រាវជ្រាវនេះ បានធ្វើឡើងមុនការរាតត្បាតនៃជំងឺកូវីដ១៩។

## ៤ ទំហំសំណាកនៃការស្ទង់មតិ

កាលពីឆ្នាំ២០១៧ មុនពេលអនុវត្តការស្ទង់មតិតាមគ្រួសាររបស់ CUFA ផ្អែកតាមការត្រួតពិនិត្យ និង ការប្រឹក្សាយោបល់ជាមួយ NGO ដៃគូ ការិយាល័យ OHCHR បានរកឃើញថាមានប្រជាពលរដ្ឋចំនួន ៣.៩១៤ គ្រួសារត្រូវបានបណ្តេញចេញទៅកាន់កន្លែងតាំងទីលំនៅថ្មីដែលត្រូវបានកំណត់ចំនួន១៧កន្លែង។ ការសិក្សានេះបានបញ្ជាក់ថា មានប្រជាពលរដ្ឋចំនួន ២.៣៤១ គ្រួសាររស់នៅក្នុងកន្លែងតាំងទីលំនៅថ្មី។ នៅទូទាំងកន្លែងតាំងទីលំនៅថ្មីទាំងអស់ មាន ៥១០ គ្រួសារកំពុងតែរស់នៅរាជធានីភ្នំពេញ និង អ្នកឆ្លើយតបចំនួន ១.៨៣១ គ្រួសារកំពុងតែរស់នៅតាមបណ្តាខេត្តទាំងប្រាំបី។ ចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៩ រហូតដល់ ខែមករា ឆ្នាំ២០២០ ការសិក្សានេះបានផ្ទៀងផ្ទាត់ចំនួនគ្រួសារសរុបតាមរយៈការរាប់ចំនួនគ្រួសារដោយផ្ទាល់ នៅតាមកន្លែងនីមួយៗ និង តាមរយៈការផ្ទៀងផ្ទាត់ចំនួនទាំងនោះជាមួយអាជ្ញាធរមូលដ្ឋាន ប្រធានភូមិ និង សមាជិកភូមិ និង សហគមន៍ផ្សេងៗគ្នា។ តារាង ២ ផ្តល់នូវការបំបែកទិន្នន័យតាមកន្លែងតាំងទីលំនៅ ព្រមទាំងទំហំនៃសំណាក ដែលរបាយការណ៍បានប្រើប្រាស់សម្រាប់កន្លែងនីមួយៗ។

**តារាងទី២៖ ចំនួនគ្រួសារដែលត្រូវបានកំណត់ និង ចំនួនសំណាកតាមទីតាំង (តាមលំដាប់លំដោយនៃតួអក្សរ)**

| កន្លែងតាំងទីលំនៅថ្មី | ចំនួនគ្រួសារដែលត្រូវបានកំណត់ | | | |
|---|---|---|---|---|
| ទីតាំង | OHCHR (២០១៦-២០១៧) | Cufa (២០១៩-២០២០) | ភាពខុសគ្នា | ចំនួនសំណាក (២៥%/៣២%) |
| អណ្តូងចាស់ (ភ្នំពេញ)* | ៦០០ | ១៣០ | -៤៧០ | ៤២ |
| អណ្តូងថ្មី (ភ្នំពេញ)* | ៣៨៤ | ២២០ | -១៦៤ | ៧០ |
| អភិវឌ្ឍដីថ្មី (ព្រះសីហនុ)* | ៥៥ | ៨ | -៤៧ | ៣ |
| អូរបាត់មាន់ (ឧត្តរមានជ័យ) | ២១៤ | ៧៤ | -១៤០ | ២៤ |
| ដំណាក់ត្រយឹង (ភ្នំពេញ)* | ៩១ | ៥៦ | -៣៥ | ១៨ |
| ក្បាលរមាសថ្មី (ស្ទឹងត្រែង) | ២០០ | ៤០០ | ២០០ | ៩៨ |
| ស្រែស្រណុកថ្មី (ស្ទឹងត្រែង) | ១៨០ | ៦០០ | ៤២០ | ១៤៧ |
| អូរកម្ពុជា (ព្រះសីហនុ) | ៤៦ | ១១ | -៣៥ | ៤ |
| អូរត្រជាក់ចិត្ត (ព្រះសីហនុ) | ១៩ | ១៩ | ០ | ៦ |

| | | | | |
|---|---|---|---|---|
| ពីស (កំពង់ស្ពឺ) | ១០០ | ៧៤ | -២៦ | ២៤ |
| ព្រៃកូនសេក (បាត់ដំបង)* | ៥៥ | ១៥ | -៤០ | ៥ |
| ព្រៃស្វាធ់ (កោះកុង) | ៨០០ | ៤០០ | -៤០០ | ៩៨ |
| ស្រះពោធិ៍ (កណ្ដាល) | ១៤០ | ១២០ | -២០ | ៣៨ |
| ស្រែអំពិល(ភ្នំពេញ)* | ១៦៨ | ១៦ | -១៥២ | ៥ |
| ត្រពាំងអញ្ចាញ(ភ្នំពេញ)* | ១៤៨ | ៤៨ | -១០០ | ១៥ |
| ទួលសំបូរ (ភ្នំពេញ)* | ៤០ | ៤០ | ០ | ១៣ |
| វាល (សៀមរាប)* | ៦៧៤ | ១១០ | -៥៦៤ | ៣៥ |
| **សរុប** | ៣.៩១៤ | ២.៣៤១ | -១.៥៧៣ | ៦៤៥ |

ដូចតារាងបានបង្ហាញ នៅ ១៥ ទីតាំង ក្នុងចំណោមទីតាំងទាំង ១៧ ចំនួនគ្រួសារដែលរស់នៅក្នុង ទីតាំងនីមួយៗមានការថយចុះ។ ការថយចុះទាំងនេះដោយសារគ្រួសារទាំងនោះ៖

- ត្រូវបានផ្ដល់ជូនតែដីធ្លីប៉ុណ្ណោះ និងគ្មានផ្ទះសម្បែងសម្រាប់រស់នៅ
- សម្រេចចិត្តមិនផ្លាស់ទី និង ទៅរស់នៅកន្លែងតាំងទីលំនៅថ្មី ពីព្រោះពួកគេចាំបាច់ត្រូវដំណើរការអាជីវកម្មរបស់ពួកគេនៅក្នុងតំបន់នៃទីលំនៅដើមរបស់ពួកគេ
- បានធ្វើទេសន្តរប្រវេសន៍ទៅក្រៅប្រទេស ឬ បានផ្លាស់ទីទៅកាន់ទីកន្លែងមួយផ្សេងទៀតដើម្បីរកការងារធ្វើ ឬ
- បានជួល ឬ លក់ផ្ទះរបស់ពួកគេនៅកន្លែងតាំងទីលំនៅថ្មីទៅឱ្យអ្នកដែលមិនត្រូវបានបណ្ដេញចេញ។

ការសិក្សានេះបានបង្ហាញ ការកើនឡើងនៃចំនួនគ្រួសារនៅតាមទីតាំងផ្សេងទៀត (ក្បាលរមាសថ្មី និង ស្រែស្រណុកថ្មីនៅខេត្តស្ទឹងត្រែង) គឺដោយសារតែមានគ្រួសារជាច្រើនបានផ្លាស់មកកាន់កន្លែងតាំងទីលំនៅថ្មីទាំងនេះ តាំងពីឆ្នាំ២០១៧ មកម្លេះ នៅពេលដែលការិយាល័យ OHCHR បានរាប់ចំនួនគ្រួសារដែលរស់នៅកន្លែងទាំងនោះជាលើកដំបូង។ នៅពេលដែលពួកគេចុះទៅកាន់កន្លែងទាំងនោះ ការិយាល័យ OHCHR បានទទួលដំណឹងថានឹងមានប្រជាពលរដ្ឋជាច្រើនកំពុងតែមកដល់ ប៉ុន្តែ ការិយាល័យ OHCHR មិនបានទទួលព័ត៌មានអំពីតួលេខជាក់លាក់ដែលត្រូវបានរំពឹងទុកនោះទេ។

ពាក់ព័ន្ធនឹងទំហំសំណាក របាយការណ៍នេះបានប្រើប្រាស់ ២៥ ភាគរយសម្រាប់ទីតាំងបីដែលធំជាងគេបំផុត (ក្បាលរមាសថ្មី និង ស្រែស្រណុកថ្មីនៅខេត្តស្ទឹងត្រែង និង ព្រៃស្វាធ់នៅខេត្តកោះកុង) និង ៣២ ភាគរយសម្រាប់កន្លែងតាំងទីលំនៅថ្មីចំនួន ១៤ កន្លែងផ្សេងទៀត។ ទំហំសំណាកដែលអាចទុកចិត្តបានទាំងនេះ ត្រូវបានគណនាដោយផ្អែកលើចំនួនបទសម្ភាសនៃការស្ទង់មតិដែលត្រូវបានធ្វើឡើងនៅតាមកន្លែងតាំងទីលំនៅថ្មីខុសៗគ្នា។[2]

2 ទំហំសំណាកអតិបរមាដ៏ល្អមួយ តាមធម្មតា គឺប្រហែល ១០ ភាគរយនៃចំនួនប្រជាជន។ សម្រាប់របាយការណ៍នេះ ទំហំសំណាកមានការប្រែប្រួល ពី ២៥ ភាគរយ ទៅ ៩០ ភាគរយ ទៅតាមកន្លែងតាំងទីលំនៅថ្មីខុសៗគ្នា។

## ៥ ភាពខ្វះចន្លោះនៅក្នុងការស្រាវជ្រាវ និង ភស្តុតាង

របាយការណ៍នេះគ្របដណ្តប់លើការវិភាគទិន្នន័យមូលដ្ឋាន។ នេះដោយសារតែទិន្នន័យឆៅមានទំហំធំ និង ការដាក់កម្រិតពេលវេលាក្នុងការអនុវត្តការវិភាគគ្រប់ជ្រុងជ្រោយ ជាពិសេស ការភ្ជាប់ទំនាក់ទំនងទៅវិញទៅមករវាងបញ្ហាខុសៗគ្នា (ឧ. ជីវភាពរស់នៅ និង សន្តិសុខស្បៀង)។ មានការណែនាំថា ការវិភាគទិន្នន័យបន្ថែមត្រូវធ្វើឡើងតាមផ្នែកជាក់លាក់នៃការស្រាវជ្រាវ រួមមានជាអាទិ៍ សន្តិសុខស្បៀង បំណុល និង បញ្ហាសិទ្ធិមនុស្សដទៃទៀត។

តាមស្ថិតិ ស្ត្រី ៥៨ ភាគរយ និង បុរស ៤២ ភាគរយ ត្រូវបានសម្ភាស។ ការវិភាគនៅក្នុងការស្រាវជ្រាវនេះបានរួមបញ្ចូលយេនឌ័រ និង ធានាថាសម្លេងរបស់ស្ត្រីត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការស្ទង់មតិ។ ផ្នែកជាក់លាក់នៃកម្រងសំណួរត្រូវបានរៀបចំឡើង ដើម្បីទាញយកចម្លើយអំពីរបៀបដែលស្ត្រីទទួលរងផលប៉ះពាល់ខុសពីបុរស ហើយនៅពេលដែលនិន្នាការនានាត្រូវបានគេឃើញថាមាននៅក្នុងទិន្នន័យនោះ និន្នាការទាំងនេះត្រូវបានចង្អុលបង្ហាញនៅក្នុងរបាយការណ៍។ ទោះបីជាយ៉ាងណាក៏ដោយ មានការលំបាកនៅក្នុងការបែងចែកទិន្នន័យតាមយេនឌ័រ ពីព្រោះអ្នកឆ្លើយតបបានតំណាងឱ្យគ្រួសាររបស់ពួកគេទាំងមូល និង មិនចាំបាច់និយាយតាងនាមឱ្យខ្លួនពួកគេផ្ទាល់នោះទេ។ គ្រួសារទាំងឡាយមិនអាចបែងចែកយេនឌ័របាននោះទេ ពីព្រោះពួកគេមានសមាជិកទាំងបុរស និង ស្ត្រី។

នៅពេលដំបូង មានការលំបាកនៅក្នុងការធ្វើការការស្ទង់មតិនៅភ្នំពេញ និង ខេត្តកោះកុង ដោយសារតែឧបសគ្គនានាដែលបង្កឡើងដោយអាជ្ញាធរមូលដ្ឋាន ដែលមិនគាំទ្រដល់ការស្ទង់មតិនៅកន្លែងតាំងទីលំនៅថ្មី និង មិនចង់ជួបជាមួយក្រុមការងារស្រាវជ្រាវដើម្បីពិភាក្សាគ្នាអំពីការស្ទង់មតិ។ នៅទីបំផុត ការលំបាកទាំងនេះត្រូវបានជំនះដោយ CUFA ទទួលបានការអនុញ្ញាតឱ្យធ្វើការស្ទង់មតិ ប៉ុន្តែពួកគេបានធ្វើឱ្យមានភាពយឺតយ៉ាវនៅក្នុងការអនុវត្តការស្ទង់មតិ។

ប្រជាពលរដ្ឋចំនួនសែសិបគ្រួសារ[3] បានសម្រេចចិត្តមិនចូលរួមនៅក្នុងការស្ទង់មតិនេះទេ ដោយសារមូលហេតុមួយក្នុងចំណោមមូលហេតុទាំងពីរគឺថា៖ ពួកគេពុំមានពេលវេលាគ្រប់គ្រាន់ ឬ ពួកគេបានស្នើសុំគ្រឿងលើកទឹកចិត្តមុនពេលដែលពួកគេអាចនឹងមានបំណងចង់ចូលរួម។ អាជ្ញាធរមូលដ្ឋានចំនួន ១១ នាក់ នៅភ្នំពេញ និង ខេត្តព្រះសីហនុ បានបដិសេធមិនទទួលយកការសម្ភាសនោះទេ។ អាជ្ញាធរទាំងនោះបាននិយាយថា ពួកគេពុំមានពេលវេលាសម្រាប់ជួបគ្នានោះទេ ហើយអាជ្ញាធរមួយចំនួនទៀតហាក់បីដូចជាមិនចង់ចែករំលែកព័ត៌មានអំពីកន្លែងតាំងទីលំនៅថ្មីនោះទេ។ ក្នុងករណីមួយចំនួន អាជ្ញាធរពុំមានព័ត៌មានអំពីកន្លែងតាំងទីលំនៅថ្មីនោះទេ ដោយសារពួកគេមិនបានចូលកាន់តំណែង នៅពេលដែលកន្លែងតាំងទីលំនៅថ្មីត្រូវបានបង្កើតឡើង។



ផ្ទះដែលបានផ្តល់អោយជាសំណងមានទីតាំងនៅក្នុងអណ្តូងថ្មី ស្ថិតក្នុងភូមិអណ្តូង, សង្កាត់គោករកា, ខ័ណ្ឌព្រែកព្នៅ, រាជធានីភ្នំពេញ។ រូបថត ៖ CUFA



ហាលសំលៀកបំពាក់នៅខាងមុខផ្ទះរបស់សហគមន៍ មុន្នីវង្ស AB ដែលត្រូវបានតាំងទីលំនៅថ្មី នៅភូមិស្រែអំពិល, សង្កាត់ស្នោរ, ខ័ណ្ឌដង្កោ, រាជធានីភ្នំពេញ។ រូបថត ៖ CUFA

3 គ្រួសារទាំងនេះមកពីព្រែកស្វាច់ ខេត្តកោះកុង (បួនគ្រួសារ) ភ្នំពេញ (៣០ គ្រួសារមកពីទីតាំងទាំងប្រាំមួយ) វាល ខេត្តសៀមរាប (បួនគ្រួសារ) និង ស្រែស្រណុកថ្មី ខេត្តស្ទឹងត្រែង (ពីរគ្រួសារ)។

# ជំពូក

# ១

# សេចក្តីផ្តើម

# ជំពូក ១៖ សេចក្ដីផ្ដើម

## ១.១ អ្នកឆ្លើយតប

### ភ្នំពេញ/ខេត្ត យេនឌ័រ អាយុ

- របាយការណ៍នេះបានសិក្សាពីអ្នកឆ្លើយតបចំនួន ៦៤៥ នាក់ ដែលម្នាក់តំណាងឱ្យមួយគ្រួសារ។
- អ្នកឆ្លើយតបកំពុងតែរស់នៅតាមកន្លែងតាំងទីលំនៅថ្មីទាំង ១៧ កន្លែង នៅភ្នំពេញ និង ខេត្តទាំង ៨។
- ៥៨ ភាគរយនៃអ្នកឆ្លើយតបជាស្ត្រី និង ៤២ ភាគរយទៀតជាបុរស។
- ៧៥ ភាគរយនៃអ្នកឆ្លើយតបកំពុងតែរស់នៅតាមបណ្ដាខេត្ត និង ៥៨% ក្នុងចំណោមពួកគេ គឺជាស្ត្រី។
- ២៥ ភាគរយនៃអ្នកឆ្លើយតបកំពុងតែរស់នៅភ្នំពេញ និង ៥៨% ក្នុងចំណោមពួកគេ គឺជាស្ត្រី។

តារាងទី៣ ផ្ដល់ការបែងចែកអ្នកឆ្លើយតបតាមយេនឌ័រ នៅតាមកន្លែងតាំងទីលំនៅថ្មីនីមួយៗ។
តារាងទី៤ បង្ហាញអំពីក្រុមអាយុរបស់អ្នកឆ្លើយតប។

**តារាងទី៣៖ ការបែងចែកអ្នកឆ្លើយតបតាមយេនឌ័រ**

| ខេត្ត និង កន្លែងតាំងទីលំនៅថ្មី | | ស្ត្រី | បុរស |
|---|---|---|---|
| បាត់ដំបង | ព្រៃកូនសេក* | ៤០% | ៦០% |
| កំពង់ស្ពឺ | ពិស | ៥៤% | ៤៦% |
| កណ្ដាល | ស្រះពោធិ៍ | ៨២% | ១៨% |
| កោះកុង | ព្រែកស្មាច់ | ៥៤% | ៤៦% |
| ឧត្ដរមានជ័យ | អូរបាត់មាន់ | ៥០% | ៥០% |
| ភ្នំពេញ | | ៥៨% | ៤២% |
| | អណ្ដូងចាស់* | ៥២% | ៤៨% |
| | អណ្ដូងថ្មី* | ៦០% | ៤០% |
| | ដំណាក់ត្រយឹង* | ៦១% | ៣៩% |
| | ស្រែអំពិល* | ៤០% | ៦០% |
| | ត្រពាំងអញ្ចាញ* | ៦៧% | ៣៣% |
| | ទួលសំបូរ* | ៦២% | ៣៨% |
| ព្រះសីហនុ | | ៥៤% | ៤៦% |
| | អភិវឌ្ឍដីថ្មី* | ៦៧% | ៣៣% |
| | អូរកម្ពុជា | ៥០% | ៥០% |
| | អូរត្រជាក់ចិត្ត | ៥០% | ៥០% |
| សៀមរាប | វាល* | ៦៣% | ៣៧% |
| ស្ទឹងត្រែង | | ៥៨% | ៤២% |
| | ក្បាលរមាសថ្មី | ៥៥% | ៤៥% |
| | ស្រែស្រណុកថ្មី | ៥៩% | ៤១% |
| សរុបរួម | | ៥៨% | ៤២% |

**តារាងទី៤៖ ក្រុមអាយុរបស់អ្នកឆ្លើយតប**

| ក្រុមអាយុ | សរុប | ស្ត្រី | បុរស |
|---|---|---|---|
| ក្រោម ២១ឆ្នាំ* | ៣,៣% | ៤,៣% | ១,៩% |
| អាយុ ២១-២៩ឆ្នាំ | ១៤,៤% | ១៦,២% | ១១,៩% |
| អាយុ ៣០-៣៩ឆ្នាំ | ២២,៦% | ២០,៥% | ២៥,៧% |
| អាយុ ៤០-៤៩ឆ្នាំ | ១៩,២% | ១៧,៣% | ២១,៩% |
| អាយុ ៥០-៥៩ឆ្នាំ | ១៩,៥% | ១៩,៤% | ១៩,៧% |
| អាយុ ៦០-៦៩ឆ្នាំ | ១២,៩% | ១៣,៦% | ១១,៩% |
| អាយុ ៧០-៧៩ឆ្នាំ | ៦,៤% | ៧,៧% | ៤,៥% |
| អាយុ ៨០-៨៩ឆ្នាំ | ១,៦% | ១,១% | ២,២% |
| អាយុ ៩០-៩៩ឆ្នាំ | ០,២% | ០,០% | ០,៤% |
| **សរុបរួម** | **១០០,០%** | **១០០,០%** | **១០០,០%** |

* ២១ឆ្នាំ គឺជាអាយុស្របច្បាប់នៅក្នុងប្រទេសកម្ពុជា។

## គ្រួសារជនជាតិដើមភាគតិច

ដប់ប្រាំភាគរយនៃអ្នកឆ្លើយតបសរុបបានកំណត់អត្តសញ្ញាណខ្លួនពួកគេថាជាជនជាតិដើមភាគតិច (៥៦ ភាគរយ ជាស្ត្រី) ហើយពួកគេទាំងអស់រស់នៅក្បាលរមាសថ្មី និង ស្រែស្រណុកថ្មី នៅក្នុងខេត្តស្ទឹងត្រែង។ កៅសិបប្រាំភាគរយនៃអ្នកឆ្លើយតបដែលកំពុងរស់នៅក្បាលរមាសថ្មី និង ២ ភាគរយដែលកំពុងរស់នៅស្រែស្រណុកថ្មីជាជនជាតិដើមភាគតិច។ជនជាតិដើមភាគតិចនៅក្បាលរមាសថ្មីតំណាងឱ្យ១៤,៤ភាគរយនៃចំនួនអ្នកឆ្លើយតបសរុប និង ជនជាតិដើមភាគតិចនៅស្រែស្រណុកថ្មី តំណាងឱ្យ ០,៥ ភាគរយនៃចំនួនអ្នកឆ្លើយតបសរុប។ ជនជាតិដើមភាគតិចទាំងអស់ មានចំនួន ២០ ភាគរយ ក្នុងចំណោមអ្នកឆ្លើយតបដែលរស់នៅតាមបណ្តាខេត្ត និង តំណាងឱ្យក្រុមជនជាតិដើមភាគតិចចំនួនប្រាំពីរក្រុម (ប៊ូនង ប្រៅ ព្រៅ គ្រឹង កួយ លាវ និង ទំពួន)។ ក្រុមជនជាតិដើមភាគតិចដែលតំណាងឱ្យអ្នកឆ្លើយតបច្រើនជាងគេបំផុត គឺ ប៊ូនង (៧៥ ភាគរយ) និង ប្រៅ (២១ ភាគរយ)។

នៅពេលដែលអាចធ្វើបាន របាយការណ៍នេះបានបែងចែកទិន្នន័យ និង បានវិភាគអំពីបទពិសោធន៍របស់គ្រួសារជនជាតិដើមភាគតិច។

## ទីតាំងបណ្តេញចេញ

- ចំនួនសរុបនៃទីតាំងបណ្តេញចេញដែលតំណាងដោយអ្នកឆ្លើយតប មានចំនួន ៣៧ កន្លែង ដែលក្នុងនោះ ប្រាំពីរកន្លែង (១៩ ភាគរយ) ស្ថិតនៅភ្នំពេញ។
- ឧបសម្ព័ន្ធទី១ ផ្តល់បញ្ជីឈ្មោះទីតាំងបណ្តេញចេញរួមជាមួយអាសយដ្ឋានពេញ និង ឈ្មោះកាត់របស់ពួកគេ ដែលត្រូវបានប្រើប្រាស់ជាការយោងដល់នៅក្នុងរបាយការណ៍នេះ។
- ឧបសម្ព័ន្ធទី២ រៀបរាប់ឈ្មោះទីតាំងបណ្តេញចេញដែលស្ថិតនៅក្រោមកន្លែងតាំងទីលំនៅថ្មីនីមួយៗ។ ក្នុងករណីមួយចំនួន អ្នកឆ្លើយតបដែលមកពីទីតាំងបណ្តេញចេញតែមួយត្រូវបានផ្លាស់ទីទៅកាន់កន្លែងតាំងទីលំនៅថ្មីខុសៗគ្នា។[4]

4 ឧទាហរណ៍៖ អ្នកឆ្លើយតបដែលត្រូវបានជ្រើសរើសពីសហគមន៍អគារសំបុកចាបនៅភ្នំពេញ ត្រូវបានបណ្តេញចេញទៅកាន់កន្លែងតាំងទីលំនៅថ្មីចំនួនបីនៅភ្នំពេញ (អណ្តូងថ្មី អណ្តូងចាស់ និង ទួលសំបូរ)។ អ្នកឆ្លើយតបមួយចំនួនទៀតត្រូវបានផ្លាស់ទីទៅកន្លែងដែលនៅក្នុងភូមិតែមួយ ឧទាហរណ៍ អ្នកដែលមកពី ភូមិពីស ក្នុងខេត្តកំពង់ស្ពឺ។

## ទំហំគ្រួសារ និង មុខតំណែងនៅក្នុងគ្រួសារ

- ដូចដែល តារាងទី៥ បានបង្ហាញ ចំនួនបុគ្គលដែលត្រូវបានតំណាងឱ្យច្រើនជាងគេបំផុតនៅក្នុងមួយគ្រួសារ គឺ ប្រាំ (២៣ ភាគរយ) បួន (២០ ភាគរយ) បី (១៦ ភាគរយ) និង ប្រាំមួយ (១៥ ភាគរយ)។
- ហាសិបប្រាំភាគរយនៃអ្នកឆ្លើយតបគឺជាមេគ្រួសារ ៣៨ ភាគរយគឺជាសមាជិកគ្រួសារ និង ៧ ភាគរយគឺជាស្វាមី/ភរិយារបស់មេគ្រួសារ។
- នៅខណៈពេលដែល ៧២ ភាគរយនៃសមាជិកគ្រួសារ និង ៩៤ ភាគរយនៃស្វាមី/ភរិយាទាំងនោះគឺជាស្ត្រី ៧០ ភាគរយនៃមេគ្រួសារគឺជាបុរស។
- ហាសិបភាគរយនៃជនជាតិដើមភាគតិចគឺជាស្វាមី/ភរិយារបស់មេគ្រួសារ ៤៥ ភាគរយគឺជាមេគ្រួសារ និង ៥ ភាគរយគឺជាសមាជិកគ្រួសារ។ នៅខណៈពេលដែល ៩៨ ភាគរយនៃស្វាមី/ភរិយា គឺជាស្ត្រី ៨៨ ភាគរយនៃមេគ្រួសារ និង ៦០ ភាគរយនៃសមាជិកគ្រួសារ គឺជាបុរស។

**តារាងទី៥៖ ទំហំគ្រួសារ**

| ចំនួនបុគ្គល | ភាគរយនៃអ្នកឆ្លើយតប | ចំនួនបុគ្គល | ភាគរយនៃអ្នកឆ្លើយតប |
|---|---|---|---|
| ១ | ២,៩% | ១០ | ១,២% |
| ២ | ៤,២% | ១១ | ១,២% |
| ៣ | ១៥,៥% | ១២ | ០,៥% |
| ៤ | ២០,២% | ១៣ | ០,៦% |
| ៥ | ២២,៦% | ១៤ | ០,៣% |
| ៦ | ១៤,៧% | ១៥ | ០,២% |
| ៧ | ៧,៨% | ១៦ | ០,២% |
| ៨ | ៥,១% | ២០ | ០,២% |
| ៩ | ២,៥% | ២២ | ០,២% |

## ស្ថានភាពគ្រួសារ

- ហុកសិបប្រាំមួយភាគរយនៃស្ត្រីជាមេគ្រួសារគឺជាស្ត្រីមេម៉ាយ និង ៣០ ភាគរយនៃស្ត្រីជាសមាជិកគ្រួសារបានរៀបអាពាហ៍ពិពាហ៍រួចហើយ។
- កៅសិបពីរភាគរយនៃបុរសជាមេគ្រួសារបានរៀបអាពាហ៍ពិពាហ៍រួចហើយ និង ៨៣ ភាគរយនៃបុរសជាសមាជិកគ្រួសារបានរៀបអាពាហ៍ពិពាហ៍រួចហើយ។
- ក្នុងចំណោមជនជាតិដើមភាគតិច ស្ត្រីជាមេគ្រួសារគ្រប់រូបគឺជាស្ត្រីមេម៉ាយ ពាក់កណ្តាលនៃស្ត្រីជាសមាជិកគ្រួសារ នៅលីវ និង ពាក់កណ្តាលទៀតបានរៀបអាពាហ៍ពិពាហ៍រួចហើយ។
- ក្នុងចំណោមបុរសជនជាតិដើមភាគតិច បុរសជាមេគ្រួសារគ្រប់រូបបានរៀបអាពាហ៍ពិពាហ៍រួចហើយ និង ៦៧ ភាគរយនៃសមាជិកគ្រួសារនៅលីវ។

## ទេសន្តរប្រវេសន៍

- ដប់ភាគរយនៃអ្នកឆ្លើយតបសរុបបាននិយាយថា មិនមែនសមាជិកគ្រួសាររបស់ពួកគេគ្រប់រូបសុទ្ធតែរស់នៅកន្លែងតាំងទីលំនៅថ្មីនោះទេ។ ជនជាតិដើមភាគតិចចំនួនបួនភាគរយ បានឆ្លើយតបដូចគ្នា។
- ដូច រូបភាពទី១ បង្ហាញ ជាមធ្យម ៨ ភាគរយនៃអ្នកឆ្លើយតបនៅកន្លែងតាំង ទីលំនៅថ្មីចំនួន ១៣ កន្លែង ក្នុងចំណោមកន្លែងតាំងទីលំនៅថ្មីទាំង ១៧ កន្លែង មានសមាជិកគ្រួសារយ៉ាងតិចម្នាក់ ដែលបានធ្វើទេសន្តរប្រវេសន៍ទៅខាងក្រៅកន្លែងតាំងទីលំនៅថ្មី។
- មានសមាជិកគ្រួសារចំនួនប្រាំបីប្រភេទបានធ្វើទេសន្តរប្រវេសន៍ទៅខាងក្រៅកន្លែងតាំងទីលំនៅថ្មី។ សមាជិកគ្រួសារបួនប្រភេទសំខាន់ៗ រួមមាន កូនប្រុស (៣៦ ភាគរយ) កូនស្រី (៣៦ ភាគរយ) ចៅ (៩ ភាគរយ) និង បង/ប្អូនប្រុស (៧ ភាគយ)។

- សមាជិកគ្រួសារម្នាក់ៗដែលបានធ្វើទេសន្តរប្រវេសន៍មានមូលហេតុមួយ ឬ ច្រើនសម្រាប់ការផ្លាស់ចេញពីកន្លែងតាំងទីលំនៅថ្មី ហើយអ្នកឆ្លើយតបម្នាក់ៗបានផ្តល់ចម្លើយមួយ ឬ ច្រើន។ មានមូលហេតុចំនួនប្រាំបីខុសៗគ្នា។ មូលហេតុបីសំខាន់ៗ រួមមាន ទៅធ្វើការ ឬ ទៅធ្វើអាជីវកម្មនៅកន្លែងផ្សេងទៀត (៦១ ភាគរយនៃចម្លើយដែលបានរាប់), ទៅរស់នៅជាមួយស្វាមី/ភរិយាដែលទើបតែរៀបអាពាហ៍-ពិពាហ៍រួច (១៣ ភាគរយ) និង ទៅសិក្សានៅទីប្រជុំជន ឬ នៅទីក្រុង (៧ ភាគរយ)។ មូលហេតុចំនួនប្រាំផ្សេងទៀតដែលអ្នកឆ្លើយតបបានផ្តល់ជូន រួមមាន ទៅរស់នៅប្រទេសផ្សេងទៀត ទៅរស់នៅជាមួយសាច់ញាតិ ទៅរស់នៅជាមួយឪពុកម្តាយ/សាច់ញាតិនៅតាមបណ្តាខេត្ត/នៅទីឆ្ងាយ ទៅរស់នៅទីក្រុង/ចំណុចកណ្តាល និង ទៅបួស។



បន្ទប់ទឹក និងបាសាំងលាងដៃនៅក្នុងផ្ទះដែលបោះបង់ចោលនៅតំបន់តាំងទីលំនៅថ្មី អណ្តូងថ្មី នៅក្នុង ភូមិអណ្តូង សង្កាត់គោករកា, ខណ្ឌព្រែកព្នៅ, រាជធានីភ្នំពេញ។ រូបថត ៖ CUFA

## រូបភាពទី១៖ សមាជិកគ្រួសារដែលបានចាកចេញពីកន្លែងតាំងទីលំនៅថ្មី



# ១.២ ក្របខណ្ឌច្បាប់ និង គោលនយោបាយ

## បទដ្ឋានច្បាប់អន្តរជាតិ

សិទ្ធិមានលំនៅឋានត្រូវបានធានាដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ មាត្រា ២៥ នៃ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស, មាត្រា ១១ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, មាត្រា ៥ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ និង មាត្រា ១៤ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ចែងអំពីក្របខណ្ឌនៃនិយាម ព្រមទាំង កាតព្វកិច្ចតាមផ្លូវច្បាប់ផងដែរ។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នដល់សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិទាំងនេះ ដែល យោងតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា ប្រជាជនកម្ពុជាអាចទទួលបានសិទ្ធិនានាដែលត្រូវបានទទួលស្គាល់នៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ។ អនុសញ្ញាដទៃទៀត ដែលត្រូវបានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជា បានពង្រីកការការពារសិទ្ធិទទួលបានកម្រិតជីវភាពរស់នៅសមរម្យ និង បានបញ្ជាក់ថា សិទ្ធិនេះត្រូវតែបានទទួលស្គាល់ដោយគ្មានការរើសអើង។

សិទ្ធិមានលំនៅឋានសមរម្យ គឺជាផ្នែកមួយនៃសិទ្ធិមានកម្រិតជីវភាពរស់នៅសមរម្យ។ សិទ្ធិមានលំនៅឋានសមរម្យមិនសំដៅលើតែសំណង់ដែលប្រជាពលរដ្ឋអាចរស់នៅបានតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរួមបញ្ចូលលក្ខខណ្ឌដែលចាំបាច់ដើម្បីធានាចំពោះទីតាំងរស់នៅប្រកបដោយផាសុកភាពផងដែរ។ យោងតាមអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (ICESCR)[5] មានសមាសធាតុចំនួនប្រាំពីរចំពោះសិទ្ធិមានលំនៅឋានសមរម្យ។ មានសុវត្ថិភាពក្នុងការកាន់កាប់តាមផ្លូវច្បាប់ លទ្ធភាពក្នុងការទទួលបានសេវា សម្ភារៈបរិក្ខារ អគារ និង ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ភាពអាចលៃលកផ្គត់ផ្គង់បាន ភាពអាចរស់នៅបាន ភាពអាចចេញចូលបាន ទីតាំងសមរម្យ និង ភាពសមស្របផ្នែកវប្បធម៌។ សិទ្ធិមានលំនៅឋានសមរម្យក៏រួមបញ្ចូលការការពារ ប្រឆាំងនឹងការបណ្តេញចេញដោយបំពាន និង ការបំផ្លិចបំផ្លាញ និង ការកម្ទេចផ្ទះសម្បែងរបស់បុគ្គលណាម្នាក់តាមទំនើងចិត្ត។ សិទ្ធិមានលំនៅឋានសមរម្យ និង ការការពារពីការបណ្តេញចេញដោយបង្ខំ និង មិនស្របច្បាប់ ក៏ត្រូវបានធានាដោយបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដទៃទៀតផងដែរ ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន។[6]

សេចក្តីពន្យល់រួមលេខ ៧ ស្តីពីសិទ្ធិមានលំនៅឋានសមរម្យ ចែងថា ការបណ្តេញចេញដោយបង្ខំ នៅពេលក្រឡេកឃើញភ្លាម មានការប្រឆាំងនឹងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌។[7] សេចក្តីពន្យល់រួមបានចែងបន្ថែមទៀតអំពីកិច្ចការពារយ៉ាងជាក់លាក់ និង ការធានាផ្នែកនីតិវិធីដែលពាក់ព័ន្ធនឹងការបណ្តេញចេញដោយបង្ខំ ដែលរួមបញ្ចូល បទដ្ឋានអប្បបរមាដែលចាំបាច់សម្រាប់ការអនុវត្តការបណ្តេញចេញ និង កំណត់កាលៈទេសៈនៅក្រោមការបណ្តេញចេញដែលនឹងត្រូវចាត់ទុកថាមិនស្របច្បាប់ និង "បង្ខំ" ស្របតាមបទដ្ឋានអន្តរជាតិ។ កាលពីឆ្នាំ២០០៧ អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីសិទ្ធិមានលំនៅឋានសមរម្យ ដែលជាសមាសធាតុមួយនៃសិទ្ធិមានកម្រិតជីវភាពរស់នៅសមរម្យ និង ស្តីពីសិទ្ធិមិនរើសអើងនៅក្នុងបរិបទនេះ (អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមានលំនៅឋានសមរម្យ) បានចេញ "គោលការណ៍ជាមូលដ្ឋាន និង គោលការណ៍ណែនាំស្តីពីការបណ្តេញចេញ និង ការចាកចេញដោយបង្ខំចិត្ត ផ្អែកលើការអភិវឌ្ឍ"(២០០៧)។[8] គោលការណ៍ណែនាំទាំងនេះបានផ្តោតលើផលប៉ះពាល់សិទ្ធិមនុស្សដោយការបណ្តេញចេញ និង ការផ្លាស់ទីលំនៅដោយបង្ខំចិត្ត ដែលមានទំនាក់ទំនងទៅនឹងការអភិវឌ្ឍ។ នៅខែធ្នូ ឆ្នាំ២០១៩ អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីសិទ្ធិទទួលបានលំនៅឋានសមរម្យ បានចេញគោលការណ៍ណែនាំសម្រាប់ការអនុវត្តសិទ្ធិមានលំនៅឋានសមរម្យ[9] ដែលបានកំណត់នូវធាតុសំខាន់ៗដែលចាំបាច់សម្រាប់ការអនុវត្តសិទ្ធិមានលំនៅឋានបានយ៉ាងមានប្រសិទ្ធភាព ដោយមានផ្នែកជាក់លាក់មួយលើកឡើងអំពីការបណ្តេញចេញដោយបង្ខំ។ គោលការណ៍ណែនាំឆ្នាំ២០១៩ ក៏បានរួមបញ្ចូលផ្នែកនានា[10] ស្តីពីតួនាទីរបស់អាជ្ញាធរមូលដ្ឋាននៅក្នុងការអនុវត្តសិទ្ធិមានលំនៅឋានសមរម្យ តួនាទីរបស់វិស័យឯកជន និងភាពចាំបាច់ក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុ។

---

5 មហាសន្និបាតអង្គការសហប្រជាជាតិ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ អង្គការសហប្រជាជាតិ បណ្តុំអនុសញ្ញាច្បាប់ទី ៩៩៣ មាត្រា ១១(១)https://www.ohchr.org/en/professionalinterest/pages/cescr.aspx បានចូលប្រើប្រាស់នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០។

6 ចូរមើល អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ (ICCPR) អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (CERD) អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) អនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC) អនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRPD) និង អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និង សមាជិកគ្រួសាររបស់ពួកគេ (CMW)។

7 គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (CESCR) នៃអង្គការសហប្រជាជាតិ សេចក្តីពន្យល់រួមលេខ ៧៖ សិទ្ធិមានលំនៅឋានសមរម្យ (មាត្រា ១១.១)៖ ការបណ្តេញចេញដោយបង្ខំ ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៧ E/១៩៩៨/២២ កថាខណ្ឌទី១។

8 A/HRC/៤/១៨ ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៧

9 អ្នករាយការណ៍ពិសេសស្តីពីការមានលំនៅឋានសមរម្យ គោលការណ៍ណែនាំសម្រាប់ការអនុវត្តសិទ្ធិមានលំនៅឋានសមរម្យ A/HRC/៤៣/៤៣ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩។

10 គោលការណ៍ណែនាំទី១១-១៣។

ក៏មានគោលការណ៍ណែនាំជាក់លាក់ ស្តីពីសិទ្ធិមានលំនៅឋានសម្រាប់ជនជាតិដើមភាគតិច នៅក្នុងរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមានលំនៅឋានសមរម្យឆ្នាំ២០១៩ ដែលត្រូវបានដាក់ជូនមហាសន្និបាតផងដែរ។[11] ក្រៅពីការបញ្ជាក់ជាថ្មីថា សិទ្ធិមានលំនៅឋានសមរម្យត្រូវតែបានធានាចំពោះជនជាតិដើមភាគតិច និងបុគ្គលទាំងឡាយដោយគ្មានការរើសអើងនោះ គោលការណ៍ណែនាំនេះក៏បានសង្កត់ធ្ងន់លើភាពចាំបាច់សម្រាប់គោលការណ៍ការយល់ព្រមដោយសេរី និងដោយបានប្រាប់ឱ្យដឹងជាមុន និងភាពសមស្របផ្នែកវប្បធម៌នៅកន្លែងតាំងទីលំនៅថ្មី។ ដោយសារតែលំនៅឋានជាធាតុផ្សំនៃសិទ្ធិទទួលបានស្តង់ដាររស់នៅសមរម្យ នៅឆ្នាំ២០២០ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិទទួលបានលំនៅដ្ឋានបានជំរុញឱ្យរដ្ឋនានាដាក់ការផ្អាកលើការបណ្តេញចេញទាំងអស់ក្នុងអំឡុងពេលនៃជំងឺរាតត្បាត។[12]

អង្គការសហប្រជាជាតិបានអនុម័តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) ទី១១ ដែលគ្របដណ្តប់លើសិទ្ធិមានលំនៅឋានសមរម្យ។ ចំណុចដៅ ១១.១ សូចនាករ ១១.១.១ គឺ "ធានាការទទួលបានសម្រាប់ទាំងអស់គ្នា នូវលំនៅឋានសមរម្យ មានសុវត្ថិភាព និង អាចផ្គត់ផ្គង់បាន និង សេវាមូលដ្ឋាន និង ធ្វើឱ្យប្រសើរឡើងនូវសំណង់អាណាធិបតេយ្យ"។

សម្រាប់គោលបំណងនៃការសិក្សានេះ ប្រភពនានាដែលបានរៀបរាប់ខាងលើ ផ្តល់នូវវិធីសាស្ត្រ និងមូលដ្ឋានច្បាប់ ដែលការសិក្សាបច្ចុប្បន្នក៏បានផ្អែកលើ បទដ្ឋាននៃលិខិតូបករណ៍អន្តរជាតិដទៃទៀត (ឧ. ស្តីពីសិទ្ធិស្ត្រី សិទ្ធិកុមារ សិទ្ធិទទួលបានសុខភាព និង ការអប់រំ សិទ្ធិទទួលបានស្បៀងអាហារ សិទ្ធិទទួលបានទឹកស្អាត និង អនាម័យ សិទ្ធិរបស់ជនជាតិដើមភាគតិច និង សិទ្ធិទទួលបានបរិស្ថានស្អាត ក្នុងចំណោមសិទ្ធិដទៃទៀត) ដែលអនុវត្តចំពោះស្ថានភាពនានាដែលពាក់ព័ន្ធនឹងការបណ្តេញចេញ និង ការតាំងទីលំនៅថ្មីផងដែរ។

## ធុរកិច្ច និងសិទ្ធិមនុស្ស

កាតព្វកិច្ចក្រោមសន្ធិសញ្ញាអន្តរជាតិរបស់រដ្ឋាភិបាលទាំងឡាយ ក្នុងការការពារ ប្រឆាំង នឹងការរំលោភបំពានសិទ្ធិមនុស្សដោយភាគីទីបី ស្ថិតនៅក្នុងវង្វង់ដែនដី និង/ឬដែនសមត្ថកិច្ចរបស់ខ្លួន រួមទាំងសហគ្រាសពាណិជ្ជកម្មជីវកម្មផងដែរ។ គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស គឺជាស្តង់ដារសកលសម្រាប់កាការពារ និងដោះស្រាយហានិភ័យនៃផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្ស ដែលភ្ជាប់ទៅនឹងសកម្មភាពធុរកិច្ច ហើយពួកគេផ្តល់នូវក្របខ័ណ្ឌដែលទទួលស្គាល់ជាអន្តរជាតិសម្រាប់ការលើកកម្ពស់ស្តង់ដារ និងការអនុវត្តទាក់ទងនឹងធុរកិច្ច និងមនុស្ស។ គោលការណ៍ណែនាំទាំងនេះមានមូលដ្ឋានលើការទទួលស្គាល់ថា៖ (ក) កាតព្វកិច្ចដែលមានស្រាប់របស់រដ្ឋក្នុងការគោរព ការពារ និងអនុវត្តសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននានា។ (ខ) សហគ្រាសពាណិជ្ជកម្ម ដែលមានតួនាទីជាអង្គភាពឯកទេសក្នុងសង្គម ដែលបំពេញមុខងារឯកទេស តម្រូវឱ្យអនុវត្តស្របតាមច្បាប់ជាធរមាន និងគោរពសិទ្ធិមនុស្ស។ (គ) តម្រូវការសម្រាប់សិទ្ធិ និងកាតព្វកិច្ចដែលមានព្រមគ្នាជាមួយនឹងការដំណោះស្រាយដ៏សមស្រប និងមានប្រសិទ្ធភាព នៅពេលមានការរំលោភបំពាន។[13]

## ការបណ្តេញចេញ និង ការតាំងទីលំនៅថ្មីស្របតាមច្បាប់ជាតិនៃប្រទេសកម្ពុជា

ប្រទេសកម្ពុជាគឺជាភាគីមួយនៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ (ICCPR)។ រដ្ឋធម្មនុញ្ញកម្ពុជា ប្រមើលមើលការរួមបញ្ចូលដោយផ្ទាល់នូវសន្ធិសញ្ញាស្តីពីសិទ្ធិមនុស្សអន្តរជាតិ និងអនុសញ្ញាដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន ដូច្នេះស្របតាម មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា សិទ្ធិមានលំនៅឋានត្រូវបានបញ្ចូលជាសិទ្ធិមនុស្សជាមូលដ្ឋានរបស់ប្រជាពលរដ្ឋកម្ពុជា។ សិទ្ធិកុមារ និង សិទ្ធិស្ត្រី សិទ្ធិទទួលបានការអប់រំ និង សុខភាព និង តម្រូវការនៃវិធានការសង្គមកិច្ចដើម្បីលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា ក៏ត្រូវបានបញ្ចូលក្នុងរដ្ឋធម្មនុញ្ញកម្ពុជាផងដែរ។ កាតព្វកិច្ចទាំងនេះមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងដំណើរការតាំងទីលំនៅថ្មី។

ច្បាប់ជាតិនៃប្រទេសកម្ពុជា មិនត្រឹមតែទទួលស្គាល់សិទ្ធិមានលំនៅឋានសមរម្យប៉ុណ្ណោះទេ ថែមទាំងផ្តល់ការការពារចំពោះសិទ្ធិនេះផងដែរ។

បន្ថែមពីលើការធានាដោយរដ្ឋធម្មនុញ្ញចំពោះសិទ្ធិមានលំនៅឋាន ច្បាប់ភូមិបាលឆ្នាំ២០០១ ទទួលស្គាល់សិទ្ធិកាន់កាប់អចលនទ្រព្យផ្ទាល់ខ្លួនផងដែរ។ ការដកហូតដីធ្លី/ទ្រព្យសម្បត្តិ អាចកើតឡើងបានតែដើម្បីផលប្រយោជន៍សាធារណៈតែប៉ុណ្ណោះ ហើយការផ្តល់សំណងយ៉ាងសមរម្យ និងយុត្តិធម៌ត្រូវតែទូទាត់ជូនជាមុន។[14] ច្បាប់ភូមិបាលក៏បានពណ៌នាអំពីរបៀបដែលបុគ្គលទាំងឡាយអាចទទួលបានសិទ្ធិភោគៈតាមសន្តិវិធីដែលសិទ្ធិនេះត្រូវបានការពាររហូតដល់ពេលដែលប័ណ្ណកម្មសិទ្ធិស្របច្បាប់ត្រូវបានប្រគល់ជូន។ បញ្ញត្តិទាំងនេះគប្បីការពារការកាន់កាប់ដីរបស់ភោគី និង ទប់ស្កាត់

---

11 A/៧៤/១៨៣ ឆ្នាំ២០១៩។

12 OHCHR, "ការហាមឃាត់ការបណ្តេញចេញក្នុងអំឡុងពេលនៃជំងឺរាតត្បាតកូវីដ១៩, អ្នកជំនាញអង្គការសហប្រជាជាតិជំរុញទៅដល់រដ្ឋនានាកាលពី" ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២០ ដែលមាននៅគេហទំព័រ https://www.ohchr.org/en/NewsEvents/Pages/DisplayNews.aspx?NewsID=26170&LangID=E.

13 គោលការណ៍ណែនាំនេះមិនបង្កើតជាឧបករណ៍អន្តរជាតិដែលនឹងអាចផ្តល់សច្ចាប័នដោយរដ្ឋទេ ហើយក៏មិនបង្កើតកាតព្វកិច្ចផ្លូវច្បាប់ថ្មីដែរ។ ផ្ទុយទៅវិញ គោលការណ៍ណែនាំនេះពន្យល់លម្អិតអំពីផលប៉ះពាល់នៃបទប្បញ្ញត្តិពាក់ព័ន្ធនៃស្តង់ដារសិទ្ធិមនុស្សអន្តរជាតិដែលមានស្រាប់ ដែលផ្នែកខ្លះមានកាតព្វកិច្ចស្របច្បាប់សំរាប់រដ្ឋ និងផ្នែកខ្លះទៀតផ្តល់ការណែនាំអំពីរបៀបដាក់ឱ្យដំណើរការ។ គោលការណ៍ណែនាំស្តីអំពីធុរកិច្ច និងសិទ្ធិមនុស្ស អាចរកបានតាមរយៈគេហទំព័រ https://www.ohchr.org/Documents/Publications/GuidingPrinciplesBusinessHR_EN.pdf.

14 ស្របតាមអនុក្រឹត្យលេខ ១២៩ ស្តីពីវិធាន និង នីតិវិធីនៃការធ្វើចំណាត់ថ្នាក់ឡើងវិញលើកម្មសិទ្ធិសាធារណៈរបស់រដ្ឋ និង នីតិបុគ្គលសាធារណៈ (ឆ្នាំ២០០៦) ដែលកំណត់គោលការណ៍ យុទ្ធសាស្ត្រ និង នីតិវិធីច្បាប់ សម្រាប់ការគ្រប់គ្រង និង ការដំណើរការទ្រព្យសម្បត្តិរដ្ឋ អាជ្ញាធរដែលទទួលខុសត្រូវលើការអង្កេត និង ការរាយការណ៍ជាសាធារណៈអំពីលក្ខខណ្ឌដែលជាផលប្រយោជន៍សាធារណៈនៃទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ គឺអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

ការបណ្តេញចេញរហូតទាល់តែភាពស្របច្បាប់នៃភោគៈនេះត្រូវបានកំណត់ដរាបណាតាមការកាន់កាប់ដោយសន្តិវិធី។ច្បាប់អស្សាមិករណ៍ឆ្នាំ២០១០ បញ្ជាក់ឡើងវិញអំពីគោលការណ៍ដែលត្រូវទូទាត់ប្រាក់សំណងយ៉ាងសមរម្យ និង ត្រឹមត្រូវជាមុន តាមតម្លៃទីផ្សារ ឬ តម្លៃជំនួសទៅឱ្យកម្មសិទ្ធិករ/ភោគី។ យោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ មានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ។

RGC ក៏បាននិងកំពុងតែប្រើប្រាស់អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (ឆ្នាំ២០០៣) ដើម្បីតាំងទីលំនៅថ្មីដល់សហគមន៍ក្រីក្រគ្មានផ្ទះសម្បែង ដែលបានទទួលរងផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ គ្រោះធម្មជាតិ ឬ ជាសហគមន៍អតីតយុទ្ធជន និង អតីតយុទ្ធជនពិការ និង គ្រួសាររបស់ពួកគេ។

កាលពីខែឧសភា ឆ្នាំ២០១០ សារាចរស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីធ្លី (ហៅថា សារាចរលេខ ០៣) ត្រូវបានបង្កើតឡើង ដើម្បីដោះស្រាយវិវាទដែលទាក់ទងនឹងការផ្លាស់ប្តូរទីលំនៅរបស់សហគមន៍នៅក្នុងទីក្រុង។ សារាចរនេះបានផ្តល់នូវដំណោះស្រាយដើម្បីគាំទ្រដល់ការអភិវឌ្ឍនៃការតាំងទីលំនៅក្រីក្រនៅក្នុងទីក្រុង ដែលត្រូវបានចាត់ទុកថាមិនស្របច្បាប់ ហើយស្របពេលដែលសារាចរបានបង្កើតបទដ្ឋានអប្បបរមាសម្រាប់កន្លែងតាំងទីលំនៅថ្មី មិនបានបញ្ចូលកិច្ចការពារតាមផ្លូវច្បាប់គ្រប់គ្រាន់សំរាប់ការផ្លាស់ទីលំនៅនោះទេ។ លើសពីនេះទៀត ក្នុងនាមសារាចរមួយ ពុំមានឥទ្ធិពលដូចច្បាប់នោះទេ។

នៅថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១៤ RGC បានចេញគោលនយោបាយជាតិស្តីពីលំនៅឋាន ដែលបានទទួលស្គាល់យ៉ាងច្បាស់លាស់អំពីសិទ្ធិមានលំនៅឋានសមរម្យ។ គោលនយោបាយនេះបានបង្កើតយុទ្ធសាស្ត្រ និង ផែនការសកម្មភាព ដែលលើកឡើងនូវគោលការណ៍សិទ្ធិមនុស្ស និង ភាពថ្លៃថ្នូរ និង កត់សម្គាល់ថា ការផ្លាស់ប្តូរទីលំនៅគួរតែជាជម្រើសចុងក្រោយ និង លើកទឹកចិត្តឱ្យមានការចូលរួមពីសហគមន៍មូលដ្ឋាន។ គោលនយោបាយស្តីពីលំនៅឋាន ក៏លើកទឹកចិត្តឱ្យមានការអនុវត្តសារាចរលេខ០៣ផងដែរ។ រាជរដ្ឋាភិបាលកម្ពុជាក៏ចេញគោលនយោបាយស្តីពីការលើកទឹកចិត្ត និង ការបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ(ឆ្នាំ២០១៧) ដើម្បីលំនៅឋានអាចរកបានសម្រាប់ក្រុមដែលមានប្រាក់ចំណូលទាប និង ក្រុមងាយរងគ្រោះ។ គោលនយោបាយនេះមានពីរដំណាក់កាលៈ ដំណាក់កាលទីមួយផ្តោតលើការលើកទឹកចិត្តផ្នែកសារពើពន្ធ ដូចជា ការបន្ធូរបន្ថយពន្ធ ដើម្បីលើកទឹកចិត្តការវិនិយោគលើលំនៅឋានដែលមានតម្លៃទាប ចំណែកដំណាក់កាលទីពីរ បង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានដែលមានតម្លៃសមរម្យ ដើម្បីធ្វើការរួមគ្នាជាមួយរបបប្រព័ន្ធសន្តិសុខសង្គម។

កាលពីខែកុម្ភៈ ឆ្នាំ២០១៨ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានចេញអនុក្រឹត្យប្រកាសឱ្យប្រើប្រាស់នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និង ការតាំងទីលំនៅឡើងវិញដោយស្ម័គ្រចិត្ត សម្រាប់គម្រោងដែលផ្តល់ហិរញ្ញប្បទានពីខាងក្រៅ នៅក្នុងប្រទេសកម្ពុជា។ អនុក្រឹត្យនេះកំណត់នីតិវិធីដែលត្រូវអនុវត្តតាមនៅពេលដែលគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលបានទទួលមូលនិធិពីម្ចាស់ជំនួយខាងក្រៅ (ដូចជាធនាគារ ពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និង ម្ចាស់ជំនួយដទៃទៀត) នឹងមានផលប៉ះពាល់ដល់សហគមន៍។ អនុក្រឹត្យនេះគូសបញ្ជាក់អំពីតួនាទី និង ទំនួលខុសត្រូវរបស់ទីភ្នាក់ងាររដ្ឋាភិបាលខុសៗគ្នា បង្ហាញជំហានដែលត្រូវអនុវត្តនៅពេលដែលការតាំងទីលំនៅថ្មីត្រូវបានចាត់ទុកថាចាំបាច់ និង បង្កើតនីតិវិធីបណ្តឹងតវ៉ាសម្រាប់សហគមន៍ ដែលមិនយល់ស្របទៅការតាំងទីលំនៅថ្មីដែលបានគ្រោងទុក។ អនុក្រឹត្យនេះមិនអនុវត្តចំពោះការតាំងទីលំនៅថ្មីដែលបណ្តាលមកពីគម្រោងអភិវឌ្ឍន៍ក្នុងស្រុកនោះទេ។ សិទ្ធិកុមារ និង សិទ្ធិស្ត្រី សិទ្ធិទទួលបានការអប់រំ និង សុខភាព និង តម្រូវការនៃវិធានការសង្គមកិច្ចដើម្បីលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជាក៏ត្រូវបានបញ្ចូលនៅក្នុងរដ្ឋធម្មនុញ្ញផងដែរ។ កាតព្វកិច្ចទាំងនេះមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងដំណើរការតាំងទីលំនៅថ្មី។


ផ្ទះខ្ទមសង់លើដីមួយកន្លែងដែលបានផ្តល់អោយនៅតំបន់តាំងទីលំនៅថ្មីអណ្តូងចាស់ នៅក្នុងភូមិអណ្តូង, សង្កាត់គោករកា, ខ័ណ្ឌព្រែកព្នៅ, រាជធានីភ្នំពេញ។ រូបថត ៖ CUFA

# ជំពូក

# ២

# ជីវិតនៅកន្លែងតាំងទីលំនៅថ្មី

# ជំពូក ២៖ ជីវិតនៅកន្លែងតាំងទីលំនៅថ្មី

## ២.១ មុននឹងធ្វើការបណ្តេញចេញ

### ២.១.១ ដំណើរការនៃការសម្រេចចិត្ត

ក្នុងអំឡុងពេលស្ទង់មតិ ពុំមានអ្នកឆ្លើយតបណាម្នាក់បានអះអាងថា ពួកគេ ឬ សមាជិកគ្រួសាររបស់ពួកគេបានចូលរួមនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ទេ។ អ្នកឆ្លើយតបមួយចំនួនបានកត់សម្គាល់យ៉ាងជាក់លាក់ថា ពួកគេមិនបានចូលរួមនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ណាមួយមុនពេលផ្លាស់ទីនោះទេ។ ការឆ្លើយតបទាំងនេះចង្អុលបង្ហាញថា ដំណើរការមុនពេលការតាំងទីលំនៅថ្មីមិនបានអនុលោមតាមបទដ្ឋានស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ ដោយសារការពិគ្រោះយោបល់ដ៏មានអត្ថន័យគឺជាធាតុដ៏សំខាន់មួយនៃដំណើរការតាំងទីលំនៅថ្មី។[15] ចំណុចនេះធ្វើឱ្យមានចម្ងល់ចំពោះភាពស្ម័គ្រចិត្តក្នុងការផ្លាស់ទីលំនៅ ហើយក៏បង្កើតការងឿងឆ្ងល់បន្ថែមទៀត ថាតើអ្នកឆ្លើយតបដែលបានអះអាងថា ការផ្លាស់ទីគឺជាការផ្លាស់ទីលំនៅដោយស្ម័គ្រចិត្តនោះ ពិតជាបានចូលរួមនៅក្នុងដំណើរការមុនពេលការតាំងទីលំនៅថ្មី ដែលស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដែរឬទេ។

សាមសិបភាគរយនៃគ្រួសារទាំងនេះបានអះអាងថា ការផ្លាស់ទីគឺជាការផ្លាស់ទីលំនៅដោយស្ម័គ្រចិត្ត។ ៦៣ ភាគរយនៃគ្រួសារទាំងនេះបានអះអាងថា ការផ្លាស់ទីគឺជាការបណ្តេញចេញដោយបង្ខំ។

មូលហេតុបីសំខាន់ៗដែលគ្រួសារទាំងឡាយជឿជាក់ថា ការផ្លាស់ទីត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្ត រួមមាន៖

- ពួកគេបានចូលរួមនៅក្នុងកិច្ចពិគ្រោះយោបល់ជាមួយមន្ត្រីរដ្ឋាភិបាល ឬ តំណាងក្រុមហ៊ុនដែលពាក់ព័ន្ធ មុនពេលការតាំងទីលំនៅថ្មី (៩២ ភាគរយ)
- ពួកគេបានទទួលព័ត៌មានដែលមានពាក់ព័ន្ធ និងគ្រប់គ្រាន់ អំពីការផ្លាស់ទីលំនៅមុនពេលការតាំងទីលំនៅថ្មី (៦១ ភាគរយ) និង
- ជម្រើសជំនួសឱ្យការផ្លាស់ទីលំនៅត្រូវបានពិចារណាយ៉ាងត្រឹមត្រូវ (៣០ ភាគរយ)។

គ្រួសារជនជាតិដើមភាគតិចបានបន្ថែមថា ទីតាំងវប្បធម៌នៃសហគមន៍របស់ពួកគេ ត្រូវបានយកមកពិចារណាក្នុងអំឡុងពេលនៃដំណើរការនេះ។ មូលហេតុបីសំខាន់ៗដែលគ្រួសារទាំងឡាយជឿជាក់ថា ការផ្លាស់ទីគឺជាការបណ្តេញចេញដោយបង្ខំ រួមមាន៖

- ពួកគេមិនចង់ផ្លាស់ទីលំនៅនោះទេ (៨១ ភាគរយ)
- ពួកគេមិនបានទទួលជម្រើសណាមួយផ្សេងទៀត ក្រៅពីការផ្លាស់ទីលំនៅនោះទេ (៧២ ភាគរយ)
- ពុំមានឱកាសក្នុងការពិគ្រោះយោបល់យ៉ាងពិតប្រាកដជាមួយភាគីពាក់ព័ន្ធ (៣៧ ភាគរយ)។

ហេតុផលផ្សេងទៀតដែលគ្រួសារជឿថាការផ្លាស់ទីលំនៅត្រូវបានបណ្តេញចេញដោយបង្ខំគឺ៖

- គ្រួសារត្រូវបានបង្ខិតបង្ខំឱ្យទទួលយកអត្ថប្រយោជន៍បន្ថែម ដើម្បីយល់ព្រមផ្លាស់ប្តូរទីលំនៅ (24 ភាគរយ)
- អាជ្ញាធរមូលដ្ឋាន ឬក្រុមហ៊ុនបានប្រើការគំរាមកំហែង អំពើហិង្សា និងវិធានការផ្សេងទៀតដើម្បី បណ្តេញគ្រួសារចេញ (24 ភាគរយ)
- គ្រួសារត្រូវបានបណ្តេញចេញ ជាមួយនឹងការប្រើកម្លាំងលើរូបរាងកាយ នៅថ្ងៃបណ្តេញចេញ(15 ភាគរយ)។

រូបភាពទី២ខាងក្រោម បង្ហាញអំពីភាគរយនៃគ្រួសារដែលបានអះអាងថាការផ្លាស់ទី គឺជាការផ្លាស់ទីលំនៅដោយស្ម័គ្រចិត្ត និង គ្រួសារដែលបានអះអាងថា ការផ្លាស់ទី គឺជាការបណ្តេញចេញដោយបង្ខំ។ ហុកសិបប្រាំបួនភាគរយនៃអ្នកឆ្លើយតបសរុបបានអះអាងថា គ្រួសាររបស់ពួកគេបានចូលរួមនៅក្នុងកិច្ចប្រជុំផ្តល់ព័ត៌មានជាមួយភាគីពាក់ព័ន្ធ រួមទាំង មន្ត្រីរដ្ឋាភិបាលផងដែរ មុនពេលការតាំងទីលំនៅថ្មី។ នៅខណៈពេលដែលប្រជាជនទទួលបានការជូនដំណឹងអំពីអ្វីដែលនឹងកើតឡើងនោះ ជិតមួយភាគបី (៣០ ភាគរយនៃគ្រួសារពុំមានឱកាសចូលរួមនៅក្នុងដំណើរការផ្តល់ព័ត៌មានមុនពេលការតាំងទីលំនៅថ្មី។ ទោះបីជាគ្រួសារដែលបានចូលរួមនៅក្នុងកិច្ចប្រជុំផ្តល់ព័ត៌មានមិនមានឥទ្ធិពលលើគ្រួសារទាំងឡាយនៅក្នុងការកំណត់ថាតើការផ្លាស់ទី ជាការផ្លាស់ទីលំនៅដោយស្ម័គ្រចិត្ត ឬ អត់ក្តី ក៏វាជាប្រភេទនៃកិច្ចប្រជុំដែលមានឥទ្ធិពលលើគ្រួសារទាំងឡាយដែរ។ លក្ខណៈនៃកិច្ចប្រជុំផ្តល់ព័ត៌មានដែលមានឥទ្ធិពលបែបនោះ គឺជាកិច្ចប្រជុំដែល៖

15 OHCHR (បោះពុម្ពឡើងវិញ ឆ្នាំ២០១៣). គោលការណ៍ជាមូលដ្ឋាន និង គោលការណ៍ណែនាំស្តីពីការបណ្តេញចេញ និង ការចាកចេញដោយបង្ខំចិត្ត ផ្អែកលើការអភិវឌ្ឍ ដែលមាននៅក្នុងសេចក្តីអត្ថាធិប្បាយរបស់អង្គការសហប្រជាជាតិ និង គោលការណ៍ណែនាំស្តីពីការបណ្តេញចេញ និង ការតាំងទីលំនៅថ្មី ភ្នំពេញ OHCHR កថាខណ្ឌទី៣៧ ទំព័រទី៣៣ https://cambodia.ohchr.org/sites/default/files/Softlaw/UN percent20Commentary-A5-En_0.pdf បានចូលប្រើប្រាស់នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០។ គេគប្បីកត់សម្គាល់ផងដែរថា តម្រូវការនៃការប្រឹក្សាយោបល់ជាសាធារណៈត្រូវបានរួមបញ្ចូលនៅក្នុងក្របខណ្ឌច្បាប់កម្ពុជា ចូរមើល អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច ឆ្នាំ២០០៥, អនុក្រឹត្យស្តីពីការប្រកាសឱ្យប្រើប្រាស់នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និង ការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត សម្រាប់គម្រោងដែលទទួលបានហិរញ្ញប្បទានពីខាងក្រៅ នៅក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៨ និង ច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦។

- បានពន្យល់អំពីមូលហេតុនៃការផ្លាស់ទីលំនៅ
- បានជូនដំណឹងដល់ពួកគេអំពីពេលវេលា និង កាលបរិច្ឆេទនៃការផ្លាស់ទីលំនៅ
- បានជូនដំណឹងដល់ពួកគេអំពីកន្លែងតាំងទីលំនៅថ្មី និង ស្ថានភាពរស់នៅ នៅកន្លែងតាំងទីលំនៅថ្មី
- បានកើតឡើងនៅពេលដែលតំណាងរបស់រដ្ឋាភិបាលបានចុះទៅជួបគ្រួសារទាំងឡាយ និង
- បានផ្តល់ពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើផែនការ និង ត្រៀមខ្លួនសម្រាប់ការផ្លាស់ទីលំនៅ។

គ្រួសារជនជាតិដើមភាគតិចទទួលរងឥទ្ធិពលស្រដៀងគ្នា ដោយកត្តាទាំងនេះបានកំណត់ថាតើការផ្លាស់ទី គឺជាការផ្លាស់ទីលំនៅដោយស្ម័គ្រចិត្ត ឬ ជាការបណ្តេញចេញដោយបង្ខំ។

**រូបភាពទី២៖ ការផ្លាស់ទីលំនៅដោយស្ម័គ្រចិត្ត ឬ ការបណ្តេញចេញដោយបង្ខំ (ភាគរយរបស់គ្រួសារ)**



អ្នកឆ្លើយតបភាគច្រើនបានអះអាងថា ទាំងបុរស និង ស្ត្រីមានវត្តមាននៅក្នុងកិច្ចប្រជុំផ្តល់ព័ត៌មាន ហើយកម្រិតតុល្យភាពយេនឌ័រនៃការចូលរួមកិច្ចប្រជុំនេះមិនបានជះឥទ្ធិពលលើគ្រួសារទាំងឡាយនៅក្នុងការកំណត់ថាតើការផ្លាស់ទី គឺជាការផ្លាស់ទីលំនៅដោយស្ម័គ្រចិត្ត ឬជាការបណ្តេញចេញដោយបង្ខំនោះទេ។ ចំនួន និង រយៈពេលនៃកិច្ចប្រជុំផ្តល់ព័ត៌មានក៏មិនបានជះឥទ្ធិពលលើគ្រួសារទាំងឡាយនៅក្នុងការកំណត់ថាតើការផ្លាស់ទី គឺជាការផ្លាស់ទីលំនៅដោយស្ម័គ្រចិត្ត ឬ ជាការបណ្តេញចេញដោយបង្ខំនោះដែរ។

នៅតាមទីតាំងភាគច្រើន អាជ្ញាធរមូលដ្ឋានបានកត់សម្គាល់ថា នៅក្នុងការសម្រេចចិត្ត ពួកគេមិនបាននិយាយថាតើកន្លែងតាំងទីលំនៅថ្មីនឹងស្ថិតនៅទីណានោះទេ។ អាជ្ញាធរមូលដ្ឋាន និង អ្នកដឹកនាំបានអះអាងថា ស្ថាប័នដែលធ្វើការសម្រេចចិត្ត គឺជាស្ថាប័នកម្រិតខ្ពស់ ចាប់ពីអាជ្ញាធរស្រុក និង អាជ្ញាធរខេត្ត រហូតដល់ គណៈកម្មាធិការអន្តរក្រសួង ក្រសួងកងនាវាកម្ពុជា និង ក្នុងករណីមួយចំនួន ជាក្រុមហ៊ុនដែលសម្បទាន ឬ គម្រោងអភិវឌ្ឍន៍របស់ពួកគេបានបង្ករឱ្យមានការផ្លាស់ទីលំនៅ។ អាជ្ញាធរមូលដ្ឋានមួយចំនួនបាននិយាយថា ពួកគេបានចូលរួមកិច្ចប្រជុំដើម្បីពិភាក្សាអំពីការតាំងទីលំនៅថ្មីនេះ ប៉ុន្តែពួកគេមានអារម្មណ៍ថា ពួកគេគ្មានអំណាច ឬ គ្មានសិទ្ធិក្នុងការសម្រេចចិត្តណាមួយឡើយ។ អាជ្ញាធរមូលដ្ឋាន និង អ្នកដឹកនាំដែលមកពីក្បាលរមាសថ្មី និង ស្រែស្រណុកថ្មី នៅក្នុងខេត្តស្ទឹងត្រែង ជាកន្លែងដែលគ្រួសារជនជាតិដើមភាគតិចតាំងទីលំនៅនោះ សហគមន៍បានជ្រើសរើសកន្លែងតាំងទីលំនៅថ្មី បន្ទាប់ពីកន្លែងដែលត្រូវបានផ្តល់ជូនត្រូវបានជំទាស់ ហើយប្រជាជនបដិសេធមិនព្រមផ្លាស់ទីលំនៅ ហើយអាជ្ញាធរមូលដ្ឋានបានត្រឹមតែជូនដំណឹងដល់អាជ្ញាធរជាន់ខ្ពស់អំពីការសម្រេចចិត្តរបស់សហគមន៍តែប៉ុណ្ណោះ។

### ២.១.២ សេចក្តីជូនដំណឹងអំពីការបណ្តេញចេញ

ប៉ែតសិបបីភាគរយនៃគ្រួសារត្រូវបានទទួលការជូនដំណឹងអំពីការផ្លាស់ទីលំនៅតាមរយៈកិច្ចប្រជុំជាមួយគ្រួសារ ឬ សហគមន៍ដែលរងផលប៉ះពាល់មុនពេលការតាំងទីលំនៅថ្មី។ ៩១,៩ ភាគរយនៃគ្រួសារដែលបានចូលរួមកិច្ចប្រជុំទាំងនេះបានកត់សម្គាល់ថា ទាំងបុរស ទាំងស្ត្រីសុទ្ធតែមានវត្តមាននៅក្នុងកិច្ចប្រជុំទាំងនេះ។ ទោះបីជាគ្រួសារដែលអាចអានព័ត៌មានជាលាយលក្ខណ៍អក្សរស្តីពីការផ្លាស់ទីលំនៅបានជះឥទ្ធិពលលើគ្រួសារទាំងឡាយនៅក្នុងការកំណត់ថាតើការផ្លាស់ទី គឺជាការផ្លាស់ទីលំនៅដោយស្ម័គ្រចិត្ត ឬជាការបណ្តេញចេញដោយបង្ខំក្តី គ្រួសារជនជាតិដើមភាគតិចទាំងអស់បានទទួលការជូនដំណឹងអំពីការផ្លាស់ទីលំនៅតាមរយៈកិច្ចប្រជុំនានា មុនពេលការតាំងទីលំនៅថ្មី។ ពុំមានគ្រួសារជនជាតិដើមភាគតិចណាមួយបានអះអាងថា អាជ្ញាធរមូលដ្ឋានបានប្រើកម្លាំងបាយដើម្បីបណ្តេញពួកគេចេញនោះទេ។

## ២.២ លក្ខខណ្ឌតម្រូវសម្រាប់កន្លែងតាំងទីលំនៅថ្មី

លក្ខខណ្ឌនៅកន្លែងតាំងទីលំនៅថ្មី បន្ទាប់ពីគ្រួសារដែលរងផលប៉ះពាល់បានមកដល់ មិនបានបំពេញតាមលក្ខណវិនិច្ឆ័យ និងគោលការណ៍ណែនាំសម្រាប់កន្លែងតាំងទីលំនៅថ្មីឱ្យបានត្រឹមត្រូវនោះទេ។ កង្វះខាតលំនៅឋាន នៅកន្លែងតាំងទីលំនៅថ្មីមួយចំនួនដែលត្រូវបានសម្គាល់ឃើញដោយអ្នកឆ្លើយតបចំនួន ១០ ភាគរយ ពុំស្របទៅនឹងសិទ្ធិមានលំនៅឋានសមរម្យ ដែលតម្រូវថាលំនៅឋានជំនួសគប្បីត្រូវបានផ្តល់ជូនមុនពេលការទៅតាំងទីលំនៅថ្មី ហើយអ្នកដែលត្រូវបានផ្លាស់ទីលំនៅ គប្បីទទួលបានទីជម្រក និង លំនៅឋានមូលដ្ឋាន។

សម្ភារៈចាំបាច់កម្រិតមូលដ្ឋាននៅកន្លែងតាំងទីលំនៅថ្មី មិនបានរៀបចំរួចជាស្រេចនៅកន្លែងតាំង ទីលំនៅថ្មី នៅពេលដែលពួកគេបានទៅដល់ ដូចបានចង្អុលបង្ហាញដោយអ្នកឆ្លើយតប ពាក់ព័ន្ធនឹងសន្តិសុខស្បៀង (គ្មានផ្សារ [១៨ ភាគរយ] គ្មានស្បៀងអាហារ [៨ ភាគរយ] អាហារតម្លៃថ្លៃ [៨ ភាគរយ] ការពិបាកក្នុងការនេសាទសម្រាប់គ្រួសារជនជាតិដើមភាគតិច [១ ភាគរយ]) កង្វះខាតប្រភពទឹក (៤៥ ភាគរយ) កង្វះខាតទឹកស្អាតសម្រាប់បរិភោគ (៣៧ ភាគរយ) និង កង្វះខាតអគ្គិសនី (៣៣ ភាគរយ)។

រាល់លក្ខខណ្ឌទាំងអស់ខាងលើ មិនសមស្របទៅនឹងគោលការណ៍ជាមូលដ្ឋាន និង គោលការណ៍ណែនាំស្តីពីការបណ្តេញចេញ និង ការតាំងទីលំនៅថ្មី ផ្អែកលើការអភិវឌ្ឍ ដែលកំណត់ថា អាជ្ញាធរមាន សមត្ថកិច្ចគប្បីធានាថា បុគ្គល ឬ ក្រុមដែលត្រូវបានបណ្តេញចេញ មានសិទ្ធិទទួលបានសេវាសំខាន់ៗនៅកន្លែងតាំងទីលំនៅថ្មីប្រកបដោយសុវត្ថិភាព និងសន្តិសុខ និង ថាតើកន្លែងទាំងនោះគប្បីត្រូវបានរៀបចំរួចរាល់មុនពេលផ្លាស់ទីលំនៅ។

កន្លែងតាំងទីលំនៅថ្មីចាំបាច់ត្រូវតែផ្តល់លទ្ធភាពទទួលបានជម្រើសការងារ និង ប្រភពចិញ្ចឹមជីវិត។ អ្នកឆ្លើយតបចំនួន ៨ ភាគរយ បាននិយាយថា ទីតាំងទាំងនោះស្ថិតនៅឆ្ងាយពីកន្លែងធ្វើការ ឬ ទីតាំងប្រកបអាជីវកម្មរបស់ពួកគេ។ ២៧ ភាគរយ បាននិយាយថា ពុំមានការងារ ឬ អាជីវកម្មនៅកន្លែងតាំងទីលំនៅថ្មី ខណៈពេលដែល ៦ ភាគរយ បានរាយការណ៍ថា ពួកគេបានបាត់បង់ការងារ/អាជីវកម្មរបស់ពួកគេដោយសារការតាំងទីលំនៅថ្មីនោះ។

អាជ្ញាធរមូលដ្ឋាន និង អ្នកដឹកនាំសហគមន៍មួយចំនួនបានទទួលស្គាល់បញ្ហាប្រឈមដោយគ្រួសារដែលបានតាំងទីលំនៅថ្មី បន្ទាប់ពីពួកគេបានមកដល់កន្លែងតាំងទីលំនៅថ្មី។ អាជ្ញាធរមូលដ្ឋាន និង អ្នកដឹកនាំសហគមន៍នៅស្រះពោធិ៍ (ខេត្តកណ្តាល) ព្រៃកកូនសេក (ខេត្តបាត់ដំបង) និង ព្រៃកស្វាច់ (ខេត្តកោះកុង) បាននិយាយថា មានការពិបាកក្នុងការស្វែងរកមុខរបរចិញ្ចឹមជីវិត និង ឱកាសការងារ។ អាជ្ញាធរមូលដ្ឋាននៅព្រែកស្វាច់ (ខេត្តកោះកុង) ក៏មានកង្វល់អំពីកង្វះខាតផ្លូវថ្នល់ និង កង្វះខាតទឹកផងដែរ។ មេភូមិនៅស្រែស្រណុកថ្មី (ខេត្តស្ទឹងត្រែង) បាននិយាយថា គ្រួសារដែលបានតាំងទីលំនៅថ្មីមានការមិនពេញចិត្ត ពីព្រោះតំបន់នោះគ្មានដើមឈើ និងខ្វះទឹកប្រើប្រាស់។ ប្រធានសហគមន៍មួយនៅអូរកម្ពុជា (ខេត្តព្រះសីហនុ) បាននិយាយថា គ្រួសារទាំងឡាយមិនសប្បាយចិត្ត ដោយសារដីមិនទាន់បានឈូសឆាយនៅឡើយ មុនពេលដែលពួកគេមកដល់។

## ២.៣ បន្ទាប់ពីការបណ្តេញចេញ

### ២.៣.១ សំណង

ការវិភាគខាងក្រោមចង្អុលបង្ហាញអំពីចំនួនប្រាក់សំណងដែលត្រូវបានផ្តល់ជូន ប៉ុន្តែមិនបានបង្ហាញថាតើសំណងទាំងនោះត្រូវបានវាយតម្លៃយ៉ាងត្រឹមត្រូវ និងគ្រប់គ្រាន់ និង សមស្រប តាមបទដ្ឋានស្តង់ដារសិទ្ធិមនុស្សអន្តរជាតិដែរឬទេ។

សំណងជាទឹកប្រាក់ និង មិនមែនជាទឹកប្រាក់ចំនួនប្រាំពីរប្រភេទ ត្រូវបានផ្តល់ជូនគ្រួសាររួមមាន៖ ដីលំនៅឋាន ជំនួយហិរញ្ញវត្ថុ ដីកសិកម្ម លំនៅឋាន ស្បៀងអាហារ ថ្លៃដឹកជញ្ជូនទ្រព្យសម្បត្តិដែលត្រូវផ្លាស់ទី និង សម្ភារៈប្រើប្រាស់នៅក្នុងផ្ទះ។

រូបភាពទី៣៖ ប្រភេទសំណង




អ្នកឆ្លើយតបនីមួយៗបានផ្តល់ចម្លើយមួយ ឬ ច្រើន ចំពោះប្រភេទសំណងដែលពួកគេបានទទួល។ រូបភាពទី៣ រៀបរាប់អំពីសំណងទាំងប្រាំពីរប្រភេទ និង ភាគរយនៃគ្រួសារដែលបានទទួលសំណង៖ ដីលំនៅឋាន (៨០ ភាគរយ) ជំនួយហិរញ្ញវត្ថុ (៦៦ ភាគរយ) ដីកសិកម្ម (៥១ ភាគរយ) លំនៅឋាន (៤១ ភាគរយ) ស្បៀងអាហារ (១៨ ភាគរយ) ថ្លៃដឹកជញ្ជូនទ្រព្យសម្បត្តិដែលត្រូវផ្លាស់ទី (១៣ ភាគរយ) និង សម្ភារៈប្រើប្រាស់ក្នុងផ្ទះ (៩ ភាគរយ)។ ដីលំនៅឋានដែលត្រូវបានផ្តល់ជូនភាគច្រើនមានទំហំធំជាង ២៥០ម២ នៅ ខណៈពេលដែលដីកសិកម្មត្រូវបានផ្តល់ជូន ភាគច្រើនមានទំហំ ៤-៥ ហិកតា។ ចំនួនទឹកប្រាក់នៃជំនួយហិរញ្ញវត្ថុដែលត្រូវបានផ្តល់ជូន ភាគច្រើន (៦១ ភាគរយ) មានចំនួនលើសពី ១.០០១ ដុល្លារអាមេរិក។ ពុំមានអ្នកឆ្លើយតបណាម្នាក់ត្រូវទូទាត់ប្រាក់ដើម្បីអាចទទួលបានសំណងនោះទេ។

អាជ្ញាធរមូលដ្ឋាននៅអូរបាត់មាន់ (ខេត្តឧត្តរមានជ័យ) និង ពីស (ខេត្តកំពង់ស្ពឺ) បាននិយាយថា គ្រួសារដែលបានតាំងទីលំនៅថ្មីមួយចំនួនមានអារម្មណ៍ថា សំណង និង ដីធ្លីដែលត្រូវបានផ្តល់ជូនពួកគេ គឺមិនគ្រប់គ្រាន់។

គ្រួសារជនជាតិដើមភាគតិចទាំងអស់ ត្រូវបានផ្តល់សំណងសម្រាប់ការបាត់បង់ទីតាំងវប្បធម៌របស់ពួកគេ ជាមួយនិងដីធ្លី និង ជំនួយហិរញ្ញវត្ថុ។ ទោះយ៉ាងណាក៏ដោយ ១៤ភាគរយ យល់ថាសំណងមានភាពអយុត្តិធម៌ និងមិនសមរម្យ។ ៦៤ ភាគរយនៃគ្រួសារជនជាតិដើមភាគតិច បានចរចាកិច្ចព្រមព្រៀងចែករំលែកអត្ថប្រយោជន៍ជាមួយក្រុមហ៊ុនពាក់ព័ន្ធ ដែលបានចូលរួមនៅក្នុងការដំណើរការនៃការតាំងទីលំនៅថ្មី។

### ២.៣.២ ទិដ្ឋភាពទូទៅ៖ ទិដ្ឋភាពវិជ្ជមាន និង អវិជ្ជមាននៃការតាំងទីលំនៅថ្មី

គ្រួសារដែលបានតាំងទីលំនៅថ្មី ត្រូវបានស្នើសុំឱ្យកំណត់ទិដ្ឋភាពវិជ្ជមាន និង អវិជ្ជមាននៃការតាំងទីលំនៅថ្មីនេះ។ គ្រួសារស្ទើរតែទាំងអស់បានកំណត់ទាំងទិដ្ឋភាពវិជ្ជមាន និង អវិជ្ជមាននៃការតាំងទីលំនៅថ្មី។ គ្រួសារជាច្រើនបានមើលឃើញថា ការទទួលបានលំនៅឋានសមរម្យ និង សេវា

សុខាភិបាល និង ការអប់រំមានភាពល្អប្រសើរជាងមុន។ ស្របពេលជាមួយគ្នានោះ មានគ្រួសារជាងពាក់កណ្ដាលបានមើលឃើញថា ការទទួលបានទឹកប្រើប្រាស់មានភាពយ៉ាប់យ៉ឺនជាងមុន និង គ្រួសារខ្លះទៀតបានមើលឃើញថា ជីវភាពរស់នៅមានការចុះអន់ថយ។

## ទិដ្ឋភាពវិជ្ជមាន៖

គ្រួសារដែលរងផលប៉ះពាល់ភាគច្រើនបានកំណត់ទិដ្ឋភាពមួយ-ចំនួននៃស្ថានភាពរស់នៅរបស់ពួកគេនៅកន្លែងតាំងទីលំនៅថ្មី ដែលបំពេញតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិស្ដីពីការតាំងទីលំនៅថ្មី - ជាពិសេសចំពោះផ្នែកលំនៅឋាន ចម្ងាយពីសាលារៀនក្នុងមូលដ្ឋាន ការផ្គត់ផ្គង់ទឹក និង អនាម័យ។

ប្រហែល ៩៨,៨ ភាគរយនៃអ្នកឆ្លើយតបសរុប បានផ្ដល់ចម្លើយមួយ ឬ ច្រើន ថាតើគ្រួសាររបស់ពួកគេបានជួបប្រទះទិដ្ឋភាពវិជ្ជមាននៃស្ថានភាពរស់នៅជាទូទៅ នៅកន្លែងតាំងទីលំនៅថ្មីដែរឬទេ។ ១,២ ភាគរយមិនដឹងចម្លើយ។ រូបភាពទី៤ បង្ហាញ ៦៧,១ ភាគរយបានលើកឡើងអំពីលំនៅឋានសមរម្យ ថាជាទិដ្ឋភាពវិជ្ជមានមួយ ៣៨,៥% បានឆ្លើយថាមានចម្ងាយឆ្ងាយគួរសមពីសាលារៀនក្នុងមូលដ្ឋាន ៣៤,៤ ភាគរយបានអះអាងអំពីការទទួលបានសេវាថែទាំសុខភាព ២១,៦ ភាគរយបាននិយាយអំពីការផ្គត់ផ្គង់ទឹក និង ២០,៣ ភាគរយបានកត់សម្គាល់អំពីអនាម័យ។ លើសពីនេះទៀត ១៤,៧ ភាគរយបាននិយាយអំពីការទទួលបានស្បៀងអាហារសមរម្យ និង ១៣,៥ ភាគរយបានឆ្លើយតបថា មានកំណើនមុខរបរចិញ្ចឹមជីវិត និង ឱកាសការងារ។

### ប្រអប់ទី១៖ តើការតាំងទីលំនៅថ្មីមានផលប៉ះពាល់លើស្ត្រីខុសពីបុរសដែរឬទេ?

៩៩,៤% នៃអ្នកឆ្លើយតបសរុបបានអះអាងថា ពុំមានទិដ្ឋភាពណាមួយនៃស្ថានភាពរស់នៅលើកន្លែងតាំង ទីលំនៅថ្មីដែលមានផលជះលើស្ត្រីខុសពីបុរសនោះទេ។ ០,២% នៃអ្នកឆ្លើយតបសរុបបានអះអាងថា ពួកគេមិនដឹងនោះទេ។

០,២% ផ្សេងទៀត នៃអ្នកឆ្លើយតបដែលរស់នៅក្បាលរមាសថ្មី (ខេត្តស្ទឹងត្រែង) និង ទួលសំបូរ (ភ្នំពេញ) បានឆ្លើយតបថា ការទទួលបានស្បៀងអាហារសមរម្យ លំនៅឋានសមរម្យ និង ការផ្គត់ផ្គង់ទឹកដែលមានគុណភាពល្អ មានផលជះជាវិជ្ជមានលើស្ត្រីខុសពីបុរស។ អ្នកឆ្លើយតបដដែលនោះបានឆ្លើយថា ការទទួលបានស្បៀងអាហារមិនគ្រប់គ្រាន់ និង មុខរបរចិញ្ចឹមជីវិត និង ឱកាសការងារតិចជាង មានផលជះជាអវិជ្ជមានលើស្ត្រីខុសពីបុរស។

**រូបភាពទី៤៖ ទិដ្ឋភាពវិជ្ជមាននៃស្ថានភាពរស់នៅ នៅកន្លែងតាំងទីលំនៅថ្មី**



## ទិដ្ឋភាពអវិជ្ជមានៈ

មួយរយភាគរយនៃគ្រួសារទាំងឡាយបានពណ៌នាអំពីទិដ្ឋភាពអវិជ្ជមាននៃស្ថានភាពរស់នៅ នៅកន្លែងតាំងទីលំនៅថ្មី។ ៥៨ ភាគរយ នៃគ្រួសារទាំងឡាយបានកំណត់ថាកង្វះខាតឬការមានចំនួនកំណត់នៃទឹកពិសារដែលមានសុវត្ថិភាពគឺជាទិដ្ឋភាពអវិជ្ជមានជាចម្បង។៥០ភាគរយបានលើកឡើងអំពីការផ្គត់ផ្គង់ទឹកមិនបានល្អ ១៨ ភាគរយ និយាយថា ទំហំដីដែលបានផ្តល់ជូនពួកគេមានទំហំតូចពេក និង ១៨ ភាគរយផ្សេងទៀត បាននិយាយថាមានការថយចុះនៃមុខរបរចិញ្ចឹមជីវិត និង ឱកាសការងារ។ ទិដ្ឋភាពអវិជ្ជមានទាំងអស់នេះបានចង្អុលបង្ហាញអំពីកង្វះខាតការអនុលោមតាមគោលការណ៍ជាមូលដ្ឋាន និង គោលការណ៍ណែនាំស្តីពីការបណ្តេញចេញ និង ការចាកចេញដោយបង្ខំចិត្ត ផ្អែកលើការអភិវឌ្ឍ ដូចបានលើកឡើងនៅក្នុងផ្នែកមុន "ការមកដល់កន្លែងតាំងទីលំនៅថ្មី"។ រូបភាពទី៥ ខាងក្រោមផ្តល់បញ្ជីចម្លើយពេញលេញមួយ រួមជាមួយ ភាគរយសរុបដែលគ្របដណ្តប់លើទីតាំងទាំង ១៧។

**រូបភាពទី៥ៈ ទិដ្ឋភាពអវិជ្ជមាននៃស្ថានភាពរស់នៅ នៅកន្លែងតាំងទីលំនៅថ្មី**




## គ្រួសារជនជាតិដើមភាគតិចៈ

ជនជាតិដើមភាគតិច បានផ្តល់ចម្លើយមួយ ឬ ច្រើន អំពីថាតើពួកគេបានឆ្លងកាត់ទិដ្ឋភាពវិជ្ជមាននៃស្ថានភាពរស់នៅរបស់គ្រួសារពួកគេនៅកន្លែងតាំងទីលំនៅថ្មីដែរឬទេ។ ដូចដែល រូបភាពទី៦ បានបង្ហាញ ៧៨ ភាគរយ បានអះអាងថា លំនៅឋានសមរម្យ គឺជាទិដ្ឋភាពវិជ្ជមានមួយ ៥៤ ភាគរយបានលើកឡើងអំពីការទទួលបានសេវាថែទាំសុខភាព ៥៣ ភាគរយ បាននិយាយអំពីចម្ងាយពីសាលារៀនក្នុងមូលដ្ឋាន និង ២៣ ភាគរយបាននិយាយអំពីការទទួលបានស្បៀងអាហារសមរម្យ។

## រូបភាពទី៦៖ ទិដ្ឋភាពវិជ្ជមាននៃស្ថានភាពរស់នៅ នៅកន្លែងតាំងទីលំនៅថ្មីសម្រាប់ជនជាតិដើមភាគតិច




រូបភាពទី៧ ខាងក្រោមបានបង្ហាញ គ្រួសារជនជាតិដើមភាគតិចបានកំណត់ទិដ្ឋភាពអវិជ្ជមានចំនួន ១១ ចំណុច។ ទិដ្ឋភាពអវិជ្ជមានសំខាន់ៗ ជាប់ពាក់ព័ន្ធនឹងទឹក ៧៦ ភាគរយនៃគ្រួសារជនជាតិដើមភាគតិចបាននិយាយថា គ្មាន/ទឹកស្អាតសម្រាប់បរិភោគមានចំនួនកំណត់។ ហុកសិបមួយភាគរយបាននិយាយថា ការផ្គត់ផ្គង់ទឹកមានគុណភាពមិនល្អ នៅកន្លែងតាំងទីលំនៅថ្មី។ ភាគរយដែលខ្ពស់ជាងគេបំផុតបន្ទាប់ទៀតគឺ ការថយចុះនៃមុខរបរចិញ្ចឹមជីវិត/ឱកាសការងារ ចំនួន ២៥ ភាគរយ និង តម្លៃអាហារឡើងថ្លៃ ចំនួន ២០ ភាគរយ។

## រូបភាពទី៧៖ ទិដ្ឋភាពអវិជ្ជមាននៃស្ថានភាពរស់នៅ នៅកន្លែងតាំងទីលំនៅថ្មី សម្រាប់គ្រួសារជនជាតិដើមភាគតិច



### ២.៣.៣ សុវត្ថិភាពនៃការកាន់កាប់

បច្ចុប្បន្នពុំទាន់មានច្បាប់ ឬ អនុក្រឹត្យដែលចែងអំពីរយៈពេលសម្រាប់ប្រជាពលរដ្ឋក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិលើទ្រព្យសម្បត្តិនៅកន្លែងតាំងទីលំនៅថ្មីនោះទេ។ ផ្ទុយមកវិញ ពួកគេពឹងផ្អែកលើអ្វីដែលត្រូវបានប្រាប់ដោយអាជ្ញាធរ ដែលមានការប្រែប្រួលពីសប្តាហ៍រហូតដល់ដប់ឆ្នាំ។ ប្រជាពលរដ្ឋមួយចំនួនបានទទួលប័ណ្ណកម្មសិទ្ធិបន្ទាប់ពីបានរស់នៅក្នុងរយៈពេលខ្លី (៤ឆ្នាំ) នៅខណៈពេលដែលអ្នកខ្លះទៀត បានរស់នៅលើទីតាំងនោះអស់រយៈពេលដប់ឆ្នាំ ឬ លើសពីនោះ នៅតែមិនទាន់បានទទួលប័ណ្ណកម្មសិទ្ធិនៅឡើយ។ ក្នុងចំណោមគ្រួសារដែលបានរាយការណ៍ថា មិនទាន់ទទួលបានប័ណ្ណកម្មសិទ្ធិ៩៨ភាគរយបាននិយាយថា ពួកគេធ្លាប់បានទទួលព័ត៌មានថា ពួកគេនឹងទទួលបានប័ណ្ណកម្មសិទ្ធិក្នុងរយៈពេល ៥ឆ្នាំ ប៉ុន្តែប្រជាពលរដ្ឋភាគច្រើនមិនទាន់បានទទួលប័ណ្ណកម្មសិទ្ធិនៅឡើយទេ បន្ទាប់ពីពួកគេបានរស់នៅលើទីតាំងអស់រយៈពេល ៥ឆ្នាំ ឬ លើសពីនេះ។ វាពិតជាមានសារៈសំខាន់នៅក្នុងការកំណត់អំពីរយៈពេលច្បាស់លាស់មួយដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិ។

រូបភាពទី៨ បង្ហាញអំពីភាគរយនៃអ្នកដែលមានប័ណ្ណកម្មសិទ្ធិ គ្មានប័ណ្ណកម្មសិទ្ធិ និង អ្នកដែលមិនអាចនិយាយបានថាតើពួកគេមានប័ណ្ណកម្មសិទ្ធិដែរឬទេ។ គ្រួសារទាំងឡាយបានប្រើប្រាស់ទម្រង់ឯកសារផ្សេងៗ ដើម្បីបញ្ជាក់អំពីកម្មសិទ្ធិ ដោយមានគ្រួសារជាងពាក់កណ្តាលបាននិយាយថា ពួកគេមានឯកសារដែលចុះហត្ថលេខាដោយអាជ្ញាធរមូលដ្ឋានទទួលស្គាល់អំពីកម្មសិទ្ធិរបស់ពួកគេ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយឯកសារទាំងនេះមិនបានផ្តល់សុវត្ថិភាពនៃការកាន់កាប់នោះទេ និង ប្រហែលជាមិនត្រូវបានទទួលស្គាល់ដោយតុលាការ ឬ គណៈកម្មការសុរិយោដី ប្រសិនបើមានវិវាទលើកម្មសិទ្ធិកើតឡើង។

រូបភាពទី៨៖ វត្តមាននៃប្លង់រឹង



អ្នកឆ្លើយតបចិតសិបពីរភាគរយមិនអាចបញ្ជាក់អំពីយន្តការដីធ្លី (ថាជាសម្បទានដីសង្គមកិច្ច សេចក្តីណែនាំលេខ ០១។ល។) ដែលបានអនុវត្តលើដីធ្លីរបស់ពួកគេនោះ ហើយពួកគេគ្រាន់តែនិយាយថា “ផ្សេងៗ” អ្នកឆ្លើយតបចំនួន ៧៤ ភាគរយបាននិយាយថា ពួកគេមិនយល់អំពីយន្តការដីធ្លី ឬរបៀបអនុវត្តយន្តការនោះទេ។ ចំណុចនេះអាចចង្អុលបង្ហាញអំពីកង្វះខាតក្នុងការទទួលបានព័ត៌មានមុនពេលតាំងទីលំនៅថ្មី។

នៅក្នុងការសិក្សា បុរសចំនួន ៥១ ភាគរយ និង ស្ត្រីចំនួន ៤៩ ភាគរយ បានរាយការណ៍ថា មានប័ណ្ណកម្មសិទ្ធិ។ ជាទូទៅនៅពេលចេញប័ណ្ណកម្មសិទ្ធិ គេនឹងដាក់ឈ្មោះដៃគូទាំងសងខាង ហើយនៅពេលដាក់ឈ្មោះដៃគូតែម្ខាង ស្ត្រីបានរាយការណ៍ថាមានប័ណ្ណកម្មសិទ្ធិដីធ្លីនៅក្រោមឈ្មោះរបស់ពួកគេច្រើនជាងបុរស។ រូបភាពទី៩ បង្ហាញអំពីកម្មសិទ្ធិលើប័ណ្ណកម្មសិទ្ធិដីធ្លីនៅកន្លែងតាំងទីលំនៅថ្មីនីមួយៗ បែងចែកតាមភេទ។

ពាក់ព័ន្ធនឹងឯកសាររដ្ឋបាល ភាគរយខ្ពស់នៃគ្រួសារទាំងឡាយ បានឆ្លើយតបថា ពួកគេមានសំបុត្រកំណើត និង សៀវភៅគ្រួសារ និងបានចុះបញ្ជីជាមួយអាជ្ញាធរភូមិ និង ឃុំ។ ដូច្នេះ អាជ្ញាធរមូលដ្ឋាន បានផ្តល់សេវារដ្ឋបាលចាំបាច់ដល់គ្រួសារដែលបានតាំងទីលំនៅថ្មី។ ភាគច្រើននៃអ្នកដែលបានទទួលសៀវភៅគ្រួសារ បានរាយការណ៍ថា ពួកគេមិនចាំបាច់បង់ប្រាក់ដើម្បីទទួលបានវានោះទេ។ ក្នុងចំណោមអ្នកឆ្លើយតប ១១ ភាគរយដែលបានបង់ប្រាក់ ជាងមួយភាគបី បាននិយាយថា ថ្លៃសេវាមានចំនួន ចន្លោះពី ០,៥-១០ ដុល្លារអាមេរិក។

**រូបភាពទី៩៖ ការប្រៀបធៀបរវាងបុរស និង ស្ត្រីដែលមានប័ណ្ណកម្មសិទ្ធិ**



## ២.៣.៤ លទ្ធភាពក្នុងការទទួលបានសេវាមូលដ្ឋាន

### ២.៣.៤.១ ផ្ទះ ផ្លូវថ្នល់ និង ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបង្ហូរទឹក

គ្រួសារចំនួនសែសិបភាគរយបានរាយការណ៍ថា មានផ្ទះដែលមានទំហំចន្លោះពី ៣០-៥០ម$^{២}$។ គ្រួសារ ៥៧ ភាគរយ បាននិយាយថា នៅក្នុងផ្ទះរបស់ពួកគេ មានពីរបន្ទប់។ បន្ទប់ភាគច្រើនត្រូវបានប្រើប្រាស់ជាបន្ទប់គេង ដែលបន្ទប់ទីពីរ តាមធម្មតា ត្រូវបានប្រើប្រាស់ជាបន្ទប់ទឹក។ ការសិក្សានេះមិនអាចទាញសេចក្តីសន្និដ្ឋានអំពីភាពគ្រប់គ្រាន់នៃទំហំផ្ទះ និង ថាតើវាចង្អៀតពេកដែរឬទេ។ ប្រទេសកម្ពុជាមិនទាន់មានបញ្ជាក់អំពីទំហំស្តង់ដារសម្រាប់លំនៅឋាននៅឡើយទេ ប៉ុន្តែស្តង់ដារអប្បបរមាសម្រាប់ទីជម្រក ផ្អែកតាមចម្លើយផ្អែកមនុស្សធម៌ គឺចាប់ពី ៣,៥ម$^{២}$ សម្រាប់មនុស្សម្នាក់[16] ឬ ២១-២៧ម$^{២}$ សម្រាប់មួយគ្រួសារដែលមានសមាជិកប្រាំមួយនាក់។

គ្រួសារចំនួនប្រាំបីភាគរយបានរាយការណ៍ថា ស័ង្កសី/លោហៈ ត្រូវបានប្រើប្រាស់ជាសម្ភារៈសង់ដំបូល ហើយគ្រួសារភាគច្រើនបាននិយាយថា ដំបូលរបស់ពួកគេមានសភាព "មធ្យម"។ គ្រួសារចំនួន ៥២ ភាគរយ បាននិយាយថា ជញ្ជាំងរបស់ពួកគេធ្វើពីឈើ និង ភាគច្រើនបាននិយាយថា ជញ្ជាំងរបស់ពួកគេមានសភាព "មធ្យម"។ ពាក់ព័ន្ធនឹងដំបូល និង លំនៅឋាន សម្ភារៈប្រើប្រាស់ហាក់បីដូចជាមានភាពសមស្រប។

ស្ថានភាពផ្លូវថ្នល់នៅលើទីតាំងទាំងនេះ ព្រមទាំង ផ្លូវទៅ និង មកពីទីតាំង ត្រូវបានចាត់ទុកថា មានលក្ខណៈ "មធ្យម" ដូច្នេះហើយ វាហាក់បីដូចជាបានបំពេញតាមស្តង់ដារនៃភាពសមរម្យ។

អ្នកឆ្លើយតបចំនួនហុកសិបប្រាំមួយភាគរយបាននិយាយថា គ្មានប្រព័ន្ធបង្ហូរទឹកនៅកន្លែងតាំងទីលំនៅថ្មីរបស់ពួកគេនោះទេ។ មួយភាគបួននៃអ្នកឆ្លើយតបទាំងអស់បាននិយាយថា កន្លែងតាំងទីលំនៅថ្មីបានរងផលប៉ះពាល់ពីទឹកជំនន់ ដោយ៣៣ ភាគរយបាននិយាយថា ទឹកជំនន់មានរយៈពេល ១-២ថ្ងៃ ប៉ុន្តែឆាប់ស្ងួតគួរសម។ គ្រួសារចំនួនម្ភៃប្រាំមួយភាគរយបាននិយាយថា ទឹកជំនន់មានរយៈពេលជាច្រើនថ្ងៃ ហើយវាបានបង្កផលប៉ះពាល់ដល់ផ្ទះ និង ការចេញចូលផ្ទះរបស់ពួកគេ និង ២៤ ភាគរយបាននិយាយថា ទឹកជំនន់ តាមធម្មតា មានរយៈពេល ៣-៤ថ្ងៃ និង មិនត្រូវបានបង្ហូរចេញយ៉ាងត្រឹមត្រូវនោះទេ។ រដ្ឋាភិបាលគប្បីផ្តល់លូ និង ប្រព័ន្ធបង្ហូរទឹក នៅកន្លែងតាំងទីលំនៅថ្មី។

រូបភាពទី១០ បង្ហាញអំពីការឆ្លើយតបដែលទទួលបានពីកន្លែងតាំងទីលំនៅថ្មីទាំងអស់ ពាក់ព័ន្ធនឹងអត្ថិភាពនៃប្រព័ន្ធបង្ហូរទឹកនៅលើទីតាំងរបស់ពួកគេ។

**រូបភាពទី១០៖ អត្ថិភាពនៃប្រព័ន្ធបង្ហូរទឹក**




16 Kennedy J. និង Parrack, C., ប្រវត្តិសាស្ត្រនៃទំហំបីចុចប្រាំម៉ែត្រការ៉េ ដែលត្រូវបានរកឃើញនៅក្នុងគម្រោងទីជម្រក ឆ្នាំ២០១១-២០១២ ទំព័រ ១០៩-១១០។ https://reliefweb.int/report/world/shelter-projects-2011-2012 បានចូលប្រើប្រាស់នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០។

### ២.៣.៤.២ ការមានស្បៀង និង លទ្ធភាពក្នុងការទទួលបានស្បៀងអាហារ

គ្រួសារចំនួនប៉ែតសិបភាគរយទទួលបានស្បៀងអាហារសមរម្យ។ គ្រួសារជាច្រើនដែលរស់នៅកន្លែងតាំងទីលំនៅថ្មី ដែលស្ថិតនៅក្នុងទីក្រុងធំៗ (រួមទាំងអ្នកដែលនៅតាមបណ្តាខេត្តផងដែរ) ទទួលបានស្បៀងអាហារសមរម្យ។ មូលហេតុបីសំខាន់ៗដែលគ្រួសារមួយចំនួនមិនទទួលបានស្បៀងអាហារសមរម្យ រួមមានៈ

- ពួកគេគ្មានប្រាក់ចំណូលទៀងទាត់
- ផ្សារនៅឆ្ងាយពីកន្លែងតាំងទីលំនៅថ្មី និង
- ស្បៀងអាហារមានតម្លៃថ្លៃជាងមុនការតាំងទីលំនៅថ្មី។

គ្រួសារជាច្រើនដែលកំពុងតែរស់នៅកន្លែងតាំងទីលំនៅថ្មី ដែលនៅឆ្ងាយពីផ្សារ និងមានប្រាក់ចំណូលមិនទៀងទាត់។ ចំណុចនេះចង្អុលបង្ហាញថា ចម្ងាយពីកន្លែងតាំងទីលំនៅថ្មីទៅផ្សារ មានផលជះដល់ទាំងកម្រិតប្រាក់ចំណូល និងកម្រិតនៃការទទួលបានស្បៀងអាហារសមរម្យដែលមានទំនាក់ទំនងទៅវិញទៅមក។

គ្រួសារប្រហែល ៧៥,៣ ភាគរយទទួលបានស្បៀងអាហារគ្រប់គ្រាន់។ មូលហេតុបីសំខាន់ៗដែលគ្រួសារមួយចំនួនទទួលបានស្បៀងអាហារមិនគ្រប់គ្រាន់ រួមមានៈ

- ពួកគេបានបាត់បង់ដីធ្លីសម្រាប់ដាំដំណាំ
- ពួកគេខ្វះខាតប្រាក់ចំណូលសមរម្យ និង
- ពួកគេបានប្រឈមមុខនឹងការពិបាកក្នុងការធ្វើដំណើរទៅផ្សារ។

គ្រួសារជាច្រើនដែលរស់នៅតាមបណ្តាខេត្ត និង នៅខាងក្រៅទីក្រុងសំខាន់ៗ ធ្លាប់ជួបប្រទះនិងការបាត់បង់ដីធ្លីសម្រាប់ដាំដំណាំ និង ខ្វះលទ្ធភាពទទួលបានស្បៀងអាហារគ្រប់គ្រាន់ ដោយសារតែមានប្រាក់ចំណូលមិនគ្រប់គ្រាន់ និង មានការពិបាកក្នុងការធ្វើដំណើរទៅផ្សារ។ នៅពេលដែលគ្រួសារទាំងឡាយបានបាត់បង់ដីធ្លីស្រែចំការ គ្រួសារទាំងនោះមានការខ្វះខាតប្រាក់ចំណូលមិនគ្រប់គ្រាន់។ នេះចង្អុលបង្ហាញថា ដីធ្លីអាចជាទ្រព្យសកម្មសម្រាប់ទាំងស្បៀងអាហារ និង ប្រាក់ចំណូល។

រូបភាពទី១១ បង្ហាញជាមធ្យម គ្រួសារចំនួន ២១ ភាគរយនៅកន្លែងតាំងទីលំនៅថ្មីទាំង ១២ កន្លែង (១១ ភាគរយនៃចំនួនគ្រួសារសរុប) ខ្វះខាតទាំងស្បៀងអាហារ និង លទ្ធភាពទទួលបានស្បៀងអាហារគ្រប់គ្រាន់។ គ្រួសារជាច្រើនដែលរស់នៅកន្លែងតាំងទីលំនៅថ្មីនៅតាមបណ្តាខេត្ត និង នៅខាងក្រៅទីក្រុងសំខាន់ៗ បានប្រឈមមុខនឹងការគំរាមកំហែងនៃធាតុទាំងពីរនេះនៃសិទ្ធិទទួលបានស្បៀងអាហារ។

គ្រួសារទាំងឡាយបានទទួលស្បៀងអាហារ ដែលពួកគេទទួលទានតាមរយៈការទិញច្រើនជាងការដាំដំណាំ ឬ ការប្រមូលអនុផលព្រៃឈើ។ មានគ្រួសារតែ០,១៦ភាគរយប៉ុណ្ណោះ និង គ្មានគ្រួសារជនជាតិដើមភាគតិចណាមួយ បានដាំដំណាំ ដើម្បីទទួលបានស្បៀងអាហារភាគច្រើនរបស់ពួកគេនោះទេ។ មាននិរសមភាពយេនឌ័រនៅពេលនិយាយដល់ ថាតើអ្នកណាជាអ្នកទទួលខុសត្រូវលើការទិញស្បៀងអាហារដែលគ្រួសារទទួលទាន។ ៩៤ ភាគរយនៃគ្រួសារ ដែលទិញស្បៀងអាហារ បានឆ្លើយតបថាស្ត្រីជាអ្នកទទួលខុសត្រូវទិញស្បៀងអាហារ។



រូបភាពនេះបង្ហាញពីផ្ទះទុកចោលនៅក្នុងតំបន់តាំងទីលំនៅថ្មី នៅតំបន់ត្រពាំងអញ្ចាញថ្មី, រាជធានីភ្នំពេញ។ រូបថត ៖ CUFA

### ២.៣.៤.៣ សេវាសាធារណៈ (ទឹក ថាមពលសម្រាប់បំភ្លឺ អគ្គិសនី ឥន្ទនៈសម្រាប់ចម្អិនម្ហូបអាហារ អនាម័យ)

ក្នុងអំឡុងរដូវប្រាំង ប្រភពទឹកសម្រាប់គ្រួសារភាគច្រើនគឺៈ ទឹកស្រះឯកជន បឹង ទន្លេ អូរ ឬ ទឹកដែលទិញពីម្ចាស់ប្រភព ឬគ្រួសារដែលរងផលប៉ះពាល់ដទៃទៀតដែលបានប្រមូលទឹកពីប្រភពឯកជន បឹង ស្រះ ទន្លេ ឬ អូរសាធារណៈ និងបំពង់ទឹកសាធារណៈ។ ក្នុងអំឡុងរដូវវស្សា គ្រួសារភាគច្រើនបានប្រើប្រាស់ៈ ទឹកភ្លៀង បឹង ស្រះ ទន្លេ ឬ អូរសាធារណៈ និង ប្រព័ន្ធទឹកសាធារណៈ។ គ្រួសារជាច្រើនដែលរស់នៅតាមបណ្តាខេត្ត

## រូបភាពទី១១៖ មិនទទួលស្បៀងអាហារសមរម្យ និង មិនទទួលបានស្បៀងអាហារគ្រប់គ្រាន់




និង នៅខាងក្រៅទីក្រុងសំខាន់ៗ បានប្រើប្រាស់ទឹកដែលបានមកពីបឹង ស្រះ ទន្លេ ឬ អូរឯកជន និង សាធារណៈ នៅខណៈពេលដែលគ្រួសារជាច្រើនទៀតដែលរស់នៅក្នុងទីក្រុងសំខាន់ៗបានប្រើប្រាស់ទឹកពីប្រព័ន្ធទឹកសាធារណៈ។

គ្រួសារជនជាតិដើមភាគតិចប្រើប្រាស់ទាំងប្រភពទឹកឯកជន និង សាធារណៈ។ ពុំមានទឹកប្រើប្រាស់ពីប្រព័ន្ធទឹកសាធារណៈទេ។ គ្រួសារជនជាតិដើមភាគតិចជាច្រើនបានពឹងផ្អែកលើទឹកក្រោមដី និងពឹងផ្អែកយ៉ាងខ្លាំងលើប្រភពទឹកឯកជន។ នេះប្រហែលមកពីកន្លែងតាំងទីលំនៅថ្មីរបស់ពួកគេស្ថិតនៅក្បែរទីតាំងចាស់របស់ពួកគេ ជាកន្លែងដែលទំនប់វារីអគ្គិសនីបានសាងសង់រួចរាល់ ហើយទំនប់ទាំងនោះអាចបង្កើតថ្លៃទឹកសម្រាប់គ្រួសារជនជាតិដើមភាគតិច។

ប្រហែល ៦៧,៦ ភាគរយនៃគ្រួសារទាំងឡាយ (រួមទាំង គ្រួសារជនជាតិដើមភាគតិចចំនួន ៦០ ភាគរយផងដែរ) បានប្រើប្រាស់ទឹកដែលពួកគេទទួលបាន សម្រាប់ពិសារ និង ចម្អិនម្ហូបអាហារ។ មូលហេតុបីសំខាន់ៗដែលគ្រួសារមួយចំនួនមិនប្រើប្រាស់ទឹកទាំងនោះសម្រាប់ពិសារ និង ចម្អិនម្ហូបអាហារ ពីព្រោះទឹកទាំងនោះ៖

- មានដី និង/ឬ សំរាមជាច្រើន
- ចាំបាច់ត្រូវដាំឱ្យពុះ ឬ ចម្រោះ និង ឬ
- ត្រូវបានចាត់ទុកថាគ្មានសុវត្ថិភាព។

វិធីសាស្ត្រចម្បងដើម្បីទទួលបានទឹកសម្រាប់ពិសារ និង ចម្អិនម្ហូបអាហារ គឺការដាំទឹក ឬ ការចម្រោះទឹក។ រូបភាពទី១២ ខាងក្រោម បង្ហាញភាគរយនៃគ្រួសារដែលបានប្រើប្រាស់ទឹកដែលពួកគេទទួលបាន សម្រាប់ពិសារ និង ចម្អិនម្ហូបអាហារ និង គ្រួសារដែលមិនបានប្រើប្រាស់ទឹកដែលពួកគេទទួលបាន សម្រាប់ពិសារ និង ចម្អិនម្ហូបអាហារ។

ប្រភពថាមពលសម្រាប់បំភ្លឺចំបង គឺអគ្គិសនី (គ្រួសារចំនួន ៧៧ ភាគរយ)។ គ្រួសារជាច្រើនដែលកំពុងតែរស់នៅក្នុងទីក្រុងសំខាន់ៗបានប្រើប្រាស់អគ្គិសនីសម្រាប់បំភ្លឺ និង គ្រួសារជាច្រើនផ្សេងទៀតដែលរស់នៅតាមបណ្ដាខេត្ត និង នៅខាងក្រៅទីក្រុងសំខាន់ៗ បានប្រើប្រាស់អាគុយសម្រាប់បំភ្លឺ។ ៩៥ ភាគរយនៃគ្រួសារជនជាតិដើមភាគតិច ដែលរស់នៅខាងក្រៅទីក្រុងសំខាន់ៗ បានប្រើប្រាស់អគ្គិសនីសម្រាប់បំភ្លឺ។ ក្នុងចំណោមគ្រួសារដែលបានប្រើប្រាស់អគ្គិសនីសម្រាប់បំភ្លឺទាំងអស់ ៩៧ ភាគរយបានអះអាងថា អគ្គិសនីគឺទទួលបានពីប្រភពសាធារណៈ។ ចំណាយប្រចាំខែលើថ្លៃអគ្គិសនីសម្រាប់គ្រួសារភាគច្រើនគឺ ចាប់ពី ១-១០ ដុល្លារអាមេរិក។

ចំពោះឥន្ធនៈសម្រាប់ចម្អិនម្ហូបអាហារ គ្រួសារ ៦០ ភាគរយបានប្រើប្រាស់អុស និង ៥១ ភាគរយបានប្រើប្រាស់ហ្គាសសម្រាប់ចម្អិនម្ហូបអាហារ។ គ្រួសារជាច្រើនដែលរស់នៅតាមបណ្ដាខេត្ត និង នៅខាងក្រៅទីក្រុងសំខាន់ៗបានប្រើប្រាស់អុស ខណៈពេលដែលគ្រួសារជាច្រើនដែលរស់នៅក្នុងទីក្រុងសំខាន់ៗ (រួមទាំងនៅតាមបណ្ដាខេត្តផងដែរ) បានប្រើប្រាស់ហ្គាសសម្រាប់ចម្អិនម្ហូបអាហារ។ ថ្លៃឥន្ធនៈសម្រាប់ចម្អិនម្ហូបអាហារប្រចាំខែ សម្រាប់គ្រួសារចំនួន ៨២ ភាគរយ គឺ ១-១០ ដុល្លារអាមេរិកក្នុងមួយខែ។ គ្រួសារជាច្រើនដែលរស់នៅក្នុងទីក្រុងសំខាន់ៗចំណាយលើថ្លៃឥន្ធនៈសម្រាប់ចម្អិនម្ហូបអាហារប្រចាំខែមានចំនួនខ្ពស់ជាងនេះ។

ចំពោះអនាម័យ គ្រួសារចំនួន ៧២ ភាគរយបានប្រើប្រាស់បង្គន់ចាក់ទឹក និង គ្រួសារចំនួន ៨៧ ភាគរយបានអះអាងថា បង្គន់ដែលពួកគេមានដំណើរការល្អ។ គ្រួសារចំនួន ១៣ ភាគរយបានអះអាងថា បង្គន់ទាំងនោះមិនដំណើរការទេ ភាគច្រើនសំដៅលើបង្គន់រណ្ដៅដែលពួកគេមានអារម្មណ៍ថាគ្មានផាសុកភាពក្នុងការប្រើប្រាស់ មួយផ្នែកដោយសារតែកង្វះភាពឯកជន។ គ្រួសារចំនួន ៧៣ ភាគរយដុតកាកសំណល់រឹងរបស់ពួកគេ ៣២ភាគរយចាក់សំណល់នៅកន្លែងតាំងទីលំនៅថ្មី និង ២១ភាគរយបានអះអាងថាមានឡានដឹកសំរាមមកប្រមូល។ គ្រួសារជាច្រើននៅភ្នំពេញមានឡានដឹកសំរាមមកប្រមូលកាកសំណល់។

រូបភាពទី១២៖ ថាតើទឹកត្រូវបានប្រើប្រាស់សម្រាប់ពិសារ និង ចម្អិនម្ហូបអាហារដែរឬទេ (ភាគរយនៃគ្រួសារ)



### ២.៣.៤.៤ ការអប់រំ និង សេវាសុខាភិបាល

គ្រួសារប្រហែល ៤៣,៦ ភាគរយ មានកូនដែលមិនបានទៅសាលារៀន។[17] ក្នុងចំណោមគ្រួសារទាំងនោះ ៦២ ភាគរយបាននិយាយថា កូនៗមិនបានទៅសាលារៀននោះទេ ពីព្រោះពួកគេមានអាយុតិចជាងអាយុត្រូវចូលសិក្សា និង ៤៧ ភាគរយបានអះអាងថា កូនៗរបស់ពួកគេចាំបាច់ត្រូវធ្វើការដើម្បីស្វែងរកប្រាក់ចំណូល ជំនួសឱ្យការទៅសាលារៀន។ គ្រួសារចំនួន ៥៦,៣ ភាគរយមានកូនម្នាក់ទៅប្រាំពីរនាក់ដែលមានអាយុត្រូវចូលសិក្សា (៤៧,២ ភាគរយមានកូនម្នាក់ ឬ ពីរនាក់ ដែលមានអាយុត្រូវចូលសិក្សា)។ រូបភាពទី១៣ ប្រៀបធៀបភាគរយនៅកន្លែងតាំងទីលំនៅថ្មីចំនួន ១៥ កន្លែង។ គ្រួសារជាច្រើនដែលរស់នៅខាងក្រៅភ្នំពេញ មិនបានបញ្ជូនកូនរបស់ពួកគេទៅសាលារៀននោះទេ ពីព្រោះពួកគេចាំបាច់ត្រូវស្វែងរកប្រាក់ចំណូល។ មានគ្រួសារជនជាតិដើមភាគតិចប្រហែល ៤៦ ភាគរយ ដែលកូនៗរបស់ពួកគេចាំបាច់ត្រូវធ្វើការជំនួសឱ្យការទៅសាលារៀន។

កុមារប្រហែល ៩០,៣ ភាគរយបានទៅសាលារៀនដែលស្ថិតនៅកន្លែងតាំងទីលំនៅថ្មី ឬ នៅក្នុងភូមិតែមួយនឹងកន្លែងតាំងទីលំនៅថ្មី។ គ្រួសារចំនួនកៅសិបភាគរយមានកូនទៅសាលារៀនដោយមិនបង់ថ្លៃសិក្សា។ ក្នុងចំណោមគ្រួសារដែលបង់ថ្លៃសិក្សា ៨៧,៥% បានបង់ថ្លៃជាចាំបាច់ និង ១២,៥ ភាគរយ បានបង់ប្រាក់ដោយស្ម័គ្រចិត្ត។ ពាក់ព័ន្ធនឹងចំណាយលើការអប់រំ គ្រួសារចំនួន ៦៨ ភាគរយដែលមានកូនទៅសាលារៀន បានទូទាត់ប្រាក់ចំនួន ១ ដុល្លារ ទៅ ៣០ ដុល្លារអាមេរិក និង ២១ ភាគរយបានចំណាយច្រើនជាង ៥០ ដុល្លារ។

គ្រួសារចំនួនចិតសិបពីរភាគរយ (រួមទាំងគ្រួសារជនជាតិដើមភាគតិចចំនួន ៥១ ភាគរយផងដែរ) មិនដឹងថាមានវត្តមានអ្នកស្ម័គ្រចិត្តផ្តល់ការថែទាំសុខភាពនៅកន្លែងតាំងទីលំនៅថ្មីនោះទេ។ គ្រួសារចំនួន៨៣ភាគរយបានប្រើប្រាស់មណ្ឌលសុខភាពឃុំ។ រូបភាពទី១៤បង្ហាញអំពីមូលហេតុដែលគ្រួសារចំនួន ១៧ ភាគរយមិនបានប្រើប្រាស់មណ្ឌលសុខភាពនៅក្នុងឃុំ។

គ្រួសារភាគច្រើនបានប្រើប្រាស់មណ្ឌលសុខភាពឃុំ ដើម្បីទទួលបានការព្យាបាលបឋម និងថ្នាំសម្រាប់ជំងឺតិចតួច និងគ្រួសារមួយភាគប្រាំ បានប្រើប្រាស់មណ្ឌលសុខភាពឃុំ សម្រាប់សេវាថែទាំសុខភាពផ្លូវភេទ និងការបន្តពូជ។ បន្ថែមពីលើ ឬ ជំនួសឱ្យមណ្ឌលសុខភាព គ្រួសារចំនួន ៤៩ភាគរយបានទៅ ឱសថស្ថាន និង ៣៧ភាគរយបានទៅព្យាបាលនៅគ្លីនិកឯកជនសម្រាប់សេវាថែទាំសុខភាព។ គ្រួសារចំនួន ៦៦ ភាគរយបានទទួលសេវាថែទាំសុខភាពសាធារណៈដោយឥតគិតថ្លៃ និង គ្រួសារចំនួន ៣១ភាគរយ (រួមទាំងគ្រួសារជនជាតិដើមភាគតិចចំនួន ៣៩ភាគរយផងដែរ) ត្រូវបានគេស្នើសុំឱ្យបង់ប្រាក់សម្រាប់សេវាទាំងនោះ។ ៨៦ភាគរយនៃគ្រួសារដែលបានបង់ប្រាក់សម្រាប់សេវាថែទាំសុខភាពសាធារណៈបានបង់ថ្លៃសេវា ស្តង់ដារជាផ្លូវការ និង ៤ភាគរយ ត្រូវបានស្នើសុំឱ្យទូទាត់ប្រាក់លើសពីថ្លៃសេវាស្តង់ដារជាផ្លូវការ (៣៧,៥ ភាគរយបានទូទាត់ "ថ្លៃទឹកតែ" ដែលមន្ត្រីបានស្នើសុំ)។

ប្រាំមួយភាគរយនៃអ្នកឆ្លើយតបសរុបបាននិយាយថា មិនមានសេវាសុខភាព (គ្មានមណ្ឌលសុខភាព គ្មានសេវាសុខភាព និងគ្មានមន្ទីរពេទ្យ) នៅកន្លែងតាំងលំនៅថ្មី។ អ្នកឆ្លើយតបទាំងនេះបានមកពីចំនួន ៧ទីតាំងក្នុងចំណោម១៧ទីតាំង។ នៅតាមបណ្តាខេត្តអត្រាអ្នកឆ្លើយតបច្រើនជាងគេ (៥០ %) គឺនៅអូរកម្ពុជា (ខេត្តព្រះសីហនុ)។

រូបភាពទី១៣៖ គ្រួសារដែលត្រូវការឱ្យកូនៗរបស់ពួកគេទៅធ្វើការ




17 សាលារៀននៅទីនេះ សំដៅលើទាំងសាលារដ្ឋ និង សាលារៀនដែលស្ថិតនៅលើកន្លែងតាំងទីលំនៅថ្មីដែលដំណើរការដោយអង្គការសប្បុរសធម៌ ឬ អង្គការមិនមែនរដ្ឋាភិបាល ដែលត្រូវបានបង្កើតឡើងក្នុងលក្ខណៈសប្បុរសធម៌។

## រូបភាពទី១៤៖ មូលហេតុដែលមិនប្រើប្រាស់មន្ទីរសម្រាកព្យាបាលនៅក្នុងឃុំ




សិទ្ធិទទួលបានស្តង់ដារខ្ពស់បំផុតនៃសុខភាពផ្លូវកាយ និងផ្លូវចិត្ត មិនត្រូវបានបង្ខាំងក្នុងការទទួលបានការថែទាំសុខភាពនោះទេ។ សិទ្ធិទទួលបានសុខភាព រួមបញ្ចូលនូវកត្តាសេដ្ឋកិច្ចសង្គមយ៉ាងទូលំទូលាយ ដែលលើកកម្ពស់លក្ខខណ្ឌដែលមនុស្សអាចដឹកនាំជីវិតប្រកបដោយសុខភាពល្អ និងពង្រីកដល់កត្តាកំណត់មូលដ្ឋាននៃសុខភាព ដូចជាចំណីអាហារ និងអាហារូបត្ថម្ភ ទទួលបានទឹកស្អាត និងមានសុវត្ថិភាព និង អនាម័យគ្រប់គ្រាន់។[18]

## ២.៣.៥ ជីវភាពរស់នៅ

មួយភាគបីនៃគ្រួសារទាំងអស់បានរាយ-ការណ៍ថាមានជាប់បំណុល។ គ្រួសារជិតពាក់កណ្តាលបានរាយការណ៍ថាមានជាប់បំណុលចាប់ពី ១.០០០ ដុល្លារ រហូតដល់ ៥.០០០ ដុល្លារ។ ក្នុងចំណោមគ្រួសារដែលមានជាប់បំណុលទាំងនោះ ៨៧ ភាគរយបាននិយាយថា បំណុលរបស់ពួកគេមានការកើនឡើងចាប់តាំងពីពួកគេបានផ្លាស់ទៅនៅកន្លែងតាំងទីលំនៅថ្មី។ ក្នុងចំណោមអ្នកឆ្លើយតបដែលបាននិយាយថាពួកគេមានជាប់បំណុលនោះ ស្ទើរតែទាំងអស់បាននិយាយថាពួកគេបានទទួលកម្ចីឥណទាន។ គ្រួសារជនជាតិដើមភាគតិចគឺជាគ្រួសារដែលទំនងជាមានបំណុលតិចជាងគេបង្អស់ ពីព្រោះមានតែ ៣ ភាគរយប៉ុណ្ណោះដែលបាននិយាយថាពួកគេបានទទួលកម្ចីឥណទាន។ រូបភាពទី១៥ បង្ហាញអំពីចំនួនទឹកប្រាក់នៃបំណុលនៅទូទាំងកន្លែងតាំងទីលំនៅថ្មីទាំងអស់។

អ្នកឆ្លើយតបចំនួនម្ភៃបីភាគរយបានអះអាងថា ប្រាក់ដែលបានខ្ចីត្រូវបានប្រើប្រាស់សម្រាប់សាងសង់ផ្ទះ ដោយអ្នកឆ្លើយតបចំនួន ២០ ភាគរយផ្សេងទៀតបានអះអាងថា ប្រាក់ទាំងនោះត្រូវបានប្រើប្រាស់លើជីវភាពរស់នៅ និង ធាតុចូលសម្រាប់ការធ្វើកសិកម្ម។ អ្នកដែលបានរាយការណ៍ថាបំណុលមានការកើនឡើង បានផ្តល់មូលហេតុ (និង ភាគរយ) ដូចគ្នានឹងហេតុផលខាងលើដែរ។ ចំណុចនេះអាចនឹងចង្អុលបង្ហាញថា ការតាំងទីលំនៅថ្មីបានរួមចំណែកកើតមានជាបំណុល ហើយសំណងសម្រាប់ការតាំងទីលំនៅថ្មីគឺមិនគ្រប់គ្រាន់។ គោលការណ៍ជាមូលដ្ឋាន និង គោលការណ៍ណែនាំស្តីពីការបណ្តេញចេញ និង ការចាកចេញដោយបង្ខំចិត្តផ្អែកលើការអភិវឌ្ឍ ចង្អុលបង្ហាញថា សំណងត្រូវតែជាសំណងសមរម្យ និង យុត្តិធម៌ សំណងគប្បីត្រូវបានផ្តល់ជូនសម្រាប់ការខូចខាតណាមួយដែលអាចវាយតម្លៃបានតាមបែបសេដ្ឋកិច្ច ដែលគិតគូរដល់ការខាតបង់ និង សោហ៊ុយនានា "ឧទាហរណ៍៖ ការបាត់បង់ដីធ្លី និង ការខូចខាតសម្ភារៈផ្ទះសម្បែង ហេដ្ឋារចនាសម្ព័ន្ធ ការដាក់បញ្ចាំ ឬ ការផាកពិន័យលើបំណុលផ្សេងទៀត លំនៅឋានបណ្តោះអាសន្ន ថ្លៃសេវាការិយាធិបតេយ្យ និង សេវាផ្លូវច្បាប់ លំនៅឋានជំនួស បាត់បង់ប្រាក់ឈ្នួល និង ប្រាក់ចំណូល បាត់បង់ឱកាសទទួលបានការអប់រំ ការថែទាំសុខភាព និង ការព្យាបាលជំងឺ សោហ៊ុយចំណាយសំរាប់ការដឹកជញ្ជូន និងការតាំងទីលំនៅថ្មី (ជាពិសេស ក្នុងករណីផ្លាស់ទីលំនៅទៅឆ្ងាយពីប្រភពចិញ្ចឹមជីវិត)។ ដីធ្លី ផ្ទះសម្បែង ក៏ជាប្រភពនៃជីវភាពដែលត្រូវបានផ្តល់ជូនដល់អ្នកដែលត្រូវបានបណ្តេញចេញ ការវាយតម្លៃអំពីផលប៉ះពាល់ និងការខាតបង់ ត្រូវតែគិតគូរបូកសរុបតម្លៃទៅដល់ការខាតបង់អាជីវកម្ម មុខរបររកស៊ី គ្រឿងបរិក្ខារ/សារពើភ័ណ្ឌ ការចិញ្ចឹមសត្វ ការដាំដុះ/ផលដំណាំ និងប្រាក់ឈ្នួល/ប្រាក់ចំណូលដែលបានបាត់បង់/ថយចុះ។

គ្រួសារភាគច្រើនមានសមាជិកម្នាក់ ឬ ច្រើននាក់នៅក្នុងគ្រួសារដែលបានរួមចំណែកផ្តល់ប្រាក់ចំណូល។ ការរួមចំណែកភាគច្រើនស្ថិតនៅក្នុងទម្រង់ជាសាច់ប្រាក់។ ៦៦ភាគរយ នៃគ្រួសារទាំងអស់បាននិយាយថាការផ្តល់ប្រាក់ចំណូលមានភាពមិនទៀងទាត់ ដោយទីតាំងទាំងពីរកន្លែងនៅក្នុង

18 សូមមើល សេចក្តីពន្យល់រួមលេខ ១៤ នៃកតិកាសញ្ញាសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ស្តីអំពី៖ សិទ្ធិទទួលបានស្តង់ដារសុខភាពខ្ពស់បំផុត (មាត្រា១២), ចុះទីថ្ងៃទី១១ ខែសីហា ឆ្នាំ២០០០, E/C.12/2000/4, para.

ខេត្តស្ទឹងត្រែង ជាកន្លែងដែលមានភាគរយច្រើនជាងគេដែលគ្រួសារជនជាតិដើមភាគតិចរស់នៅ ពួកគេបានរាយការណ៍អំពីបញ្ហានេះ។

គ្រួសារចំនួនកៅសិបបីភាគរយបាននិយាយថា អ្នករួមចំណែកផ្តល់ប្រាក់ចំណូលបានរស់នៅលើកន្លែងតាំង ទីលំនៅថ្មីដែរ។ ក្នុងចំណោមគ្រួសារដែលបាននិយាយថា អ្នករួមចំណែកផ្តល់ប្រាក់ចំណូលបានផ្លាស់ចេញទៅនៅទីឆ្ងាយ ៤៥ ភាគរយបាននិយាយថា ពួកគេបានផ្លាស់ទីទៅទីក្រុង/ទីប្រជុំជន។ នៅខណៈពេលដែល បច្ចុប្បន្នមានភាគរយខ្ពស់នៃគ្រួសារបានរាយការណ៍ថាមានប្រាក់ចំណូលគ្រប់គ្រាន់ ពួកគេបានកត់សម្គាល់ឃើញថាមុនពេលផ្លាស់ទីលំនៅ ភាគរយនៃគ្រួសារដែលបានរាយការណ៍ថាមានប្រាក់ចំណូលគ្រប់គ្រាន់មានចំនួនច្រើនជាងនេះទៀត ដូច្នេះមានន័យថាការតាំងទីលំនៅថ្មី បានធ្វើឱ្យគ្រួសារទាំងឡាយមានភាពក្សត់ខ្សោយជាងពេលដែលស្នាក់នៅទីតាំងចាស់របស់ពួកគេ។ គ្រួសារចំនួនប៉ែតសិបប្រាំភាគរយ

### រូបភាពទី១៥៖ បំណុលសរុប (ភាគរយនៃគ្រួសារ)



បានរាយការណ៍ថាការរួមចំណែកទាំងអស់ចំពោះគ្រួសារ ធ្វើអោយប្រាក់ចំណូលរបស់គ្រួសារមានចំនួនគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការរបស់គ្រួសារនៅកន្លែងតាំងទីលំនៅថ្មី។ គ្រួសារដែលបាននិយាយថាមានប្រាក់ចំណូលមិនគ្រប់គ្រាន់ ត្រូវបានសាកសួរថាតើហេតុអ្វីបានជាពួកគេអះអាងបែបនេះ ហើយជាងពាក់កណ្តាលបាននិយាយថាប្រាក់ចំណូលមិនគ្រប់គ្រាន់ពីព្រោះឱកាសការងារនៅកន្លែងតាំងទីលំនៅថ្មីមានចំនួនតិចជាងមុន។ នៅពេលដែលគ្រួសារត្រូវបានសាកសួរថាតើមានប្រាក់ចំណូលគ្រប់គ្រាន់ដែរឬទេ នៅពេលនៅទីតាំងចាស់របស់ពួកគេ (កន្លែងដែលពួកគេត្រូវបានបណ្តេញចេញ) ៩៦ភាគរយ បាននិយាយថាគ្រប់គ្រាន់។ គ្រួសារទាំងឡាយត្រូវបានសាកសួរថាតើហេតុអ្វីបានជាពួកគេមានប្រាក់ចំណូលគ្រប់គ្រាន់ នៅពេលនៅទីតាំងចាស់របស់ពួកគេ ហើយពួកគេបាននិយាយថា ពីព្រោះទីតាំងចាស់៖

- នៅជិតកន្លែងធ្វើការរបស់ពួកគេជាង (២៦ ភាគរយ)
- នៅជិតកន្លែងធ្វើការជាង និង ងាយចេញចូលផ្សារជាង (២៥ ភាគរយ)
- បានផ្តល់ធនធានពីធម្មជាតិ (១៧ ភាគរយ)។

ស្ទើរតែគ្រប់គ្រួសារទាំងអស់បាននិយាយថា ពួកគេគ្មានប្រភពប្រាក់ចំណូលផ្សេង ក្រៅពីការរួមចំណែកពីសមាជិកគ្រួសាររបស់ពួកគេនោះទេ។ មានកង្វល់អំពីភាពមិនទៀងទាត់នៃការផ្តល់ប្រាក់ចំណូល ជាពិសេសនៅពេលដែលវាមានទំនាក់ទំនងនឹងសន្តិសុខស្បៀងអាហារ (ចូរមើល ផ្នែកស្តីពីការមានស្បៀង និង លទ្ធភាពក្នុងការទទួលបានស្បៀងអាហារ)។

រូបភាពទី១៦ បង្ហាញអំពីភាពមិនទៀងទាត់នៃប្រាក់ចំណូលនៅគ្រប់កន្លែងតាំងទីលំនៅថ្មីទាំងអស់។

**រូបភាពទី១៦៖ ភាពទៀងទាត់នៃប្រាក់ចំណូល (ភាគរយនៃគ្រួសារ)**



គ្រួសារចំនួនហាសិបបួនភាគរយបាននិយាយថា ឱកាសការងារនៅតែមានដូចនៅទីតាំងចាស់របស់ពួកគេដែរ ២៤ភាគរយបាននិយាយថា ឱកាសការងារមានភាពល្អប្រសើរជាងមុន និង ២២ ភាគរយផ្សេងទៀត បាននិយាយថាឱកាសការងារមានការថយចុះ។ អ្នកដែលបានឆ្លើយតបថា ឱកាសការងារមានការប្រែប្រួល ត្រូវបានស្នើសុំឱ្យពន្យល់អំពីចម្លើយរបស់ពួកគេ។ គ្រួសារដែលបាននិយាយថាឱកាសការងារមានភាពល្អប្រសើរឡើង បានពន្យល់ថា៖

- លក្ខខណ្ឌការងារល្អជាងមុន (៥៩ ភាគរយ)
- មានជម្រើសនៃឱកាសច្រើនជាងមុន (៥៧ ភាគរយ) និង
- ការទៅផ្សារមានភាពងាយស្រួលជាងមុន (២៦ ភាគរយ)។

គ្រួសារដែលបាននិយាយថាពុំមានការភាពល្អប្រសើរទេនោះ បាននិយាយថា៖

- កង្វះខាតអតិថិជននៅក្បែរកន្លែងតាំងទីលំនៅថ្មី (៥៥ ភាគរយ)
- លក្ខខណ្ឌការងារអាក្រក់ជាងមុន (៥០ ភាគរយ) និង
- កង្វះខាតបណ្តាញក្នុងមូលដ្ឋាន (៤៥ ភាគរយ)។

គ្រួសារជនជាតិដើមភាគតិចមានភាគរយខ្ពស់ ដែលបាននិយាយថា ឱកាសការងារបានថយចុះ (២៨ ភាគរយ) ហើយពួកគេបានផ្តល់ហេតុផលខុសៗគ្នា។ ពួកគេបានបន្ថែមពីលើចម្លើយទាំងបីដែលត្រូវបានលើកឡើងនៅខាងលើ និង បាននិយាយថា មានការកាត់បន្ថយការចេញចូលផ្សារ បង្កើនថ្លៃដឹកជញ្ជូន ព្រមទាំង ការធ្វើដំណើរពីទីតាំងទៅ និង មកពីកន្លែងធ្វើការរបស់ពួកគេ មានចម្ងាយឆ្ងាយជាងមុន។

## ២.៣.៦ ផលប៉ះពាល់សង្គម និង បរិស្ថាន

កៅសិបប្រាំបីភាគរយនៃគ្រួសារដែលបានតាំងទីលំនៅថ្មី បានឆ្លើយតបនឹងការស្ទង់មតិនេះ បាននិយាយថា ពួកគេអាចបន្តអនុវត្តសាសនារបស់ពួកគេបានដោយបើកចំហរ និង ដោយសេរី។ នេះរួមទាំងគ្រួសារជនជាតិដើមភាគតិចទាំងអស់ផងដែរ។

យោងតាមអាជ្ញាធរមូលដ្ឋាន និង អ្នកដឹកនាំសហគមន៍ មានជម្លោះបន្តិចបន្តួចរវាងអ្នកភូមិជាម្ចាស់ទីតាំង ដែលរស់នៅទីនោះស្រាប់ និង គ្រួសារដែលបានតាំងទីលំនៅថ្មី នៅកន្លែងតាំងទីលំនៅថ្មីចំនួនបួនកន្លែង។ នៅស្រះពោធិ៍ (ខេត្តកណ្តាល) ជម្លោះបណ្តាលមកពីមិនទុកចិត្តគ្នា ដោយសារតែគ្រួសារដែលបានតាំងទីលំនៅថ្មី ទើបតែមកនៅថ្មី។ នៅកន្លែងបីផ្សេងទៀត ជម្លោះបណ្តាលមកពីការបែងចែកដីធ្លី។ នៅអូរបាត់មាន់ (ខេត្ត ឧត្តរមានជ័យ) បានរាយការណ៍ថា គ្រួសារដែលបានតាំងទីលំនៅថ្មី ប៉ុនប៉ងយកដីធ្លីច្រើនជាងដីធ្លីដែលត្រូវបានបែងចែកសម្រាប់ពួកគេ។ នៅពីស (ខេត្តកំពង់ស្ពឺ) និង ព្រែកស្មាច់ (ខេត្តកោះកុង) លំនៅឋានដែលមានស្រាប់នៅក្នុងភូមិនោះ មានកម្មសិទ្ធិលើដីធ្លីដែលត្រូវបានបែងចែកជូនគ្រួសារដែលបានតាំងទីលំនៅថ្មីរួចទៅហើយ។ នៅព្រែកកូនសេក (ខេត្តបាត់ដំបង) ការប្រើប្រាស់គ្រឿងញៀនដោយប្រជាពលរដ្ឋនៅកន្លែងតាំងទីលំនៅថ្មីគឺជាកង្វល់មួយ។ ជាអកុសលមិនមានព័ត៌មានត្រូវបានផ្តល់ឱ្យដឹង អំពីបញ្ហាដែលបានកើតឡើង និង ថាតើអាជ្ញាធរកំពុងដោះស្រាយដោយរបៀបណានោះទេ។ ជនជាតិដើមភាគតិចគ្រប់រូបនៅកន្លែងតាំង ទីលំនៅថ្មីស្រែស្រណុកថ្មី និង ជនជាតិដើមភាគតិចចំនួន ៧៦ ភាគរយនៅ (ក្បាលរមាសថ្មី និង ស្រែស្រណុកថ្មី នៅក្នុងខេត្តស្ទឹងត្រែង) បាននិយាយថា ពួកគេអាចបន្តរបៀបរស់នៅរបស់ពួកគេបាន។ ២៤ ភាគរយដែលមកពីក្បាលរមាសថ្មីបាននិយាយថា ពួកគេមិនអាចបន្តរបៀបរស់នៅរបស់ពួកគេបាននោះទេ។ រូបភាពទី១៧ ខាងក្រោម បង្ហាញសេចក្តីអធិប្បាយអំពីមូលហេតុដែលពួកគេមានអារម្មណ៍ថា ពួកគេអាចបន្តរបៀបរស់នៅតាមបែបប្រពៃណីរបស់ពួកគេបាន និង រូបភាពទី១៨ ខាងក្រោម បង្ហាញសេចក្តីអធិប្បាយអំពីមូលហេតុដែលពួកគេមានអារម្មណ៍ថា ពួកគេមិនអាចបន្តរបៀបរស់នៅតាមបែបប្រពៃណីរបស់ពួកគេបាននោះទេ។



ផ្ទះដែលសាងសង់លើដីដែលបានផ្តល់ជូនមានទីតាំងនៅក្នុងភូមិស្រះពោធិ ឃុំភ្នំបាត ស្រុកពញាឮ, ខេត្តកណ្តាល។ រូបថត ៖ CUFA

## រូបភាពទី១៧៖ ភាគរយនៃមូលហេតុថាហេតុអ្វីបានជាអ្នកឆ្លើយតបអាចបន្តរបៀបរស់នៅតាមបែបប្រពៃណីបាន




## រូបភាពទី១៨៖ ភាគរយនៃមូលហេតុដែលមិនអាចបន្តរបៀបរស់នៅតាមបែបប្រពៃណីបាន (ក្បាលរមាសថ្មី ស្ទឹងត្រែង)






ផ្ទះនៅក្នុងសហគមន៍អភិវឌ្ឍន៍ដីថ្មីមានទីតាំងនៅក្នុងភូមិ១ ឃុំ១, ស្រុកឃ្លាំងលើ, ខេត្តព្រះសីហនុ។ រូបថត ៖ CUFA



ផ្លូវចូលផ្ទះមួយកន្លែងនៅក្នុងភូមិព្រែកកូនសេក, សង្កាត់អូចារ ក្រុងបាត់ដំបង, ខេត្តបាត់ដំបង។ រូបថត ៖ CUFA

# ជំពូក

# ៣

# សេចក្ដីសន្និដ្ឋាន និង អនុសាសន៍

# ជំពូក ៣៖ សេចក្តីសន្និដ្ឋាន និង អនុសាសន៍

## ប្រវ៉ាទ្បង់នៃការបណ្តេញចេញដោយបង្ខំ

### ក្របខណ្ឌច្បាប់

១. ពុំទាន់មានគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីការតាំងទីលំនៅថ្មីនៅឡើយទេ នៅពេលដែលការផ្លាស់ទីលំនៅ បណ្តាលមកពីសម្បទានដីសេដ្ឋកិច្ច និង គម្រោងអភិវឌ្ឍន៍ដែលផ្តល់មូលនិធិដោយផ្នែកឯកជន។

*អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា៖*

១.១. នៅខណៈពេលដែលច្បាប់ និង គោលនយោបាយជាតិចាំបាច់ត្រូវធ្វើការពិនិត្យឡើងវិញ ដើម្បីធានាបាននូវការអនុលោមតាមបទដ្ឋាន និង ស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ ក្របខណ្ឌដែលមានស្រាប់គួរត្រូវបានអនុវត្តយ៉ាងតឹងរ៉ឹងដោយអាជ្ញាធរពាក់ព័ន្ធទាំងអស់ រួមជាមួយកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិដែលបានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជា។

១.២. រដ្ឋាភិបាលគប្បីអនុម័ត និង អនុវត្តសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការតាំងទីលំនៅថ្មីដែលបានភ្ជាប់មកជាមួយជាឧបសម្ព័ន្ធនៃការសិក្សានេះ ដែលអនុវត្តចំពោះគ្រប់គម្រោងអភិវឌ្ឍន៍ទាំងអស់នៅក្នុងប្រទេសកម្ពុជា ទោះបីជាទទួលបានមូលនិធិពីខាងក្រៅ ឬនៅក្នុងប្រទេស។

### ការហាមឃាត់ការបណ្តេញចេញដោយបង្ខំ

២. ការផ្លាស់ទីលំនៅភាគច្រើនដែលបានកើតឡើង គឺជាការបណ្តេញចេញដោយបង្ខំ គ្រួសារដែលបានតាំងទីលំនៅថ្មីបានប្រឈមមុខនឹងការបង្ខិតបង្ខំ និង គំរាមកំហែង មុនពេល ក្នុងអំឡុងពេល និង ក្រោយពេលបណ្តេញចេញ ហើយមិនត្រូវបានផ្តល់ការជូនដំណឹងគ្រប់គ្រាន់អំពីការផ្លាស់ទីលំនៅដូច្នេះពួកគេពុំមានពេលវេលាគ្រប់គ្រាន់សម្រាប់រៀបចំផែនការ និង ត្រៀមខ្លួនសម្រាប់ការផ្លាស់ទីលំនៅនោះ។

*អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា៖*

២.១. រដ្ឋាភិបាលគប្បីធានាថា ពុំមានការបណ្តេញចេញដោយបង្ខំត្រូវបានអនុវត្ត ដោយមិនគិតអំពីកម្មសិទ្ធិ ឬ ស្ថានភាពនៃការកាន់កាប់របស់ជនដែលរងផលប៉ះពាល់នោះទេ។ ការបណ្តេញចេញអាចកើតឡើងបានតែក្នុងករណីកាលៈទេសៈពិសេសប៉ុណ្ណោះ ដែលតម្រូវឱ្យមានការធ្វើយុត្តិកម្មយ៉ាងពេញលេញ ដូចបានកំណត់នៅក្នុងច្បាប់សិទ្ធិមនុស្ស និងច្បាប់ជាតិនៃប្រទេសកម្ពុជា ។

## មុននឹងធ្វើការបណ្តេញចេញ

### ដំណើរការនៃការសម្រេចចិត្ត

៣. គ្រួសារទាំងឡាយមិនបានចូលរួមនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ឱ្យបានត្រឹមត្រូវមុនពេលតាំងទីលំនៅថ្មីនោះទេ។

*អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា៖*

៣.១. នៅពេលដែលចាំបាច់មានការតាំងទីលំនៅថ្មី អាជ្ញាធរពាក់ព័ន្ធត្រូវតែបង្ហាញយ៉ាងច្បាស់ថា ការបណ្តេញចេញគឺមិនអាចជៀសវាងបាន និង បង្ហាញការប្តេជ្ញាចិត្តស្របតាមសិទ្ធិមនុស្សអន្តរជាតិ។

៣.២. អាជ្ញាធរពាក់ព័ន្ធគប្បីធានាថា ដំណើរការនៃការតាំងទីលំនៅថ្មីទាំងមូលគួរធ្វើឡើងដោយមានការចូលរួមពេញលេញពីបុគ្គលដែលរងផលប៉ះពាល់ រួមមាន ស្ត្រី បុរស និង មនុស្សភេទទីបី ក្រុម និង សហគមន៍ផងដែរ។ គោលការណ៍នៃការយល់ព្រមជាមុន ដោយសេរី និង ជូនដំណឹងអោយបានគ្រប់គ្រាន់ គប្បីត្រូវបានអនុវត្តនៅក្នុងដំណើរការធ្វើការសម្រេចចិត្ត។

៣.៣. អាជ្ញាធរពាក់ព័ន្ធគប្បីរៀបចំកិច្ចប្រជុំពិគ្រោះយោបល់យ៉ាងហោចណាស់ចំនួនបីដង មុនពេលបណ្តេញចេញ ដើម្បីអោយគ្រួសារដែលរងផលប៉ះពាល់មានពេលវេលា និង ឱកាសគ្រប់គ្រាន់នៅក្នុងលើកឡើងអំពីកង្វល់របស់ពួកគេ និង ស្នើផែនការជំនួស។ ស្ត្រី បុរស អ្នកស្រលាញ់ភេទដូចគ្នា និង មនុស្សភេទទីបីផ្សេងទៀត រួមទាំង ជនជាតិដើមភាគតិច ជនជាតិភាគតិច ជនគ្មានដីធ្លី ជនពិការ និង ស្ត្រីផ្ទុកមេរោគអេដស៍ និង កុមារ គប្បីត្រូវបានតំណាង និង បានរួមបញ្ចូលនៅក្នុងដំណើរការនេះ។ កិច្ចប្រជុំដែលជាប់ពាក់ព័ន្ធនឹងជនជាតិដើមភាគតិច និង ជនជាតិភាគតិចគប្បីត្រូវបានធ្វើឡើងជាភាសារបស់ពួកគេ ដើម្បីធានាថាពួកគេយល់យ៉ាងច្បាស់អំពីនីតិវិធីនេះ។

៣.៤. ប្រសិនបើអាចធ្វើទៅបាន អាជ្ញាធរពាក់ព័ន្ធគប្បីពិចារណា និង អនុម័តផែនការជំនួសដែលត្រូវបានស្នើឡើងដោយបុគ្គល ក្រុម និង សហគមន៍ដែលរងផលប៉ះពាល់។ បុគ្គលដែលរងផលប៉ះពាល់ត្រូវតែអាចមានឥទ្ធិពលដល់លទ្ធផលនៃដំណើរការ ធ្វើការសម្រេចចិត្ត ដោយផ្អែកលើការដឹងអំពីសិទ្ធិរបស់ពួកគេ។

៣.៥. អាជ្ញាធរពាក់ព័ន្ធគួរតែពិគ្រោះយោបល់ជាមួយសហគមន៍ដែលជាម្ចាស់ទីកន្លែងផងដែរ ដើម្បីកំណត់ថាតើពួកគេនឹងទទួលយកគ្រួសារដែលបានតាំងទីលំនៅថ្មី ដែរឬទេ។

៤. អាជ្ញាធរមូលដ្ឋាន និង អ្នកដឹកនាំសហគមន៍មិនមិនជាប់ពាក់ព័ន្ធក្នុងការសម្រេចចិត្តថាតើកន្លែងតាំងទីលំនៅថ្មីគួរស្ថិតនៅកន្លែងណានោះទេ។

*អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា៖*

៤.១. អាជ្ញាធរថ្នាក់ជាតិ និង ថ្នាក់ខេត្ត គប្បីបញ្ចូលអាជ្ញាធរមូលដ្ឋានដែលទទួលខុសត្រូវចំពោះភូមិ ឃុំ និង ស្រុក នៅក្នុងដំណើរការធ្វើការសម្រេចចិត្តអំពីទីតាំងនៃទីកន្លែងទាំងនោះ។ ការធ្វើបែបនេះនឹងធានាថា តំបន់ដែលបានស្នើឡើងសម្រាប់ទីកន្លែងទាំងនោះមិនរំលោភបំពានលើដីដែលបានកាន់កាប់រួចហើយ និង អនុញ្ញាតឱ្យអាជ្ញាធរមូលដ្ឋានអាចរៀបចំសម្រាប់ការមកដល់របស់គ្រួសារដែលបានតាំងទីលំនៅថ្មី និង ការពារជម្លោះរវាងសហគមន៍ជាម្ចាស់ និង គ្រួសារដែលបានតាំងទីលំនៅថ្មី។

## សេចក្តីជូនដំណឹងអំពីការបណ្តេញចេញ

៥. គ្រួសារមួយចំនួនមិនបានទទួលការជូនដំណឹងគ្រប់គ្រាន់ មុនពេលមានការបណ្តេញចេញ។

*អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា៖*

៥.១. អាជ្ញាធរពាក់ព័ន្ធគប្បីប្រកាសអំពីសេចក្តីសម្រេចស្តីពីការបណ្តេញចេញជាមុន និង ជាលាយលក្ខណ៍អក្សរ ជាភាសាខ្មែរ និង ជាភាសាជនជាតិដើមភាគតិច ដល់បុគ្គលទាំងអស់ដែលពាក់ព័ន្ធ។ ការជូនដំណឹងអំពីការបណ្តេញចេញ គួរមានមូលហេតុសមស្របយ៉ាងលម្អិតសម្រាប់ការសម្រេចចិត្ត ដែលរួមមាន៖

៥.១.១. មានហេតុផលសមរម្យ ចំពោះការបដិសេធនូវជម្រើសជំនួស

៥.១.២. ព័ត៌មានលម្អិតយ៉ាងពេញលេញអំពីជម្រើសជំនួសដែលត្រូវបានស្នើឡើង និង

៥.១.៣. ប្រសិនបើគ្មានជម្រើសជំនួសទេនោះ អនុវត្ត និង ប្រមើលមើលគ្រប់វិធានការទាំងអស់ ដើម្បីកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់អវិជ្ជមាននៃការបណ្តេញចេញ។

៥.២. អាជ្ញាធរពាក់ព័ន្ធគប្បីធានាថា ការជូនដំណឹងបានផ្តល់ពេលវេលាគ្រប់គ្រាន់ដល់គ្រួសារទាំងនោះដែលត្រូវបណ្តេញចេញ ដើម្បីបង្កើតបញ្ជីសារពើភ័ណ្ឌ និង ប៉ាន់ប្រមាណអំពីតម្លៃនៃទ្រព្យសម្បត្តិ ការវិនិយោគ និង ទំនិញសំខាន់ៗដទៃទៀត ដែលអាចរងការខូចខាត។ គ្រួសារដែលនឹងត្រូវបណ្តេញចេញគប្បីត្រូវបានផ្តល់ឱកាសធ្វើការវាយតម្លៃ និង កត់ត្រាឯកសារការខាតបង់ដែលមិនមែនជាទឹកប្រាក់ដើម្បីផ្តល់ជាសំណង។

៥.៣. អាជ្ញាធរពាក់ព័ន្ធគប្បីធានាថា រាល់ការសម្រេចចិត្តចុងក្រោយ គឺស្ថិតក្រោមការត្រួតពិនិត្យផ្នែករដ្ឋបាល និង តុលាការ។ ភាគីដែលរងផលប៉ះពាល់ក៏ត្រូវតែទទួលបានការធានាថានឹងទទួលបានការប្រឹក្សាផ្នែកច្បាប់យ៉ាងទាន់ពេលវេលាដោយឥតគិតថ្លៃប្រសិនបើចាំបាច់។ បន្ទាប់ពីមានការពិគ្រោះយោបល់ជាសាធារណៈយ៉ាងពេញលេញ និង យុត្តិធម៌ហើយ ការតាំងទីលំនៅថ្មី នឹងចាប់ផ្តើម ដំណើរការបុគ្គល ក្រុម និង សហគមន៍ដែលរងផលប៉ះពាល់ត្រូវទទួលបានសេចក្តីជូនដំណឹងយ៉ាងតិច ៩០ ថ្ងៃមុនកាលបរិច្ឆេទនៃការតាំងទីលំនៅថ្មី។

# លក្ខខណ្ឌតម្រូវសម្រាប់កន្លែងតាំងទីលំនៅថ្មី

៦. កន្លែងតាំងទីលំនៅថ្មីមិនបានត្រៀមរួចរាល់សម្រាប់អ្នកដែលត្រូវបានបណ្តេញចេញ ហើយសេវាមូលដ្ឋានមិនត្រូវបានផ្តល់នៅពេលទៅដល់ជាពិសេសការផ្តល់ជូនទឹកពិសារ ផ្លូវថ្នល់ សន្តិសុខស្បៀង ប្រភពថាមពល អនាម័យ សេវាសុខាភិបាល និង ការអប់រំ។

*អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា៖*

៦.១. អាជ្ញាធរពាក់ព័ន្ធគប្បីធានាថា រួមជាមួយលក្ខខណ្ឌតម្រូវនៃការជូនដំណឹងយ៉ាងត្រឹមត្រូវ និងទាន់ពេលវេលា មិនត្រូវមានការបណ្តេញចេញ ឬ ការផ្លាស់ទីលំនៅណាមួយឡើយលុះត្រាតែ និងរហូតទាល់តែ កន្លែងតាំងទីលំនៅថ្មីត្រូវបានរៀបចំ និងរួចរាល់សម្រាប់ការមកដល់របស់គ្រួសារដែលបានតាំងទីលំនៅថ្មី។ កន្លែងតាំងទីលំនៅថ្មីគប្បីនៅជិតទីតាំងចាស់បំផុតតាមដែលអាចធ្វើទៅបាន ជិតសាលារៀន ជិតមណ្ឌលសុខភាព និងជិតកន្លែងដែលមានឱកាសការងារ។

៦.២. អាជ្ញាធរពាក់ព័ន្ធគប្បីធានាថា លំនៅឋានសមរម្យត្រូវបានផ្តល់ជូន ដើម្បីការពារគ្រួសារដែលបានតាំងទីលំនៅថ្មីពីជំងឺ អាកាសធាតុមិនល្អ និង ស្ថានភាពផ្សេងទៀត។

៦.៣. អាជ្ញាធរពាក់ព័ន្ធគប្បីធានាថា មុនពេលតាំងទីលំនៅថ្មី សេវាមូលដ្ឋានត្រូវបានបង្កើតឡើងនៅកន្លែងតាំងទីលំនៅថ្មី ដែលរួមមាន ភាពអាចទទួលបានសេវាកម្ម សម្ភារៈ អាគារ ឬកន្លែងផ្តល់សេវា និង ហេដ្ឋារចនាសម្ព័ន្ធ ដូចជា៖

- ៦.៣.១. ទឹកពិសារមានសុវត្ថិភាព (ទឹកស្អាត)
- ៦.៣.២. ថាមពលគ្រប់គ្រាន់សម្រាប់ចម្អិនម្ហូបអាហារ ប្រព័ន្ធកម្តៅ និង ឧបករណ៍សម្រាប់បំភ្លឺ
- ៦.៣.៣. អនាម័យ និង កន្លែងលាងសម្អាត
- ៦.៣.៤. មធ្យោបាយរក្សាទុកស្បៀងអាហារ
- ៦.៣.៥. កន្លែងចាក់កាកសំណល់
- ៦.៣.៦. ប្រព័ន្ធបង្ហូរទឹកនៅលើទីតាំង
- ៦.៣.៧. សេវាសង្គ្រោះបន្ទាន់ និង
- ៦.៣.៨. ការទទួលបានធនធានធម្មជាតិ និង ធនធានទូទៅ ប្រសិនបើសមស្រប

៦.៤. អាជ្ញាធរពាក់ព័ន្ធគិតគូរពីតម្រូវការក្នុងការផ្តល់លំនៅឋាន ដែលមានលក្ខណៈសមស្របតាម ផ្នែកវប្បធម៌ ជាពិសេសសម្រាប់ជនជាតិដើមភាគតិច និង ជាតិពន្ធភាគតិច ឧទាហរណ៍ ពាក់ព័ន្ធនឹងទំហំផ្ទះសម្រាប់គ្រួសារធំ និង ទីតាំងដែលអនុញ្ញាតឱ្យមានការថែរក្សារបៀបរស់នៅតាមបែបប្រពៃណីជាដើម។

# ក្រោយពេលបណ្តេញចេញ

## សំណង

៧. មិនមែនគ្រប់ក្រុមគ្រួសារទាំងអស់សុទ្ធតែពេញចិត្តនឹងផ្ទះ និង សម្ភារៈប្រើប្រាស់ក្នុងផ្ទះដែលពួកគេបានទទួលជាសំណងនោះទេ។ គ្រួសារជនជាតិដើមភាគតិចមួយចំនួនមានអារម្មណ៍ថា សំណងសម្រាប់ទីតាំងវប្បធម៌របស់ពួកគេ (ដីធ្លី និង ជំនួយកហិរញ្ញវត្ថុ) គឺមិនយុត្តិធម៌ និង មិនសុក្រឹតនោះទេ។

*អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា៖*

៧.១. អាជ្ញាធរពាក់ព័ន្ធគប្បីធានាថា សំណងសមរម្យ និងយុត្តិធម៌ ត្រូវបានផ្តល់ជូនភ្លាមៗនៅពេលមានការបណ្តេញចេញ សម្រាប់ការខាតបង់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន និង ទំនិញផ្សេងៗទៀត។ សំណងគប្បីផ្តល់ជូនសម្រាប់ការខូចខាតដែលអាចប៉ាន់ប្រមាណបានតាមបែបសេដ្ឋកិច្ច ដូចជា៖

- ៧.១.១. ការបាត់បង់ជីវិត ឬ អវយវៈ
- ៧.១.២. ការប៉ះទង្គិចផ្លូវកាយ ឬ ផ្លូវចិត្ត
- ៧.១.៣. ការបាត់បង់ឱកាស រួមទាំង ការងារ ការអប់រំ និង អត្ថប្រយោជន៍សង្គម
- ៧.១.៤. ការខូចខាតធ្ងន់ធ្ងរ និង ការបាត់បង់ប្រាក់ចំណូល រួមទាំង ការបាត់បង់សក្តានុពលក្នុងការស្វែងរកប្រាក់ចំណូល
- ៧.១.៥. ការខូចខាតផ្នែកសីលធម៌ និង
- ៧.១.៦. សោហ៊ុយដែលចាំបាច់សម្រាប់ជំនួយផ្នែកច្បាប់ ឬអ្នកជំនាញ ឱសថ និង ការព្យាបាលជំងឺ និង សេវាចិត្តសាស្ត្រ និង សង្គមកិច្ច។

៧.២. អាជ្ញាធរពាក់ព័ន្ធគប្បីពិចារណាថា សំណងជាសាច់ប្រាក់មិនគួរជំនួសឱ្យសំណងជាក់ស្តែងនៅក្នុងទម្រង់ជាដីធ្លី និង ធនធានទ្រព្យសម្បត្តិរួមនោះទេ។ នៅពេលដែលមានការយកដីធ្លី ជនដែលត្រូវគេបណ្តេញចេញ គួរទទួលបានសំណងជាដីធ្លីដែលមានគុណភាព ទំហំ និង តម្លៃសមមាត្រគ្នា ឬ ប្រសើរជាងមុន។

៧.៣. អាជ្ញាធរពាក់ព័ន្ធគប្បីចងចាំថា ជនដែលត្រូវគេបណ្តេញចេញទាំងអស់មានសិទ្ធិទទួលបានសំណងសម្រាប់ការខាតបង់ ទ្រព្យសង្គ្រោះ និង ការដឹកជញ្ជូនទ្រព្យសម្បត្តិរបស់ពួកគេ ដែលបានទទួលរងផលប៉ះពាល់រួមទាំង លំនៅឋាន និង ដីធ្លីស្រែចំការ ដែលត្រូវបានបាត់បង់ ឬ រងការខូចខាតនៅក្នុងដំណើរការនេះ។

៧.៤. អាជ្ញាធរពាក់ព័ន្ធគប្បីធ្វើការវាយតម្លៃឡើងវិញអំពីស្ថានភាពរស់នៅ ក្នុងតំបន់ផ្លាស់ទីលំនៅ ដែលមានស្រាប់ ដោយយកចិត្តទុកដាក់ជាពិសេសលើទីតាំងដែលត្រូវបានរកឃើញថាមានបញ្ហា យោងតាមការសិក្សានេះ។ បន្ទាប់មកអាជ្ញាធរពាក់ព័ន្ធគប្បីចាត់វិធានការកែតម្រូវដើម្បីកែលម្អស្ថានភាពរស់នៅ និង ផ្តល់ឧបាស្រ័យដល់គ្រួសារដែលរងផលប៉ះពាល់ដោយសារ ស្តង់ដាររស់នៅមិនសមរម្យ។

៧.៥. អាជ្ញាធរពាក់ព័ន្ធគប្បីធានាថា ការថែទាំផ្នែកវេជ្ជសាស្ត្រសមស្រប រួមទាំង សេវាចិត្តសាស្ត្រ និងសង្គម ត្រូវបានផ្តល់ជូនជនដែលត្រូវគេបណ្តេញចេញ ដែលបានរងរបួស ឈឺ ពិការ ឬ បានទទួលរងការប៉ះទង្គិចផ្លូវចិត្តយ៉ាងខ្លាំង ក្នុងអំឡុងពេលបណ្តេញចេញ។ តម្រូវការពិសេសៗរបស់ស្ត្រី កុមារ ជនពិការ និង អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ គួរត្រូវបានដោះស្រាយ។ ការបណ្តេញចេញមិនគួរបង្កការរំខានដល់ការព្យាបាលជំងឺរបស់បុគ្គលណាម្នាក់ឡើយ។

៧.៦. អាជ្ញាធរពាក់ព័ន្ធគប្បីគោរពសិទ្ធិរបស់អ្នកដែលត្រូវបានបណ្តេញចេញទាំងអស់ និង អ្នកដែលប្រឈមនឹងការបណ្តេញចេញ ដើម្បីមានលទ្ធភាពទទួលបានដំណោះស្រាយទាន់ពេលវេលា។ ដំណោះស្រាយដែលសមស្របរួមមាន៖

- ៧.៦.១. សវនាកា យុត្តិធម៌
- ៧.៦.២. ការទទួលបានជំនួយផ្នែកច្បាប់
- ៧.៦.៣. សំណង
- ៧.៦.៤. បដិទាន និង ការវិលត្រឡប់មកវិញ និង
- ៧.៦.៥. ការតាំងទីលំនៅថ្មី។

*អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា សង្គមស៊ីវិល និង សហគមន៍អន្តរជាតិ និងសហគ្រាសពាណិជ្ជកម្ម៖*

៧.៧. ការសិក្សាបន្ថែមគប្បីត្រូវបានធ្វើឡើង ថាតើគ្រួសារដែលបានតាំងទីលំនៅថ្មីបានទទួលសំណងយ៉ាងជាក់ស្តែងសម្រាប់ការរងរបួសណាមួយ (ទាំងផ្លូវកាយ និង ផ្លូវចិត្ត) ដែលបានអូសបន្លាយដោយសារតែការផ្លាស់ទីលំនៅ ការបាត់បង់ឱកាសស្វែងរកប្រាក់ចំណូល និង អត្ថប្រយោជន៍សង្គម និង ការបាត់បង់ប្រាក់ចំណូលក្រោមស្តង់ដារអន្តរជាតិ។ [19]

៧.៨. គោរពតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស ដើម្បីពង្រឹងការការពារប្រឆាំងនឹងការរំលោភបំពានសិទ្ធិមនុស្ស ទាក់ទងនឹងធុរកិច្ច។

## សុវត្ថិភាពនៃការកាន់កាប់

៨. ស្ទើរតែពាក់កណ្តាលនៃគ្រួសារ មិនបានទទួលប័ណ្ណកម្មសិទ្ធិលើដីរបស់ពួកគេទេ។ អ្នកឆ្លើយតបបានប្រើប្រាស់ទម្រង់ឯកសារផ្សេងៗដើម្បីបញ្ជាក់អំពីភាពជាម្ចាស់ ដែលមិនបានផ្តល់ជូនពួកគេនូវសុវត្ថិភាពនៃការកាន់កាប់ដែលត្រូវបានតម្រូវ ហើយប្រហែលជាមិនត្រូវបានទទួលស្គាល់ដោយតុលាការ ឬ គណៈកម្មការសុរិយោដី ប្រសិនបើមានវិវាទលើកម្មសិទ្ធិកើតឡើង។ ពុំមានច្បាប់ ឬ អនុក្រឹត្យដែលកំណត់អំពីរយៈពេលសម្រាប់ប្រជាពលរដ្ឋ ក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិបន្ទាប់មានការផ្លាស់ទីលំនៅនោះទេ ហើយមានគ្រួសារដែលបាន និងកំពុងតែរស់នៅលើទីតាំងទាំងនេះអស់រយៈពេលជាងដប់ឆ្នាំមកហើយ មិនទាន់ទទួលបានប័ណ្ណកម្មសិទ្ធិនៅឡើយ។

*អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា៖*

៨.១. គណៈកម្មការសុរិយោដីគប្បីផ្តល់អាទិភាពដល់គ្រួសារដែលបានផ្លាស់ទីលំនៅថ្មី ដែលបាន និង កំពុងរស់នៅលើទីតាំងទាំងនោះអស់រយៈពេលលើសពី ៥ ឆ្នាំ នៅក្នុងការដាក់ពាក្យស្នើសុំ និងទទួលបានប័ណ្ណកម្មសិទ្ធិ។ អាជ្ញាធរមូលដ្ឋានគប្បីធ្វើការស្ទង់មតិលើគ្រួសារដែលបានផ្លាស់ទីលំនៅថ្មី ដើម្បីកំណត់អ្នកដែលមានសិទ្ធិទទួលបានប័ណ្ណកម្មសិទ្ធិ និង ផ្តល់ការគាំទ្រដល់ការដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិរបស់ពួកគេ។

៨.២. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គប្បីបង្កើតរយៈពេលស្តង់ដារសម្រាប់គ្រួសារដែលបានតាំងទីលំនៅថ្មី មានសិទ្ធិដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិបន្ទាប់ពីបានស្នាក់នៅជាបន្តបន្ទាប់នៅក្នុងកន្លែងតាំងទីលំនៅថ្មីរយៈពេល៥ឆ្នាំ។ “ការស្នាក់នៅជាបន្តបន្ទាប់” គប្បីពិចារណាអំពីការកែលម្អលំនៅឋាន និងដីធ្លីដែលត្រូវបានផ្តល់ជូន និងមិនត្រូវផ្តោតលើតែមានវត្តមានរបស់សមាជិកគ្រួសារដែលបានតាំងទីលំនៅថ្មីនោះទេ។

៨.៣. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រួមជាមួយអាជ្ញាធរពាក់ព័ន្ធ គួរតែរៀបចំនីតិវិធីក្នុងការចុះបញ្ជី និងធ្វើប័ណ្ណកម្មសិទ្ធិជាប្រព័ន្ធសំរាប់គ្រួសារដែលបានតាំងទីលំនៅថ្មី ក្នុងរយៈពេលដែលសមរម្យ និងស្របគ្នាចាប់ពីថ្ងៃផ្លាស់ទីលំនៅថ្មី។

៩. អាជ្ញាធរមូលដ្ឋានបានផ្តល់សេវារដ្ឋបាលល្អៗដល់គ្រួសារដែលបានតាំងទីលំនៅថ្មី ដោយគ្រួសារស្ទើរតែទាំងអស់បានរាយការណ៍ថាបានទទួលសៀវភៅគ្រួសារ សំបុត្រកំណើត ឯកសារទទួលស្គាល់កម្មសិទ្ធិ និង ឯកសារផ្សេងៗទៀត ដោយគ្មានការបង់ថ្លៃលើស។

---

19 UN OHCHR (បោះពុម្ពឡើងវិញ ឆ្នាំ ២០១៣). កថាខណ្ឌទី ៦០ ទំព័រទី ៤១ https://cambodia.ohchr.org/sites/default/files/Softlaw/UN percent20Commentary-A5-En_0.pdf បានចូលប្រើប្រាស់នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០។

# លទ្ធភាពក្នុងការទទួលបានសេវាមូលដ្ឋាន

## ផ្ទះ ផ្លូវថ្នល់ និង ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបង្ហូរទឹក

១០. ប្រទេសកម្ពុជាមិនទាន់មានកំណត់អំពីទំហំស្តង់ដារសម្រាប់លំនៅឋាននោះទេ។ មិនទាន់អាចធ្វើការសេចក្តីសន្និដ្ឋានបានថាតើទំហំផ្ទះដែលអ្នកឆ្លើយតបកាន់កាប់នាពេលបច្ចុប្បន្នមានភាពសមរម្យដែរឬទេ ពីព្រោះពុំមានព័ត៌មានអំពីចំនួនសមាជិកគ្រួសារដែលរស់នៅក្នុងផ្ទះនោះនៅឡើយទេ។

អ្នកឆ្លើយតបស្ទើរតែទាំងអស់បានរាយការណ៍ថា ដំបូល និង ជញ្ជាំងរបស់ពួកគេមានសភាពមធ្យម ដោយគ្រួសារភាគច្រើនប្រើស័ង្កសី/លោហៈសម្រាប់លំនៅឋាន និង ឈើ ឬ ថ្មសម្រាប់ជញ្ជាំង។ ទោះបីជាយ៉ាងណាក៏ដោយ ទិដ្ឋភាពមួយចំនួនផ្សេងទៀតនៃលំនៅឋានសមរម្យមិនត្រូវបានបំពេញតាមនោះទេ ឧទាហរណ៍៖ អនាម័យ ទឹកពិសារ ថាមពល ភ្លើងបំភ្លឺយ៉ាងសមរម្យ និង ការការពារពីគ្រោះធម្មជាតិ។

១១. ស្ថានភាពផ្លូវថ្នល់នៅក្នុងទីតាំង ព្រមទាំងទៅ និង មកពីទីតាំង ត្រូវបានចាត់ទុកថា "មធ្យម" ដូច្នេះវាហាក់បីដូចជាបានបំពេញតាមស្តង់ដារនៃភាពសមរម្យ។

១២. មានកង្វះខាតប្រព័ន្ធបង្ហូរទឹកនៅកន្លែងតាំងទីលំនៅថ្មីមួយចំនួន។

## សិទ្ធិទទួលបានស្បៀងអាហារ

១៣. សិទ្ធិទទួលបានស្បៀងអាហារមិនត្រូវបានទទួលស្គាល់យ៉ាងពេញលេញនោះទេ គ្រួសារមួយចំនួនមិនបានទទួលស្បៀងអាហារសមរម្យ និង គ្រួសារប្រហែលមួយភាគបួនទទួលបានស្បៀងអាហារមិនបានគ្រប់គ្រាន់នោះទេ។ គ្រួសារមួយចំនួនខ្វះខាតទាំងការទទួលបានស្បៀងអាហារ និងការទទួលបានស្បៀងអាហារគ្រប់គ្រាន់។

១៤. មានវិសមភាពយេនឌ័រនៅពេលនិយាយដល់ ថាតើអ្នកណា នៅក្នុងគ្រួសារ ជាអ្នកទទួលខុសត្រូវ ទិញស្បៀងអាហារ គ្រួសារស្ទើរតែទាំងអស់បានឆ្លើយថា ស្ត្រីជាអ្នកទទួលខុសត្រូវទិញស្បៀងអាហារ។ ចំណុចនេះអាចធ្វើឱ្យស្ត្រីមានការចាញ់ប្រៀប ដោយសារតែស្ត្រី តាមធម្មតា ជាមនុស្សដំបូងដែលលះបង់ការទទួលទានអាហាររបស់ពួកគេផ្ទាល់ ដើម្បីធានាថាគ្រួសាររបស់ពួកគេមានស្បៀងអាហារគ្រប់គ្រាន់។

## សេវាសាធារណៈ (ទឹក ថាមពលសម្រាប់បំភ្លឺ/អគ្គិសនី អនាម័យ)

១៥. សិទ្ធិទទួលបានទឹក មិនត្រូវបានទទួលស្គាល់យ៉ាងពេញលេញនោះទេ គ្រួសារប្រហែលមួយភាគបួនមិនអាចប្រើប្រាស់ទឹកដែលពួកគេទទួលបាន សម្រាប់ពិសារ និង ចម្អិនម្ហូបអាហារបាននោះទេ ពីព្រោះទឹកទាំងនោះមានដី និង/ឬ សំរាមជាច្រើន។ ចំណុចនេះបង្កើតវិសមាមាត្រនៃបន្ទុករបស់ស្ត្រី ដែលជាអ្នកមើលថែទាំចម្បងនៅក្នុងផ្ទះ ទទួលខុសត្រូវលើការចម្អិនម្ហូបអាហារ និង ការបោសសម្អាត។

១៦. គ្រួសារមួយចំនួនគ្មានអគ្គិសនីសម្រាប់ប្រើប្រាស់នោះទេ និង បានប្រើប្រាស់ចង្កៀងប្រេងកាត និង ឥន្ធនៈសម្រាប់បំភ្លឺ។

១៧. សិទ្ធិទទួលបានអនាម័យមិនត្រូវបានទទួលស្គាល់យ៉ាងពេញលេញនោះទេ គ្រួសារដែលប្រើប្រាស់បង្គន់រណ្តៅ បាននិយាយថាបង្គន់ទាំងនោះ "មិនដំណើរការនោះទេ" ហើយពួកគេគ្មានផាសុកភាពក្នុងការប្រើប្រាស់បង្គន់ទាំងនោះទេ មួយផ្នែក ដោយសារតែកង្វះភាពឯកជន រួមទាំងដោយសារ ការមករដូវ និង អនាម័យផងដែរ។

១៨. សិទ្ធិទទួលបានសុខភាព អនាម័យ និង មជ្ឈដ្ឋានដែលមានសុខភាព និង មាននិរន្តរភាព មានការថយចុះ ដោយសារតែគ្រួសារភាគច្រើនកំពុងតែដុតសំណល់រឹងរបស់ពួកគេ និង ប្រហែលមួយភាគបីកំពុងតែចាក់សំណល់នៅកន្លែងតាំងទីលំនៅថ្មី។

## សិទ្ធិទទួលបានការអប់រំ និង សេវាសុខាភិបាល

១៩. សិទ្ធិទទួលបានការអប់រំ មិនត្រូវបានទទួលស្គាល់យ៉ាងពេញលេញនោះទេ គ្រួសារចំនួនមួយភាគប្រាំ (រួមទាំងគ្រួសារជនជាតិភាគតិចជិតពាក់កណ្តាលផងដែរ) មិនបានបញ្ជូនកូនរបស់ពួកគេទៅសាលារៀននោះទេ ពីព្រោះពួកគេកំពុងតែធ្វើការដើម្បីស្វែងរកប្រាក់ចំណូល ចំណុចនេះមានប្រេវ៉ាឡង់កាន់តែខ្ពស់នៅតាមបណ្តាខេត្ត។

២០. សិទ្ធិទទួលបានសុខភាព មិនត្រូវបានទទួលស្គាល់យ៉ាងពេញលេញនោះទេ គ្រួសារមួយចំនួនបានអះអាងថា មណ្ឌលសុខភាពឃុំមានគុណភាពមិនល្អ ខ្វះខាតបុគ្គលិក ផ្តល់សេវាដែលមានចំនួនកំណត់ និង ស្ថិតនៅឆ្ងាយពីកន្លែងតាំងទីលំនៅថ្មី។ គ្រួសារមួយចំនួនត្រូវបានស្នើសុំឱ្យបង់ប្រាក់លើសពីថ្លៃសេវាស្តង់ដារជាផ្លូវការ ដើម្បីទទួលសេវាថែទាំសុខភាពសាធារណៈ។ កត្តាកំណត់មូលដ្ឋាននៃសុខភាពដែលរួមមានសិទ្ធិទទួលបានស្បៀងអាហារ លំនៅឋាន ទឹកស្អាតនិងមានសុវត្ថិភាព និង អនាម័យគ្រប់គ្រាន់ មិនត្រូវបានទទួលស្គាល់យ៉ាងពេញលេញនៅឡើយទេ។

*អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា៖*

២០.១. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ គប្បីបង្កើតបទដ្ឋានសម្រាប់ទំហំលំនៅឋានអប្បបរមាដែលអាចទទួលយកបាន។ រហូតទាល់តែបទដ្ឋានទាំងនេះត្រូវបាននបង្កើតឡើង បទដ្ឋានអន្តរជាតិដែលមានទំហំ ៣,៥ម២ សម្រាប់មនុស្សម្នាក់នៅក្នុងគ្រួសារ គប្បីត្រូវបានយកមកប្រើប្រាស់។

២០.២. ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់គប្បីធានាចំពោះបទដ្ឋានអប្បបរមានៃភាពសមរម្យនិងទំហំសម្រាប់គ្រប់គ្រួសារទាំងអស់ ដោយមិនគិតអំពីប្រភេទលំនៅឋានដែលមានពីមុនមកនោះទេ។

២០.៣. ក្រសួងសាធារណការ និង ដឹកជញ្ជូនគប្បីធានាថា មានការថែទាំគុណភាពផ្លូវថ្នល់នៅក្នុង និង នៅខាងក្រៅកន្លែងតាំងទីលំនៅថ្មី។

២០.៤. អាជ្ញាធរអគ្គិសនីកម្ពុជា និង អាជ្ញាធរពាក់ព័ន្ធដទៃទៀត គប្បីធានាថា គ្រប់គ្រួសារទាំងអស់មានអគ្គិសនីសម្រាប់ប្រើប្រាស់ក្នុងតម្លៃសមរម្យ ដើម្បីកាត់បន្ថយជាអប្បបរមានូវហានិភ័យផ្នែកសុខភាព និង បរិស្ថាន។

២០.៥. ក្រសួងអប់រំ យុវជន និងង កីឡា គប្បីអនុវត្តអនុសាសន៍នៅក្នុង របាយការណ៍ដែលគាំទ្រដោយ UNICEF នៅឆ្នាំ២០១៨[20] ស្តីពីការបង្កើតក្របខណ្ឌត្រួតពិនិត្យមួយ ហើយការកែលម្អគណៈកម្មការគាំទ្រសាលារៀនគប្បីត្រូវបានគោរពតាម និង អនុវត្ត។

*អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា សង្គមស៊ីវិល និង សហគមន៍អន្តរជាតិ៖*

២០.៦. គ្រួសារដែលបានតាំងទីលំនៅថ្មី ដែលបានរាយការណ៍ថាដំបូល និង ជញ្ជាំងរបស់ពួកគេមានសភាពមិនល្អ គប្បីទទួលបានជំនួយលើការកែលម្អលំនៅឋានរបស់ពួកគេ ដើម្បីការពារពួកគេពីការជំពាក់បំណុលបន្ថែមទៀត។

២០.៧. ចាំបាច់ត្រូវតែមានការសិក្សាបន្ថែមលើបញ្ហានានាដូចខាងក្រោម៖

- ២០.៧.១. ដើម្បីវាយតម្លៃថាតើភាពចង្អៀតណែន កើតឡើងនៅកន្លែងតាំងទីលំនៅថ្មី ដោយប្រៀបធៀបស្ថិតិចំនួនប្រជាពលរដ្ឋដែលរស់នៅក្នុងគ្រួសារនីមួយៗនឹងបទដ្ឋានស្តង់ដារអន្តរជាតិ
- ២០.៧.២. តួនាទីយេនឌ័រពាក់ព័ន្ធនឹងការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុនៅក្នុងគ្រួសារ និង រួមបញ្ចូលមូលហេតុដែលស្ត្រីត្រូវទទួលខុសត្រូវលើការទិញស្បៀងអាហារ។

២០.៨. អន្តរាគមន៍របស់ភាគីពាក់ព័ន្ធខុសៗគ្នា និង ជំនួយដែលពួកគេបានផ្តល់ជូនសហគមន៍ គប្បីត្រូវបានវាយតម្លៃ និង ប៉ាន់ប្រមាណលើផ្នែកនានាដូចខាងក្រោម។ ការវិភាគយេនឌ័រគប្បីត្រូវបានអនុវត្តចំពោះការវាយតម្លៃ/ការប៉ាន់ប្រមាណទាំងនោះ ដោយប្រើប្រាស់ទិន្នន័យដែលបែងចែកតាមយេនឌ័រយ៉ាងសកម្ម៖

- ២០.៨.១. ការផ្តល់ប្រព័ន្ធបង្ហូរទឹកដែលសមស្រប
- ២០.៨.២. ការទទួលស្គាល់សិទ្ធិទទួលបានស្បៀងអាហារសមរម្យ និង គ្រប់គ្រាន់
- ២០.៨.៣. ការទទួលស្គាល់សិទ្ធិទទួលបានទឹក ជាពិសេសទឹកពិសារ
- ២០.៨.៤. ការផ្តល់ជូននូវអនាម័យ និង ការចោលកាកសំណល់យ៉ាងត្រឹមត្រូវ
- ២០.៨.៥. ថាតើកុមារដែលមានវ័យក្រោម ១៨ឆ្នាំ ត្រូវស្ថិតនៅក្រោមពលកម្មកុមារដែរឬទេ និង
- ២០.៨.៦. គុណភាពនៃសេវាសុខាភិបាល។

២០.៩. រដ្ឋាភិបាល និង ភាគីពាក់ព័ន្ធគប្បីផ្តល់ជំនួយដែលចាំបាច់ទាំងអស់ដើម្បីធានាដល់៖

- ២០.៩.១. ភាពអាចទទួលបាននូវប្រព័ន្ធបង្ហូរទឹកនៅលើទីតាំង ដើម្បីទប់ស្កាត់ទឹកជំនន់ និង ហានិភ័យផ្នែកសុខភាព និង បរិស្ថាន ដែលពាក់ព័ន្ធ
- ២០.៩.២. លទ្ធភាពក្នុងការទទួលបានស្បៀងអាហារ
- ២០.៩.៣. លទ្ធភាពក្នុងការទទួលបានទឹកស្អាតសម្រាប់ពិសារ និង
- ២០.៩.៤. លទ្ធភាពក្នុងការទទួលបានការថែទាំសុខភាពសមរម្យ។

20 UNICEF (ឆ្នាំ២០១៨). កិច្ចការពារកុមារ និង តម្រូវការនៃការអប់រំសម្រាប់កុមារ និង មនុស្សវ័យជំទង់នៅក្នុងសហគមន៍ជនក្រីក្រនៅរាជធានីភ្នំពេញ ភ្នំពេញ UNICEF។ https://www.unicef.org/cambodia/media/641/file/20181112_URBAN_POOR_FULL_REPORT_ENG.pdf percent20.pdf បានចូលប្រើប្រាស់នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០។020.

## ជីវភាពរស់នៅ និង ឱកាសផ្នែកសេដ្ឋកិច្ច

២១. ការតាំងទីលំនៅថ្មីបានរួមចំណែកទៅដល់បំណុល និង សិទ្ធិមានលំនៅឋានសមរម្យ និង សិទ្ធិដទៃទៀត (ដូចជា ស្បៀងអាហារ សុខភាព ការអប់រំ និង ការងារ ជាដើម) ត្រូវបានរងផលប៉ះពាល់ ដោយសារគ្រួសារបានជំពាក់បំណុលគេដើម្បីកែលម្អលំនៅឋាន និង លក្ខខណ្ឌចិញ្ចឹមជីវិតរបស់ពួកគេ។

២២. មានកង្វល់ចំពោះភាពមិនទៀងទាត់នៃការផ្តល់ប្រាក់ចំណូល ជាពិសេសនៅពេលដែលវាជាប់ទាក់ទងទៅនឹងសន្តិសុខស្បៀង។ ការតាំងទីលំនៅថ្មី បានធ្វើឱ្យគ្រួសារមានភាពក្រត់ខ្សោយជាងពេលដែលពួកគេស្នាក់នៅទីតាំងចាស់របស់ពួកគេ។

២៣. សិទ្ធិទទួលបានការងារ និង ឱកាសទទួលបានជីវភាពរស់នៅតាមរយៈការងារ មិនត្រូវបានទទួលស្គាល់យ៉ាងពេញលេញនោះទេ ដោយសារខ្វះខាតឱកាសការងារនៅកន្លែងតាំងទីលំនៅថ្មី។ ចំណុចនេះបានប៉ះពាល់ទៅលើជនជាតិដើមភាគតិច ដោយសារតែជិតមួយភាគបីបានរាយការណ៍ថាមានការថយចុះនូវឱកាសការងារ។

*អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា៖*

២៣.១. អាជ្ញាធរពាក់ព័ន្ធគប្បីធានាថា សហគមន៍ដែលបានតាំងទីលំនៅថ្មីទទួលបាន យ៉ាងហោចណាស់ ស្តង់ដាររស់នៅដូចគ្នា ក្រោយពេលបណ្តេញចេញ។ ស្តង់ដាររស់នៅមិនគួរមានភាពអន់ថយក្រោយពេលតាំងទីលំនៅថ្មីនោះទេ។

២៣.២. ដូចបានកត់សម្គាល់នៅខាងលើ (ចូរមើល កថាខណ្ឌ ៦.១. ខាងលើ) អាជ្ញាធរគប្បីធានាថា កន្លែងតាំងទីលំនៅថ្មី គួរស្ថិតនៅក្នុងតំបន់ដែលមានជីវភាពរស់នៅ និង ឱកាសការងារសម្រាប់ទាំងស្ត្រី និង បុរស និង នៅជិតទីតាំងចាស់ខ្លាំងបំផុតតាមដែលអាចធ្វើបានកន្លែងដែលគ្រួសារមានអាជីវកម្ម ឬ កន្លែងធ្វើការ។ សោហ៊ុយនៃការធ្វើដំណើរទៅមក មកពីកន្លែងធ្វើការ ក៏ចាំបាច់ត្រូវតែយកមកពិចារណាដែរ។

*អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា សង្គមស៊ីវិល និង សហគមន៍អន្តរជាតិ៖*

២៣.៣. ការសិក្សាបន្ថែមគប្បីត្រូវបានអនុវត្ត ពាក់ព័ន្ធនឹងផលប៉ះពាល់នៃកម្ចីឥណទាន និង បំណុល ដែលបានកើតឡើងចំពោះគ្រួសារទាំងឡាយដែលបានតាំងទីលំនៅថ្មី និង ចាត់វិធានការសមស្របដើម្បីដោះស្រាយការរំលោភបំពានលើសិទ្ធិណាមួយដែលអាចកំពុងតែកើតឡើង។ ការវិភាគយេនឌ័រគប្បីត្រូវបានដាក់បញ្ចូលនៅក្នុងការវាយតម្លៃ និង ការឆ្លើយតប។

២៣.៤. អាជ្ញាធរពាក់ព័ន្ធ និង ភាគីពាក់ព័ន្ធគប្បីធ្វើការវាយតម្លៃអំពីឱកាសទទួលបានជីវភាពរស់នៅនៅកន្លែងតាំងទីលំនៅថ្មី និង ដោះស្រាយបញ្ហាកង្វះខាតប្រាក់ចំណូល ជាពិសេសនៅពេលដែលកង្វះខាតប្រាក់ចំណូលមានផលប៉ះពាល់អវិជ្ជមាន ចំពោះការទទួលបានសិទ្ធិដទៃទៀត។ ការវិភាគយេនឌ័រគប្បីត្រូវបានដាក់បញ្ចូលទៅក្នុងការវាយតម្លៃ និងការឆ្លើយតប។

២៣.៥. នៅពេលបាត់បង់ការងារ និងឱកាសក្នុងការរកបរចិញ្ចឹមជីវិត មានភាពខ្វះខាតនៅកន្លែងតាំងទីលំនៅថ្មី អាជ្ញាធរពាក់ព័ន្ធ និង ភាគីពាក់ព័ន្ធគប្បីផ្តល់ការបណ្តុះបណ្តាលអំពីការស្តារជីវភាពរស់នៅ និង ជំនាញនានា ដើម្បីអោយគ្រួសារដែលបានតាំងទីលំនៅថ្មី អាចមានមធ្យោបាយផ្សេងទៀតដើម្បីស្វែងរកប្រាក់ចំណូល អាជ្ញាធរពាក់ព័ន្ធក៏ត្រូវធានាថា គ្មានការដកហូតសិទ្ធិផ្សេងទៀត ដូចជា សិទ្ធិទទួលបានស្បៀងអាហារ សុខភាព និង សិទ្ធិប្រហាក់ប្រហែលគ្នា ដោយមិនត្រឹមត្រូវឡើយ។

## ផលប៉ះពាល់ផ្នែកសង្គម និង បរិស្ថាន

២៤. សិទ្ធិក្នុងការអនុវត្តសាសនារបស់ពួកគេដោយបើកចំហរ និង ដោយសេរី ត្រូវបានគោរព ពីព្រោះគ្រួសារស្ទើរតែទាំងអស់ រួមទាំងគ្រួសារជនជាតិដើមភាគតិចផងដែរ បានអះអាងថា ពួកគេអាចអនុវត្តសាសនារបស់ពួកគេដោយបើកចំហរ និង ដោយសេរីបាន នៅកន្លែងតាំងទីលំនៅថ្មី។

២៥. មានទីតាំងមួយបានរាយការណ៍ថា ការប្រើគ្រឿងញៀនដោយអ្នកខាងក្រៅ និង ខាងក្នុងកន្លែងតាំងទីលំនៅថ្មី គឺជាបញ្ហាចម្បង។ ពុំមានព័ត៌មានណាមួយត្រូវបានផ្តល់ជូនពាក់ព័ន្ធនឹងដើមហេតុ និង របៀបដោះស្រាយបញ្ហានេះទេ។

២៦. សិទ្ធិរបស់ជនជាតិដើមភាគតិច ពាក់ព័ន្ធនឹងសមត្ថភាពក្នុងការបន្តរបៀបរស់នៅតាមបែបប្រពៃណីរបស់ពួកគេនៅកន្លែងតាំងទីលំនៅថ្មី ត្រូវបានគោរព។ បីភាគបួននៃគ្រួសារជនជាតិដើមភាគតិចបានរាយការណ៍ថាអាចបន្តរបៀបរស់នៅតាមបែបប្រពៃណីរបស់ពួកគេបាន តាមរយៈការបរបាញ់សត្វ ការនេសាទ និង ការប្រមូលស្បៀងអាហារ។ ទោះបីជាយ៉ាងណាក៏ដោយ ទោះបីជាពួកគេរស់នៅកន្លែងដូចគ្នាក៏ដោយ គ្រួសារមួយចំនួនបានយល់ឃើញថា វាមានការពិបាកនៅក្នុងការបន្តរបៀបរស់នៅតាមបែបប្រពៃណីរបស់ពួកគេ។

*អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា៖*

២៦.១.ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រួមជាមួយក្រសួងអភិវឌ្ឍន៍ជនបទ និង អាជ្ញាធរពាក់ព័ន្ធដទៃទៀត គប្បីគោរព ការពារ និង បំពេញ នូវសិទ្ធិរបស់ជនជាតិដើមភាគតិចឱ្យបានពេញលេញ ដើម្បីឱ្យពួកគេអាចរក្សា និងបន្តរបៀបរស់នៅតាមបែបប្រពៃណីរបស់ពួកគេ។ កន្លែងតាំងទីលំនៅថ្មីគួរត្រូវបានរៀបចំឡើងក្នុងលក្ខណៈ ដែលមានភាពសមស្របតាមបែបវប្បធម៌ និងផ្តល់ជូនគ្រួសារជនជាតិដើមភាគតិចទាំងអស់ នូវឱកាសក្នុងការបន្តរបៀបរស់នៅតាមបែបប្រពៃណីរបស់ពួកគេ។

*អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា សង្គមស៊ីវិល និង សហគមន៍អន្តរជាតិ៖*

២៦.២.ក្រសួងសុខាភិបាល និង អាជ្ញាធរពាក់ព័ន្ធ និង ភាគីពាក់ព័ន្ធដទៃទៀត គប្បីអនុវត្តការសិក្សាបន្ថែមទៀតអំពីដើមហេតុចម្បងនៃការប្រើគ្រឿងញៀននៅកន្លែងតាំងទីលំនៅថ្មីនេះ និង រៀបចំ និង អនុវត្តអន្តរាគមន៍យ៉ាងត្រឹមត្រូវ ដោយផ្អែកលើសិទ្ធិទទួលបានសុខភាព។



សហគមន៍ បូរីសន្តិភាព II មានទីតាំងស្ថិតនៅ ភូមិដំណាក់ត្រយឹង, សង្កាត់ចោមចៅ, ខ័ណ្ឌពោធិ៍សែនជ័យ, រាជធានីភ្នំពេញ។ រូបថត ៖ CUFA

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១៖ ឈ្មោះទីកន្លែង និងអាសយដ្ឋានពេញនៃទីតាំងបណ្ដេញចេញ

ឧបសម្ព័ន្ធទី១៖ បញ្ជីឈ្មោះទីតាំងបណ្ដេញចេញចំនួន ៣៧ កន្លែង តាមខេត្ត (តាមលំដាប់លំដោយនៃតួអក្សរ)

| អាសយដ្ឋានពេញ | ឈ្មោះទីកន្លែង |
|---|---|
| **បាត់ដំបង** | |
| ភូមិកំពង់ក្របី សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង | កំពង់ក្របី |
| ភូមិទួលតាឯក សង្កាត់ទួលតាឯក ក្រុងបាត់ដំបង ខេត្តបាត់ដំបង | ទួលតាឯក |
| **កំពង់ស្ពឺ** | |
| [មិនស្គាល់ឈ្មោះសហគមន៍/ភូមិ] ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ | ត្រពាំងជោ |
| ផ្ដៅច [មិនស្គាល់ឈ្មោះភូមិ] ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ | ផ្ដៅច |
| អូរព្រឡៅ [មិនស្គាល់ឈ្មោះភូមិ] ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ | អូរព្រឡៅ |
| ភូមិចាស់ [មិនស្គាល់ឈ្មោះភូមិ] ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ | ភូមិចាស់ |
| ភូមិពីស ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ | ពីស |
| ស្រះប៉ូប [មិនស្គាល់ឈ្មោះភូមិ] ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ | ស្រះប៉ូប |
| ភូមិទឹកថ្លាលាច ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ | ទឹកថ្លាលាច |
| **កោះកុង** | |
| ភូមិព្រែកស្វាច់ ឃុំកោះស្វាច់ ស្រុកគិរីសាគរ ខេត្តកោះកុង | ព្រែកស្វាច់ |
| ភូមិតានួន ឃុំតានួន ស្រុកបុទុមសាគរ ខេត្តកោះកុង | តានួន |
| ភូមិទួលពោធិ៍ ឃុំតានួន ស្រុកបុទុមសាគរ ខេត្តកោះកុង | ទួលពោធិ៍ |
| **ឧត្ដរមានជ័យ** | |
| ភូមិបូស សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្ដរមានជ័យ | បូស |
| **ភ្នំពេញ** | |
| បឹងកក់ [មិនស្គាល់ឈ្មោះភូមិ] សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ | បឹងកក់ |
| ប៊ុរីកីឡា [មិនស្គាល់ឈ្មោះភូមិ] សង្កាត់វាលវង់ ខណ្ឌ ៧ មករា ភ្នំពេញ | ប៊ុរីកីឡា |
| ដីក្រហម [មិនស្គាល់ឈ្មោះភូមិ] សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ | ដីក្រហម |

| | |
|---|---|
| ក្រុម ៦៦ ភូមិ ១១ សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ ភ្នំពេញ | ក្រុម ៦៦ |
| គីឡូលេខ ៦ [មិនស្គាល់ឈ្មោះភូមិ] សង្កាត់គីឡូម៉ែត្រលេខ ៧ ខណ្ឌឫស្សីកែវ ភ្នំពេញ | គីឡូលេខ ៦ |
| អគារសំបុកចាប [មិនស្គាល់ឈ្មោះភូមិ] សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ | អគារសំបុកចាប |
| ទួលសង្កែ [មិនស្គាល់ឈ្មោះភូមិ] សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ ភ្នំពេញ | ទួលសង្កែ |
| **ព្រះសីហនុ** | |
| [មិនស្គាល់ឈ្មោះសហគមន៍/ភូមិ] ឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ | ទំនប់រលក |
| ភូមិក្បាលឆាយ [មិនស្គាល់ឈ្មោះឃុំ ប៉ុន្តែអាចហៅថា ឃុំអូរទ្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ | ក្បាលឆាយ |
| ភូមិអុង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ | អុង |
| ភូមិ ៣ សង្កាត់មួយ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ | ភូមិ ៣ |
| ភូមិ ៦ សង្កាត់ ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ | ភូមិ ៦ |
| **សៀមរាប** | |
| ភូមិបឹងដូនប៉ា សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប | បឹងដូនប៉ា |
| ភូមិមណ្ឌល ៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប | មណ្ឌល ៣ |
| ភូមិសាលាកំរើក សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប | សាលាកំរើក |
| ភូមិស្លក្រាម សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប | ស្លក្រាម |
| ស្ពានចាស់ [មិនស្គាល់ឈ្មោះភូមិ] សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប | ស្ពានចាស់ |
| ភូមិទ្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប | ទ្រាំង |
| ភូមិវត្តដំណាក់ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប | វត្តដំណាក់ |
| ភូមិវត្តពោធិ៍ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប | វត្តពោធិ៍ |
| ភូមិវត្តស្វាយ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប | វត្តស្វាយ |
| **ស្ទឹងត្រែង** | |
| ភូមិក្បាលរមាសចាស់ ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង | ក្បាលរមាសចាស់ |
| ភូមិស្រែស្រណុកចាស់ ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង | ស្រែស្រណុកចាស់ |
| ភូមិស្រែគចាស់ ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង | ស្រែគចាស់ |

"សង្កាត់" និង "ឃុំ" មានផ្នែករដ្ឋបាលប្រហាក់ប្រហែលគ្នា ប៉ុន្តែ "សង្កាត់" ត្រូវបានប្រើសម្រាប់ហៅឈ្មោះនៅទីក្រុង និង "ឃុំ" ត្រូវបានប្រើសម្រាប់ហៅឈ្មោះនៅទីជនបទ ឬ នៅតាមបណ្តាខេត្ត។ "ខណ្ឌ" និង "ស្រុក" មានផ្នែករដ្ឋបាលប្រហាក់ប្រហែលគ្នា ប៉ុន្តែ "ខណ្ឌ" ត្រូវបានប្រើសម្រាប់ហៅឈ្មោះនៅទីក្រុង និង "ស្រុក" ត្រូវបានប្រើសម្រាប់ហៅឈ្មោះនៅទីជនបទ ឬ នៅតាមបណ្តាខេត្ត។

# ឧបសម្ព័ន្ធទី២៖ ទីតាំងបណ្ដេញចេញ តាមកន្លែងតាំងទីលំនៅថ្មី

## ឧបសម្ព័ន្ធទី២៖ កន្លែងតាំងទីលំនៅថ្មី និង ទីតាំងបណ្ដេញចេញ តាមខេត្ត (ខេត្ត កន្លែងតាំងទីលំនៅថ្មី និង ទីតាំងបណ្ដេញចេញ)

### បាត់ដំបង
- **ព្រៃកូនសេក**
  - កំពង់ក្របី
  - ទួលតាឯក

### កំពង់ស្ពឺ
- **ពីស**
  - ផ្លោច
  - អូរព្រឡៅ
  - ភូមិចាស់
  - ពីស
  - ស្រះប៉ូប
  - ត្រពាំងជោ
  - ទឹកថ្លាលាច

### កណ្ដាល
- **ស្រះពោធិ៍**
  - ប៉ុរីកីឡា

### កោះកុង
- **ព្រៃកស្វាច់**
  - ព្រៃកស្វាច់
  - តាន្ទួន
  - ទួលពោធិ៍

### ឧត្ដរមានជ័យ
- **អូរបាត់មាន់**
  - បួស

### ភ្នំពេញ
- **អណ្ដូងចាស់**
  - បឹងកក់
  - អគារសំបុកចាប
- **អណ្ដូងថ្មី**
  - បឹងកក់
  - ប៉ុរីកីឡា
  - អគារសំបុកចាប
- **ដំណាក់ត្រយឹង**
  - បឹងកក់
  - ប៉ុរីកីឡា
  - ដីក្រហម
- **ស្រែអំពិល**
  - ក្រុម ៦៦
- **ត្រពាំងអញ្ចាញ**
  - គីឡូលេខ ៦
  - ទួលសង្កែ
- **ទួលសំបូរ**
  - ប៉ុរីកីឡា
  - អគារសំបុកចាប

### ព្រះសីហនុ
- **អភិវឌ្ឍដីថ្មី**
  - ក្បាលឆាយ
  - ភូមិ ៣
  - ទំនប់រលក
- **អូរកម្ពុជា**
  - អុង
  - ទំនប់រលក
- **អូរត្រជាក់ចិត្ត**
  - ក្បាលឆាយ
  - ភូមិ ៦

### សៀមរាប
- **វាល**
  - បឹងដូនប៉ា
  - មណ្ឌល ៣
  - សាលាកំរើក
  - ស្លក្រាម
  - ស្ពានចាស់
  - ទ្រាំង
  - វត្តដំណាក់
  - វត្តពោធិ៍
  - វត្តស្វាយ

### ស្ទឹងត្រែង
- **ក្បាលរមាសថ្មី**
  - ក្បាលរមាសចាស់
  - ស្រែស្រណុកចាស់
  - ស្រែគចាស់
- **ស្រែស្រណុកថ្មី**
  - ស្រែស្រណុកចាស់
  - ស្រែគចាស់

# ឧបសម្ព័ន្ធទី៣៖ ការពិគ្រោះយោបល់

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២១ ការិយាល័យ OHCHR បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ដើម្បីអនុញ្ញាតឱ្យភាគីពាក់ព័ន្ធសំខាន់ៗ មកពីក្រសួងនានានៃរាជរដ្ឋាភិបាលកម្ពុជា មេដឹកនាំសហគមន៍ និងតំណាងសង្គមស៊ីវិល ដែលធ្វើការងារក្នុងវិស័យនេះ ដើម្បីបញ្ជាក់សុពលភាពនៃការរកឃើញតាមរយៈការស្រាវជ្រាវដែលបានធ្វើឡើងនៅក្នុងឆ្នាំ ២០១៩ និង ២០២០ និងពិភាក្សាអំពីអនុសាសន៍នៅក្នុងរបាយការណ៍ សេចក្តីព្រាងគោលការណ៍ណែនាំ និងពិភាក្សាអំពីដំណើរឆ្ពោះទៅមុខរួមគ្នា។

ការិយាល័យ OHCHR បានទទួលការរួមចំណែកដ៏មានតម្លៃពីអ្នកចូលរួមនៅក្នុងអំឡុងពេលនៃកិច្ចប្រជុំពិគ្រោះយោបល់។ អនុសាសន៍ដែលធ្វើឡើងដោយភាគីពាក់ព័ន្ធ ត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍ជាការចាំបាច់។

### ការទទួលស្គាល់នៃការរាតត្បាតនៃជំងឺកូវីដ១៩៖

របាយការណ៍នេះទទួលស្គាល់ការផ្ទុះឡើងនៃការរាតត្បាតនៃជំងឺកូវីដ១៩នៅក្នុងផ្នែកទី៣ នៃផ្នែកវិធីសាស្ត្រ។

### វាក្យសព្ទ និងការបកប្រែ៖

ពាក្យថា “eviction” ជាភាសាខ្មែរ ជាទូទៅត្រូវបានប្រែថា “ ការបណ្តេញចេញ” ដែលមកពីកិរិយាស័ព្ទ “ដេញចេញ” មានន័យថា “ដេញនណាម្នាក់ចេញអោយឆ្ងាយ”។ ជារឿយៗគេយល់ថា ពាក្យនេះមានទស្សនទានអវិជ្ជមាន ដែលមិនស្របទៅតាមន័យ “eviction” ជាភាសាអង់គ្លេស។

ជាឧទាហរណ៍ ជំនួសឱ្យការប្រើពាក្យ “ការបណ្តេញចេញ” នៅក្នុងសារាចរលេខ០៣ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីធ្លី បានប្រើប្រាស់ពាក្យ “ការប្តូរទីតាំងថ្មី” ដែលមានន័យថា “ផ្លាស់ប្តូរទៅទីតាំងថ្មី” ដូច្នេះហើយត្រូវបានបកប្រែជាភាសាអង់គ្លេសថា “ការផ្លាស់ទីលំនៅ”។ ដូចគ្នានេះដែរ នៅក្នុងសារាចរលេខ០៣បានប្រើប្រាស់ពាក្យ“ការតាំងទីលំនៅថ្មី”ដែលមានន័យថា‘ទៅរស់នៅកន្លែងថ្មី’ហើយត្រូវបានបកប្រែជាភាសាអង់គ្លេសថា ”ការតាំងទីលំនៅថ្មី”។ ខណៈពេលដែល ការផ្លាស់ទីលំនៅ ឬ ការតាំងទីលំនៅថ្មី អាចកើតឡើងបន្ទាប់ពីការបណ្តេញចេញ តែវាមិនមែនគ្រប់ករណីនោះទេ។ ដូច្នេះពាក្យទាំងពីរនេះ មិនបានពិពណ៌នាអោយបានច្បាស់លាស់ អំពីដំណើរការដែលមនុស្សត្រូវបានបង្ខំឱ្យចាកចេញពីផ្ទះរបស់ពួកគេទេ។ ពាក្យទាំងពីរអាចប្រើជំនួសគ្នាបាន។ នៅក្នុងការសិក្សានេះការប្រើប្រាស់ពាក្យ “ការតាំងទីលំនៅថ្មី” ត្រូវបានប្រើដើម្បីពិពណ៌នាអំពីលក្ខខណ្ឌរយៈពេលវែងដែលទាក់ទងនឹងការផ្លាស់ប្តូរទៅកន្លែងថ្មី; ហើយការប្រើប្រាស់ពាក្យ “ការផ្លាស់ទីលំនៅ” ដើម្បីពណ៌នាកាន់តែពិសេសអំពីសកម្មភាពនៃការផ្លាស់ប្តូរទៅទីតាំងថ្មី។

### ការបញ្ជាក់អំពីលក្ខខណ្ឌផ្លូវច្បាប់ “ ការបណ្តេញចេញ” និង “ការបណ្តេញចេញដោយបង្ខំ”៖

ការបណ្តេញចេញដោយបង្ខំត្រូវបានហាមឃាត់គ្រប់កាលៈទេសៈទាំងអស់ ដោយមិនគិតអំពីស្ថានភាពកម្មសិទ្ធិ ឬឋានៈនៃការកាន់កាប់របស់អ្នកដែលរងផលប៉ះពាល់។ ការបណ្តេញចេញដោយបង្ខំ រួមមាន សកម្មភាព ឬការមិនបំពេញកាតព្វកិច្ច ដែលជាប់ពាក់ព័ន្ធនឹងការចាកចេញដោយបង្ខំ ឬដោយមិនស្ម័គ្រចិត្តរបស់បុគ្គល ក្រុម និង សហគមន៍ ពីផ្ទះ ឬដីធ្លី និងធនធាននៃទ្រព្យសម្បត្តិទូទៅ ដែលត្រូវបានកាន់កាប់ ឬអាស្រ័យផល ដូច្នេះបានលុបបំបាត់ ឬដាក់កម្រិតលើសមត្ថភាពរបស់បុគ្គល ក្រុម និងសហគមន៍ នៅក្នុងការស្នាក់នៅ ឬធ្វើការនៅក្នុងទីតាំងជាក់លាក់ណាមួយ ដោយមិនបានផ្តល់ជូន និងទទួលបានទម្រង់សមរម្យនៃការការពារតាមផ្លូវច្បាប់ ឬការការពារដទៃទៀត[21]។

ក្នុងករណីដែលការបណ្តេញចេញត្រូវបានចាត់ទុកថាមានភាពយុត្តិធម៌ ការបណ្តេញចេញនោះត្រូវតែបាន អនុវត្តយ៉ាងតឹងរ៉ឹងជាមួយនឹងបទដ្ឋាន និងស្តង់ដារសិទ្ធិមនុស្សអន្តរជាតិដែលពាក់ព័ន្ធ ដោយអនុលោមតាមគោលការណ៍ទូទៅនៃភាពសមហេតុសមផល និងសមាមាត្រ ហើយជាមួយនឹងការទាមទារ និងដំណោះស្រាយផ្លូវច្បាប់ទាំងអស់ដែលមានសម្រាប់អ្នកដែលរងផលប៉ះពាល់[22]។

---

21 កាតព្វកិច្ចរបស់រដ្ឋក្នុងការបដិសេធ និងការពារប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំពីលំនៅឋាន និងដី កើតឡើងពីឧបករណ៍ច្បាប់អន្តរជាតិមួយចំនួនដែលការពារសិទ្ធិមនុស្សក្នុងការមានលំនៅឋានសមរម្យ និងសិទ្ធិមនុស្សពាក់ព័ន្ធផ្សេងទៀត។ ទាំងនេះរួមមាន សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (មាត្រា១១ កថាខណ្ឌទី១) អនុសញ្ញាស្តីពីសិទ្ធិកុមារ (មាត្រា២៧ កថាខ័ណ្ឌទី៣) បទប្បញ្ញត្តិមិនរើសអើងដែលមាននៅក្នុងមាត្រា១៤ កថាខ័ណ្ឌទី២ (h) នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី និងមាត្រា 5 (e) នៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍។ លើសពីនេះទៀត និងស្របជាមួយនឹងភាពមិនអាចកាត់ផ្តាច់បាននៃវិធីសាស្ត្រសិទ្ធិមនុស្ស មាត្រា១៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយចែងថា “[n]o គ្មានជនណាម្នាក់នឹងត្រូវទទួលរងនូវការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ចំពោះឯកជនភាព គ្រួសារ ផ្ទះ ឬការឆ្លើយឆ្លងរបស់គាត់។ ហើយបន្ថែមពីនេះគឺ “[e]មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការការពារពីច្បាប់ប្រឆាំងនឹងការជ្រៀតជ្រែក ឬការវាយប្រហារ”មាត្រា១៦ កថាខ័ណ្ឌទី១ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារដែលមានបទប្បញ្ញត្តិស្រដៀងគ្នា។

22 គណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (CESCR) សេចក្តីពន្យល់រួម លេខ៧៖ សិទ្ធិទទួលបានលំនៅឋានសមរម្យ (មាត្រា ១១.១)៖ ការបណ្តេញចេញដោយបង្ខំ កថាខណ្ឌ១៤-១៥។

# ឧបសម្ព័ន្ធទី៤៖

## សេចក្តីព្រាងគោលការណ៍ណែនាំអំពីការតាំងទីលំនៅថ្មី


១. សេចក្តីផ្តើម ៥១

២. ការហាមឃាត់ការបណ្តេញចេញដោយបង្ខំ ៥២

៣. មុននឹងធ្វើការបណ្តេញចេញ ៥២

៣.១ ដំណើរការនៃការសម្រេចចិត្ត ៥២

៣.២ សេចក្តីជូនដំណឹងអំពីការបណ្តេញចេញ ៥៣

៣.៣ លក្ខខណ្ឌតម្រូវសម្រាប់កន្លែងផ្លាស់ទីលំនៅថ្មី ៥៤

៤. ការអនុវត្តការបណ្តេញចេញ ៥៥

៥. សេវាដែលនឹងត្រូវផ្តល់ជូនក្រោយពេលបណ្តេញចេញ ៥៦

៥.១ គោលការណ៍ណែនាំសម្រាប់ការកំណត់សំណងដោយយុត្តិធម៌ ៥៧

៥.២ បដិទាន និង ការវិលត្រឡប់មកវិញ ៥៧

៥.៣ សុវត្ថិភាពនៃការកាន់កាប់ ៥៨

៥.៤ ការដោះស្រាយវិវាទ ៥៨

៦. ការត្រួតពិនិត្យ ការវាយតម្លៃ និង ការតាមដានបន្ត ៥៩

# ១. សេចក្តីផ្តើម

១. គោលការណ៍ណែនាំទាំងនេះត្រូវបានបង្កើតឡើងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និង មានបំណង ជួយដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានាថាមានច្បាប់ជាតិ គោលនយោបាយ និងគោលការណ៍ណែនាំ ពាក់ព័ន្ធនឹងសិទ្ធិមានលំនៅឋានសមរម្យ។ គោលការណ៍ណែនាំទាំងនេះក៏មានបំណងផ្តល់ការណែនាំដល់រាជរដ្ឋាភិបាលកម្ពុជាផងដែរ ដែលជាផ្នែកមួយនៃសិទ្ធិទទួលបានស្តង់ដាររស់នៅសមរម្យ នៅពេលអនុវត្តការបណ្តេញចេញ ការផ្លាស់ទីលំនៅ ឬ ការតាំងទីលំនៅថ្មី ដើម្បីធានាថាឱ្យមានការគោរព និងអនុលោមតាមនិយាម និង បទដ្ឋានសិទ្ធិមនុស្សក្នុងប្រទេស និង អន្តរជាតិ។

២. គោលការណ៍ណែនាំនេះ ត្រូវអនុវត្តចំពោះរាល់ការផ្លាស់ទីលំនៅ និងការតាំងទីលំនៅថ្មី នៅប្រទេស កម្ពុជាដែលបណ្តាលមកពីគម្រោងអភិវឌ្ឍន៍នានាដូចជា សម្បទាន និងកិច្ចសន្យាសាធារណៈជាដើម ដោយមិនគិតអំពីប្រភពមូលនិធិនោះទេ និង/ឬ គ្រោះធម្មជាតិ រួមបញ្ចូលទាំង ផលប៉ះពាល់យឺតៗ និង ផលប៉ះពាល់យ៉ាងខ្លាំងក្លាភ្លាមៗនៃការប្រែប្រួលអាកាសធាតុផងដែរ។

៣. ការអនុវត្តការបណ្តេញចេញដោយបង្ខំ ផ្ទុយនឹងច្បាប់ដែលអនុលោមតាមនិយាម និង បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ បង្កើតបានជាការរំលោភបំពានយ៉ាងខ្លាំងក្លាលើសិទ្ធិមនុស្សជាច្រើន ជាពិសេស សិទ្ធិមានលំនៅឋានសមរម្យ។ មនុស្សគ្រប់រូបមានសិទ្ធិទទួលបានលំនៅឋានសមរម្យ ដែលជាសមាសធាតុមួយនៃសិទ្ធិទទួលបានស្តង់ដាររស់នៅសមរម្យ។ ការទប់ស្កាត់ការបណ្តេញចេញដោយបង្ខំគឺជាផ្នែកមួយដែលមានជាប់មកជាមួយនឹងសិទ្ធិនេះ។

៤. ក្នុងនាមជារដ្ឋភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ស្របតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សិទ្ធិមានលំនៅឋានសមរម្យអនុវត្តចំពោះពលរដ្ឋកម្ពុជាគ្រប់រូប ដោយឥតប្រកាន់ពូជសាសន៍ ភេទ ភាសា សាសនា ឬ ជំនឿ ទស្សនៈផ្នែកនយោបាយ ឬ ទស្សនៈផ្សេងទៀត ឋានៈតាមផ្លូវច្បាប់ ឬ ឋានៈនៅក្នុងសង្គម អាយុ ពិការភាព ទ្រព្យសម្បត្តិ កំណើត ឬ ឋានៈផ្សេងទៀតនោះទេ។

៥. ជនគ្រប់រូប ក្រុម និង សហគមន៍ទាំងអស់ មានសិទ្ធិទទួលបានការតាំងទីលំនៅថ្មី ដែលរួមមាន សិទ្ធិទទួលបានដីធ្លីជំនួសដែលមានគុណភាពល្អជាងមុន ឬ ស្មើគ្នា និង លំនៅឋាន ដែលត្រូវតែបំពេញតាមលក្ខណវិនិច្ឆ័យនៃភាពសមរម្យដូចតទៅ៖ អាចចេញចូលបាន អាចផ្គត់ផ្គង់បាន អាចស្នាក់នៅបាន មានសុវត្ថិភាពនៃការកាន់កាប់ មានភាពសមរម្យផ្នែកវប្បធម៌ ភាពសមរម្យនៃទីតាំង និង ការទទួលបានសេវាសំខាន់ៗ ដូចជា សេវាសុខាភិបាល និង ការអប់រំ ជាដើម។

៦. គណៈកម្មាធិការដោះស្រាយផលប៉ះពាល់អន្តរក្រសួង (ការបណ្តេញចេញ ការផ្លាស់ទីលំនៅ និង ការតាំងទីលំនៅថ្មី) សមាសភាពដែលមានមិនកំណត់នោះទេ គប្បីត្រូវបានបង្កើតឡើងដែលរួមមានជាអាទិ៍ ក្រសួងមហាផ្ទៃ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងសុខាភិបាល, ក្រសួងអប់រំ យុវជន និង កីឡា, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងកិច្ចការនារី, ក្រសួងបរិស្ថាន និង ក្រសួងយុត្តិធម៌។ គណៈកម្មាធិការអន្តរក្រសួងនឹងមានភារកិច្ចត្រួតពិនិត្យការអនុវត្តគោលការណ៍ណែនាំទាំងនេះ រួមទាំង ទប់ស្កាត់ការបណ្តេញតាមដោយបង្ខំ តាមរយៈ៖

  ក. ការកំណត់ហេតុផលសំអាងនៃការបណ្តេញចេញណាមួយដែលត្រូវបានស្នើឡើង និង មិនអនុញ្ញាតចំពោះការបណ្តេញចេញដែលអាចចាត់ទុកថាជាការបណ្តេញចេញដោយបង្ខំ

  ខ. ត្រួតពិនិត្យការអនុវត្តការបណ្តេញចេញដែលមានហេតុផលសំអាង និង ដំណើរការនៃការតាំងទីលំនៅថ្មី

  គ. ពិនិត្យតាមដាន និង វាយតម្លៃផលប៉ះពាល់នៃការតាំងទីលំនៅថ្មី លើបុគ្គល និង សហគមន៍ដែលរងផលប៉ះពាល់ និង

  ឃ. ធានា និង ត្រួតពិនិត្យវិធានការដោះស្រាយ រួមទាំង ការផ្តល់សំណងដល់ប្រជាជនដែលរងផលប៉ះពាល់ផងដែរ។

៧. គណៈកម្មាធិការអន្តរក្រសួងនេះអាចបំបែកជាអនុគណៈកម្មាធិការដើម្បីដោះស្រាយ៖

  ក. ហេតុផលសំអាងសំរាប់ការបណ្តេញចេញ (ផ្នែក ២ នៃគោលការណ៍ណែនាំ)

  ខ. ការប្រឹក្សាយោបល់ និង ការជូនដំណឹងអំពីការបណ្តេញចេញ (ផ្នែក ៣.១ និង ៣.២)

  គ. កំណត់ និង រៀបចំកន្លែងតាំងទីលំនៅថ្មី (ផ្នែក ៣.៣)

  ឃ. ត្រួតពិនិត្យសកម្មភាពក្នុងពេលបណ្តេញចេញ (ផ្នែក ៤)

  ង. ការទូទាត់សំណងដល់គ្រួសារដែលរងផលប៉ះពាល់ (ផ្នែក ៥.១ និង ៥.២)

  ច. ធានាចំពោះសុវត្ថិភាពនៃការកាន់កាប់ (ផ្នែក ៥.៣) និង

  ឆ. ពិនិត្យតាមដាន និង វាយតម្លៃស្ថានភាពរបស់សហគមន៍នៃកន្លែងតាំងទីលំនៅថ្មី(ផ្នែក ៦)។

៨. ទំនួលខុសត្រូវរបស់រដ្ឋ និង សហគ្រាសពាណិជ្ជកម្ម

  ក. តួអង្គមិនមែនរដ្ឋ រួមទាំងសហគ្រាសពាណិជ្ជកម្មផងដែរ មានទំនួលខុសត្រូវចំពោះការគោរពសិទ្ធិមនុស្ស និង សិទ្ធិកាន់កាប់តាមផ្លូវច្បាប់។ សហគ្រាសពាណិជ្ជកម្មគប្បីធ្វើសកម្មភាពដោយមានការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នជាមុន ដើម្បីបញ្ជៀសការបំពានលើសិទ្ធិមនុស្ស និង សិទ្ធិ

កាន់កាប់តាមផ្លូវច្បាប់របស់អ្នកដទៃ។ ពួកគេគប្បីបញ្ចូលប្រព័ន្ធគ្រប់គ្រងហានិភ័យសមស្រប ដើម្បីទប់ស្កាត់ និង ដោះស្រាយផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្ស និង សិទ្ធិកាន់កាប់តាមផ្លូវច្បាប់។ សហគ្រាសពាណិជ្ជកម្មគប្បីផ្ដល់ និង ផសហការនៅក្នុងយន្តការដោះស្រាយក្រៅប្រព័ន្ធតុលាការ រួមទាំង យន្តការបណ្ដឹងសារទុក្ខនៅកម្រិតប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ក្នុងករណីសមស្របដែលពួកគេបានបង្ក ឬ បានរួមចំណែកដល់ផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្ស និង សិទ្ធិកាន់កាប់តាមផ្លូវច្បាប់។ សហគ្រាសពាណិជ្ជកម្មគប្បីកំណត់ និង ប៉ាន់ប្រមាណអំពីផលប៉ះពាល់ជាក់ស្ដែង ឬ ជាសក្ដានុពលលើសិទ្ធិមនុស្ស និង សិទ្ធិកាន់កាប់តាមផ្លូវច្បាប់ ដែលពួកគេអាចជាប់ពាក់ព័ន្ធ។

ខ. រាជរដ្ឋាភិបាលកម្ពុជា ស្របតាមកាតព្វកិច្ចជាអន្តរជាតិរបស់ខ្លួន គប្បីផ្ដល់ការទទួលបានដំណោះស្រាយតាមប្រព័ន្ធតុលាការយ៉ាងមានប្រសិទ្ធភាព ចំពោះផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្ស និង សិទ្ធិកាន់កាប់តាមផ្លូវច្បាប់ ដោយបង្កឡើងដោយសហគ្រាសពាណិជ្ជកម្ម។ ប្រសិនបើជាប់ពាក់ព័ន្ធនឹងសាជីវកម្មឆ្លងប្រទេសនោះ រដ្ឋកំណើតរបស់ពួកគេមានតួនាទីផ្ដល់ជំនួយដល់ទាំងសាជីវកម្មទាំងនោះ និង រដ្ឋនៃប្រទេសម្ចាស់ផ្ទះ ដើម្បីធានាថា ធុរកិច្ចទាំងនោះមិនបានជាប់ពាក់ព័ន្ធនឹងការបំពានលើសិទ្ធិមនុស្ស និង សិទ្ធិកាន់កាប់តាមផ្លូវច្បាប់នោះទេ។ រដ្ឋគប្បីអនុវត្តវិធានការបន្ថែមដើម្បីការពារប្រឆាំងនឹងការបំពានលើសិទ្ធិមនុស្ស និង សិទ្ធិកាន់កាប់តាមផ្លូវច្បាប់ ដោយសហគ្រាសពាណិជ្ជកម្ម ដែលត្រូវបានកាន់កាប់ និង គ្រប់គ្រងដោយរដ្ឋ ឬ ដែលទទួលបានជំនួយ និង សេវាសំខាន់ៗពីទីភ្នាក់ងាររដ្ឋ។

# ២. ការហាមឃាត់ការបណ្ដេញចេញដោយបង្ខំ

១. ការបណ្ដេញចេញដោយបង្ខំ រួមមាន សកម្មភាព និង/ឬ ការមិនបំពេញកាតព្វកិច្ច ដែលជាប់ពាក់ព័ន្ធនឹងការចាកចេញដោយបង្ខំ ឬ ដោយមិនស្ម័គ្រចិត្តរបស់បុគ្គល ក្រុម និង សហគមន៍ ពីផ្ទះ និង/ឬ ដីធ្លី និង ធនធាននៃទ្រព្យសម្បត្តិទូទៅ ដែលត្រូវបានកាន់កាប់ ឬ អាស្រ័យផល ដូច្នេះបានលុបបំបាត់ ឬ ដាក់កម្រិតលើសមត្ថភាពរបស់បុគ្គល ក្រុម និង សហគមន៍នៅក្នុងការស្នាក់នៅ ឬ ធ្វើការនៅក្នុងលំនៅឋាន ទីលំនៅ ឬ ទីតាំងជាក់លាក់ណាមួយ ដោយមិនបានផ្ដល់ជូន និង ទទួលបានទម្រង់សមរម្យនៃការការពារតាមផ្លូវច្បាប់ ឬ ការការពារដទៃទៀត។

២. ការបណ្ដេញចេញដោយបង្ខំត្រូវបានហាមឃាត់នៅគ្រប់កាលៈទេសៈទាំងអស់ ដោយមិនគិតអំពីកម្មសិទ្ធិ ឬ ឋានៈនៃការកាន់កាប់របស់អ្នកដែលរងផលប៉ះពាល់នោះទេ។ គ្រប់ស្ថាប័នទាំងអស់នៃរាជរដ្ឋាភិបាលកម្ពុជា ចាប់ពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋាន ត្រូវតែធានាថា ពុំមានការបណ្ដេញចេញដោយបង្ខំបានកើតឡើងនៅក្នុងយុត្តាធិការរបស់ពួកគេរៀងៗខ្លួននោះទេ។

៣. ការបណ្ដេញចេញនឹងកើតឡើងតែនៅក្នុងករណីកាលៈទេសៈពិសេសតែប៉ុណ្ណោះ។ ពួកគេតម្រូវឱ្យមានយុត្តិកម្មយ៉ាងពេញលេញ និង ត្រូវតែះ

ក. អនុញ្ញាតដោយច្បាប់

ខ. អនុវត្តស្របតាមច្បាប់កម្ពុជាដែលមានស្រាប់ និង ស្របជាមួយបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ

គ. អនុវត្តសម្រាប់តែក្នុងគោលបំណងលើកកម្ពស់សុខមាលភាពសាធារណៈតែប៉ុណ្ណោះ ដោយចងភ្ជាប់អំពីកាតព្វកិច្ចសិទ្ធិមនុស្សរបស់ប្រទេសកម្ពុជា និង តម្រូវការក្នុងការការពារជនដែលងាយរងគ្រោះបំផុត។

ឃ. មានមូលហេតុសមរម្យ និង មានសមាមាត្រ

ង. ធ្វើនិយ័តកម្ម ដើម្បីធានាបាននូវសំណងពេញលេញ និងយុត្តិធម៌ និងការស្ដារនីតិសម្បទារ និង

ច. អនុវត្តស្របតាមគោលការណ៍ណែនាំទាំងនេះ។

៤. ការបណ្ដេញចេញពុំមានយុត្តិកម្មនោះទេ នៅពេលដែលពួកគេមិនបានរួមចំណែកដល់ការទទួលបានសិទ្ធិមនុស្ស។

# ៣. មុននឹងធ្វើការបណ្ដេញចេញ

## ៣.១. ដំណើរការនៃការសម្រេចចិត្ត

១. មុនពេលសម្រេចចិត្តចាប់ផ្ដើមធ្វើការបណ្ដេញចេញ អាជ្ញាធរពាក់ព័ន្ធគប្បីស្វែងរកអោយបានពេញលេញនូវជម្រើសដែលអាចកើតឡើងតាមរយៈការពិគ្រោះយោបល់ជាមួយជនដែលរងផលប៉ះពាល់ជាសក្ដានុពលទាំងអស់។ សិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការកាន់កាប់ ប្រើប្រាស់ អភិវឌ្ឍ និង គ្រប់គ្រងដីធ្លី ដែនដី និង ធនធានដែលពួកគេកាន់កាប់ គប្បីត្រូវបានគោរព និង ការពារ។

២. ការវាយតម្លៃផលប៉ះពាល់គ្រប់ជ្រុងជ្រោយ និង យ៉ាងពេញលេញ គប្បីត្រូវបានអនុវត្តមុនពេលចាប់ផ្ដើមគម្រោងណាមួយដែលអាចបណ្ដាលឱ្យមានការផ្លាស់ទីលំនៅ ការបណ្ដេញចេញ ឬ ការតាំងទីលំនៅថ្មី ។ ការវាយតម្លៃនោះគួរជូនដំណឹងអំពីការសម្រេចចិត្តលើការបណ្ដេញចេញ ព្រមទាំង ការកំណត់ជម្រើសជំនួសឱ្យការបណ្ដេញចេញផងដែរ។ ការវាយតម្លៃផលប៉ះពាល់ត្រូវតែគិតគូរពីផលប៉ះពាល់ខុសៗគ្នានៃការ

បណ្តេញចេញលើស្ត្រី បុរស កុមារ មនុស្សចាស់ និងវិស័យដែលខ្វះខាតនៅក្នុងសង្គម។ ការវាយតម្លៃទាំងអស់គប្បីផ្អែកលើការប្រមូលទិន្នន័យដែលត្រូវបានបែងចែករួចហើយ ដូច្នេះ ផលប៉ះពាល់ខុសៗគ្នាទាំងអស់នោះអាចត្រូវបានកំណត់ និង ដោះស្រាយបានត្រឹមត្រូវ។

៣. ប្រសិនបើការបណ្តេញចេញគឺមិនអាចជៀសវាងបាន អាជ្ញាធរដែលស្នើឱ្យមានការបណ្តេញចេញត្រូវតែបង្ហាញថា ការបណ្តេញចេញគឺមិនអាចជៀសវាងបាន និង បង្ហាញពីការប្តេជ្ញាចិត្ត អនុវត្តស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងស្តង់ការការពារសុខមាលភាពទូទៅ។

៤. អាជ្ញាធរពាក់ព័ន្ធដែលស្នើ និង ត្រួតពិនិត្យការបណ្តេញចេញគប្បីធានាថា ដំណើរការនៃការបណ្តេញចេញ និង ការតាំងទីលំនៅថ្មី ត្រូវបានអនុវត្តដោយមានការចូលរួមយ៉ាងពេញលេញពីសំណាក់អ្នកដែលរងផលប៉ះពាល់ ក្រុម និង សហគមន៍ រួមទាំងសហគមន៍នៃការតាំងទីលំនៅថ្មី និង សហគមន៍ជាម្ចាស់ទីតាំងផងដែរ។ គោលការណ៍នៃការយល់ព្រមដោយសេរី ជាមុន និង ដោយមានព័ត៌មានគ្រប់គ្រាន់ គប្បីត្រូវបានយកមកអនុវត្តនៅក្នុងដំណើរការនៃការសម្រេចចិត្ត។

៥. អាជ្ញាធរពាក់ព័ន្ធគប្បីរៀបចំកិច្ចប្រជុំពិគ្រោះយោបល់យ៉ាងហោចណាស់ចំនួនបីដង ដើម្បីធានាថាជនដែលរងផលប៉ះពាល់គ្រប់រូបយល់យ៉ាងច្បាស់អំពីការបណ្តេញចេញដែលត្រូវបានស្នើឡើង និង ផលវិបាករបស់វា និង មានពេលវេលា និង ឱកាសគ្រប់គ្រាន់នៅក្នុងការលើកឡើងអំពីកង្វល់របស់ពួកគេ និង ស្នើផែនការជំនួស។

៦. ត្រូវតែមានការយកចិត្តទុកដាក់ជាពិសេស ដើម្បីធានាថា ស្ត្រី បុរស ក្រុមស្រលាញ់ភេទដូចគ្នា និង មនុស្សភេទទីបីផ្សេងទៀត ដែលជាជនជាតិដើមភាគតិច ជនជាតិភាគតិច ជនគ្មានដីធ្លី កុមារ មនុស្សចាស់ និង ជនពិការ ឬ ជនដែលមានផ្ទុកមេរោគអេដស៍ ត្រូវបានតំណាង និង បានរួមបញ្ចូលនៅក្នុងដំណើរការនេះ។ នៅពេលដែលជនជាតិដើមភាគតិចទទួលរងផលប៉ះពាល់ នាយកដ្ឋានកិច្ចការជនជាតិភាគតិចនៃក្រសួងអភិវឌ្ឍន៍ជនបទ សហការជាមួយអាជ្ញាធរពាក់ព័ន្ធ គប្បីធានាថា សិទ្ធិ និង ផលប្រយោជន៍របស់សហគមន៍ជនជាតិដើមភាគតិចត្រូវបានការពារ។

៧. គ្រប់ផែនការជំនួសទាំងអស់ដែលត្រូវបានស្នើឡើងដោយបុគ្គល ក្រុម និង សហគមន៍ដែលរងផលប៉ះពាល់ គប្បីត្រូវបានយកមកពិចារណាឱ្យបានច្រើនបំផុតតាមដែលអាចធ្វើបាន។ បុគ្គលដែលរងផលប៉ះពាល់ត្រូវតែៈ

   ក. អាចមានឥទ្ធិពលដល់លទ្ធផលនៃដំណើរការ ធ្វើការសម្រេចចិត្ត ដោយផ្អែកលើការដឹងអំពីសិទ្ធិរបស់ពួកគេ និង

   ខ. មានសិទ្ធិទទួលបានព័ត៌មានដែលពាក់ព័ន្ធ និង មានពេលវេលាគ្រប់គ្រាន់ដើម្បីប្រឹក្សាពិគ្រោះយោបល់។

   ឧបសគ្គផ្នែកសេដ្ឋកិច្ចសង្គម ភាសា អក្ខរកម្ម និង ឧបសគ្គដទៃទៀតចំពោះការចូលរួមប្រកបដោយអត្ថន័យ ត្រូវតែបានដោះស្រាយមុនពេលប្រឹក្សាយោបល់។

៨. បុគ្គល ក្រុម និង សហគមន៍ដែលរងផលប៉ះពាល់ មានសិទ្ធិតវ៉ាចំពោះការជូនដំណឹងអំពីការបណ្តេញចេញ និង មានសិទ្ធិធ្វើការតំណាងតាមផ្លូវច្បាប់។ ពួកគេគួរទទួលបានជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬ អង្គការដទៃទៀតដែលផ្តល់ជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ។

៩. បន្ទាប់ពីមានការពិគ្រោះយោបល់ជាសាធារណៈយ៉ាងពេញលេញ និង យុត្តិធម៌ហើយ ការតាំងទីលំនៅថ្មីនឹងចាប់ផ្តើមដំណើរការ បុគ្គលក្រុម និង សហគមន៍ដែលរងផលប៉ះពាល់ត្រូវតែទទួលបានការជូនដំណឹងនូវរយៈពេលយ៉ាងតិច ៩០ ថ្ងៃមុនកាលបរិច្ឆេទនៃការតាំងទីលំនៅថ្មី។

១០. មុនពេលបណ្តេញចេញ ឬ មុនការតាំងទីលំនៅថ្មី អាជ្ញាធរដែលពាក់ព័ន្ធគប្បីធ្វើការវាយតម្លៃដោយឯករាជ្យអំពីសិទ្ធិកាន់កាប់ និង ការទាមទារដែលមានស្រាប់ ដោយមានការចូលរួមពីជនដែលរងផលប៉ះពាល់គ្រប់រូប រួមទាំងជនដែលមានសិទ្ធិកាន់កាប់តាមបែបប្រពៃណី និង សិទ្ធិកាន់កាប់មិនផ្លូវការ ព្រមទាំង សិទ្ធិ និង ជីវភាពរស់នៅរបស់ជនដែលរងផលប៉ះពាល់គ្រប់រូបផងដែរ។ ការវាយតម្លៃបែបនោះគប្បីជាមូលដ្ឋានសម្រាប់ការកំណត់តម្លៃយ៉ាងសុក្រឹត និង ការផ្តល់សំណងភ្លាមៗ។ ការកាន់កាប់មិនផ្លូវការ រួមមាន សិទ្ធិកាន់កាប់បន្ទាប់បន្សំ (សិទ្ធិកាន់កាប់បែបបុត្រសម្ព័ន្ធ) ដូចជា សិទ្ធិប្រមូលផ្តុំ ជាដើម។

## ៣.២. សេចក្តីជូនដំណឹងអំពីការបណ្តេញចេញ

១. អាជ្ញាធរពាក់ព័ន្ធគប្បីប្រកាសអំពីការសម្រេចចិត្តណាមួយ ដែលពាក់ព័ន្ធនឹងការបណ្តេញចេញ ជាលាយលក្ខណ៍អក្សរ ជាភាសាខ្មែរ និង/ឬជាភាសាជនជាតិដើមភាគតិចដែលសមរម្យ ដល់បុគ្គលគ្រប់រូបដែលពាក់ព័ន្ធឱ្យបានគ្រប់គ្រាន់ជាមុន។ នៅពេលអនក្ខរភាពកើតមានជាទូទៅ ឬ នៅពេលដែលមិនមានទម្រង់ជាលាយលក្ខណ៍អក្សរសម្រាប់ភាសាជនជាតិដើមភាគតិចទេនោះ អាជ្ញាធរមូលដ្ឋានគប្បីធានាថា អ្នកបកប្រែបានអានសេចក្តីជូនដំណឹងនោះ ដល់គ្រួសារដែលរងផលប៉ះពាល់ ដែលមិនអាចអាន ឬ និយាយខ្មែរបាន ។ នាយកដ្ឋានកិច្ចការជនជាតិភាគតិចនឹងជួយដល់ការធានាថានឹងមានវត្តមានរបស់អ្នកបកប្រែ។ សេចក្តីជូនដំណឹងអំពីការបណ្តេញចេញគប្បីមានមូលហេតុសមស្របឱ្យបានលម្អិតសម្រាប់ការសម្រេចចិត្ត ដែលរួមមានៈ

   ក. អវត្តមាននៃជម្រើសជំនួសយ៉ាងសមហេតុផល

   ខ. ព័ត៌មានលម្អិតយ៉ាងពេញលេញអំពីជម្រើសជំនួសដែលត្រូវបានស្នើឡើង និង

គ. ប្រសិនបើគ្មានជម្រើសជំនួសទេនោះ អនុវត្ត និង ប្រមើលមើលគ្រប់វិធានការទាំងអស់ ដើម្បីកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់អវិជ្ជមាននៃការបណ្តេញចេញ។

រាល់ការសម្រេចចិត្តចុងក្រោយគប្បីស្ថិតក្រោមការពិនិត្យផ្នែករដ្ឋបាល និង តុលាការ។ ភាគីដែលរងផលប៉ះពាល់ក៏ត្រូវតែទទួលបានការធានាថានឹងទទួលបានការប្រឹក្សាផ្នែកច្បាប់យ៉ាងទាន់ពេលវេលាដោយឥតគិតថ្លៃផងដែរ ប្រសិនបើចាំបាច់។

២. សេចក្តីជូនដំណឹងអំពីការបណ្តេញចេញគប្បីអនុញ្ញាត ឱ្យអ្នកដែលទទួលរងការបណ្តេញចេញអាចធ្វើបញ្ជីសារពើភ័ណ្ឌដើម្បីវាយតម្លៃអំពីទ្រព្យសម្បត្តិ ការវិនិយោគ និង ទំនិញសំខាន់ៗផ្សេងទៀតរបស់ពួកគេ ដែលអាចរងការខូចខាត។ អ្នកដែលទទួលរងការបណ្តេញចេញគប្បីទទួលបានឱកាសដើម្បីធ្វើការវាយតម្លៃ និង រៀបចំឯកសារនៃការខាតបង់ដែលមិនមែនជាសាច់ប្រាក់ដើម្បីផ្តល់ជាសំណង។

## ៣.៣. លក្ខខណ្ឌតម្រូវសម្រាប់កន្លែងផ្លាស់ទីលំនៅថ្មី

១. ការបណ្តេញចេញមិនគួរធ្វើឱ្យបុគ្គលទាំងឡាយប្រែជាគ្មានផ្ទះសម្បែង ឬ ក្លាយជាជនងាយរងគ្រោះដោយសារការរំលោភបំពានលើសិទ្ធិមនុស្សផ្សេងៗទៀត។ មុនពេលមានការបណ្តេញចេញ លំនៅឋានជំនួស ការតាំងទីលំនៅថ្មី ឬ ការទទួលបានដីធ្លីធ្វើផលិតកម្ម ត្រូវតែអាចស្វែងរកបាន និង ត្រូវបានផ្តល់ជូន។

២. គណៈកម្មាធិការអន្តរក្រសួង និងអនុគណៈកម្មាធិការរបស់ខ្លួន ដូចដែលបានរៀបរាប់នៅក្នុងផ្នែកទី១ កថាខណ្ឌទី៥ និងទី៦ គប្បីធានាថាមានការសម្របសម្រួលចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងការផ្តល់សេវាដែលចាំបាច់ត្រូវបានសម្របសម្រួល។ គណៈកម្មាធិការអន្តរក្រសួងគប្បីធ្វើការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរខេត្ត ក្រុង និង អាជ្ញាធរមូលដ្ឋានដើម្បីផ្តល់សេវាទាំងនេះ។

៣. គណៈកម្មាធិការអន្តរក្រសួង និង អនុគណៈកម្មាធិការរបស់ខ្លួន ត្រូវតែធានាថា ការតាំងទីលំនៅថ្មី បានការពារសិទ្ធិមនុស្សរបស់ស្ត្រី កុមារ ជនជាតិដើមភាគតិច និង ក្រុមដទៃទៀតដែលស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះស្មើៗគ្នា រួមទាំងសិទ្ធិរបស់ពួកគេ ដែលពាក់ព័ន្ធនឹងកម្មសិទ្ធិលើទ្រព្យសម្បត្តិ និង ការទទួលបានធនធាន និង ការចិញ្ចឹមជីវិត។

៤. អាជ្ញាធរពាក់ព័ន្ធដែលស្នើ និង/ឬ អនុវត្តការតាំងទីលំនៅថ្មី ត្រូវបានតម្រូវដោយច្បាប់ឱ្យទូទាត់ថ្លៃចំណាយដែលពាក់ព័ន្ធ រួមទាំងចំណាយលើការតាំងទីលំនៅថ្មីទាំងអស់ បន្ថែមពីលើសំណងសមរម្យ និងយុត្តិធម៌។ ក្រុមហ៊ុនឯកជន ដែលគម្រោងអភិវឌ្ឍន៍របស់ពួកគេគឺជាដើមហេតុនៃការផ្លាស់ទីលំនៅ ត្រូវបានស្នើសុំឱ្យរួមចំណែករ៉ាប់រងក្នុងការចំណាយ។

៥. ពុំមានបុគ្គល ក្រុម ឬ សហគមន៍ដែលរងផលប៉ះពាល់ណាមួយត្រូវទទួលរងការខូចខាត ដរាបណាសិទ្ធិក្នុងការធ្វើឱ្យប្រសើរឡើងជាបន្តបន្ទាប់ឥតដាច់នៃជីវភាពរស់នៅរបស់ពួកគេ នៅតែជាក្តីកង្វល់ ប្រឈមនឹងការរំលោភបំពាន។ ចំណុចនេះអនុវត្តស្មើៗគ្នាចំពោះសហគមន៍ដែលជាម្ចាស់កន្លែងតាំងទីលំនៅថ្មី និង បុគ្គល ក្រុម និង សហគមន៍ដែលរងការបណ្តេញចេញដោយបង្ខំ។

៦. នៅពេលជ្រើសរើសកន្លែងផ្លាស់ទីលំនៅថ្មី គណៈកម្មាធិការអន្តរក្រសួង និង អនុគណៈកម្មាធិការរបស់ខ្លួនគប្បីពិចារណាអំពីកត្តានានាដូចខាងក្រោម៖

ក. ផែនការជំនួសណាមួយដែលត្រូវបានស្នើឡើងដោយជន ក្រុម និងសហគមន៍ដែលរងផលប៉ះពាល់

ខ. កន្លែងផ្លាស់ទីលំនៅគប្បីនៅជិតទីតាំងចាស់បំផុតទៅតាមដែលអាចធ្វើបាន ដើម្បីការពារ បណ្តាញសង្គមដែលមានស្រាប់ ទំនាក់ទំនងនៅក្នុងសហគមន៍ និង ប្រភពនៃការចិញ្ចឹមជីវិត។ ប្រសិនបើអាចធ្វើបាន គ្រួសារដែលបានតាំងទីលំនៅថ្មី គប្បីផ្លាស់ទីលំនៅនៅក្នុងភូមិ ឬ ឃុំនៃទីលំនៅដើមរបស់ពួកគេ

គ. កន្លែងតាំងទីលំនៅថ្មីគប្បីស្ថិតនៅជិតសាលារៀន មន្ទីរពេទ្យ និង ឱកាសការងារ

ឃ. គប្បីមានដីរដ្ឋសម្រាប់កែប្រែទៅជាកន្លែងតាំងទីលំនៅថ្មី

ង. គប្បីមានការពិគ្រោះយោបល់ជាមួយសហគមន៍ដែលជាម្ចាស់កន្លែង ដើម្បីវាយតម្លៃពីវិសាលភាពនៃការទទួលយករបស់ពួកគេចំពោះគ្រួសារដែលបានតាំងទីលំនៅថ្មី

ច. កន្លែងនោះគប្បីមានលទ្ធភាពទទួលបានស្បៀងអាហារ ទឹក អនាម័យ អគ្គិសនី និង មធ្យោបាយដឹកជញ្ជូន

ឆ. ពេលវេលា និង ចំណាយផ្នែកហិរញ្ញវត្ថុដែលត្រូវការសម្រាប់ធ្វើដំណើរទៅមកពីកន្លែងធ្វើការ ឬ ដើម្បីទទួលបានសេវាសំខាន់ៗ មិនគួរមានការទាមទារហួសហេតុលើមធ្យោបាយផ្នែកហិរញ្ញវត្ថុនៃគ្រួសារដែលមានប្រាក់ចំណូលទាបនោះទេ។

ជ. កន្លែងតាំងទីលំនៅថ្មីមិនត្រូវស្ថិតនៅលើដីធ្លីដែលមានការបំពុល ឬ នៅជិតប្រភពនៃការបំពុល ឬ សារធាតុដែលមានគ្រោះថ្នាក់

ឈ. ចំពោះសហគមន៍ដែលពឹងផ្អែកលើកសិកម្ម និង ការធ្វើស្រែចម្ការ កន្លែងផ្លាស់ទីលំនៅគួររួមបញ្ចូលដីធ្លីដែលមានជីជាតិ សមស្របតាមទំហំ និង គុណភាពសម្រាប់ការធ្វើកសិកម្ម និង ការចិញ្ចឹមសត្វ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ គប្បីត្រូវបាន បញ្ចូលនៅក្នុងដំណើរការជ្រើសរើសសម្រាប់ដីធ្លីប្រភេទនេះ និង

ញ. ក្នុងករណីរបស់សហគមន៍ជនជាតិដើមភាគតិច ដីដែលត្រូវបានផ្តល់ជូនត្រូវមានលក្ខណៈសមស្របតាមបែបវប្បធម៌ និង ទទួលស្គាល់អំពីសាសនា និងទំនៀមទំលាប់ប្រពៃណីរបស់ពួកគេ រួមទាំងគោរពដីបញ្ចុះសព ដី/ព្រៃអារក្ស និង ទម្លាប់អនុវត្តចំការវិលជុំរបស់ពួកគេ។

៧. ការសម្រេចចិត្តអំពីទីកន្លែងសម្រាប់បង្កើតកន្លែងតាំងទីលំនៅថ្មី ត្រូវបានធ្វើឡើងដោយមានការចូលរួម និង មានធាតុចូលរបស់អាជ្ញាធរមូលដ្ឋានដែលទទួលខុសត្រូវចំពោះភូមិ ឃុំ និង ស្រុកនៃកន្លែងដែលត្រូវបានស្នើឡើងនោះ ដើម្បីធានាថា៖
   ក. តំបន់ដែលត្រូវបានស្នើឡើងសម្រាប់កន្លែងតាំងទីលំនៅថ្មីនឹងមិនដកហូតការកាន់កាប់ដីធ្លី និង សិទ្ធិលើទ្រព្យសម្បត្តិដទៃទៀត និង សិទ្ធិកម្មសិទ្ធិពីសហគមន៍ដែលមានស្រាប់ឡើយ
   ខ. អាជ្ញាធរមូលដ្ឋានមានឆន្ទៈ និង រៀបចំជាស្រេចដើម្បីទទួលយកគ្រួសារដែលបានតាំងទីលំនៅថ្មី
   គ. អាជ្ញាធរមូលដ្ឋានអាចត្រួតពិនិត្យការរៀបចំកន្លែងតាំងទីលំនៅថ្មីបាន
   ឃ. អាជ្ញាធរមូលដ្ឋានអាចជួយសម្រួលដល់ការធ្វើសមាហរណកម្មនៃគ្រួសារដែលបានតាំងទីលំនៅថ្មី ជាមួយសហគមន៍ជាម្ចាស់ និង
   ង. អាជ្ញាធរមូលដ្ឋានត្រូវបានផ្តល់ជូននូវធនធានមនុស្ស និង ធនធានហិរញ្ញវត្ថុដែលចាំបាច់ដើម្បីសំរេចបាននូវការទទួលខុសត្រូវខាងលើ។

៨. គណៈកម្មាធិការអន្តរក្រសួងគប្បីធានាថា កន្លែងផ្លាស់ទីលំនៅដែលត្រូវបានកំណត់ បានបំពេញតាមលក្ខណវិនិច្ឆ័យសម្រាប់លំនៅឋានសមរម្យ ស្របតាមបទដ្ឋាន និងស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ។ លក្ខណវិនិច្ឆ័យទាំងនេះ រួមមាន៖
   ក. សុវត្ថិភាពនៃការកាន់កាប់
   ខ. ភាពអាចទទួលបានសេវាកម្ម សម្ភារៈ អាគារ ឬកន្លែងផ្តល់សេវា និង ហេដ្ឋារចនាសម្ព័ន្ធ ដូចជា ទឹកពិសារមានសុវត្ថិភាព ថាមពលគ្រប់គ្រាន់សម្រាប់ចម្អិនម្ហូបអាហារ ប្រព័ន្ធកម្តៅ និង ឧបករណ៍សំរាប់បំភ្លឺ អនាម័យ និង សម្ភារៈលាងសម្អាត មធ្យោបាយសម្រាប់រក្សាទុកស្បៀងអាហារ កន្លែងចាក់កាកសំណល់ ប្រព័ន្ធបង្ហូរទឹកនៅលើទីតាំង និង សេវាសង្គ្រោះបន្ទាន់ និង ធនធានធម្មជាតិ និង ធនធានទូទៅប្រសិនបើសមស្រប
   គ. លំនៅឋានដែលមានតម្លៃសមរម្យ
   ឃ. លំនៅឋានដែលអាចរស់នៅបាន ដែលផ្តល់ជូនអ្នកស្នាក់នៅនូវទីធ្លាគ្រប់គ្រាន់ ការការពារពីភាពត្រជាក់ សំណើម កម្តៅ ទឹកភ្លៀង ខ្យល់ និងស្ថានភាពដទៃទៀតដែលគំរាមកំហែងដល់សុខភាព គ្រោះថ្នាក់នៃគ្រឿងបង្កុំ និងភ្នាក់ងារចម្លងជំងឺ និងធានាចំពោះសុវត្ថិភាពផ្លូវកាយរបស់អ្នកកាន់កាប់
   ង. មធ្យោបាយងាយស្រួល សម្រាប់ក្រុមជនទន់ខ្សោយ រួមទាំងជនពិការ
   ច. ការទទួលបានជម្រើសការងារ សេវាថែទាំសុខភាព សាលារៀន មណ្ឌលថែទាំកុមារ និង បរិក្ខារសម្រួលផ្នែកសង្គមកិច្ចដទៃទៀត មិនថានៅក្នុងទីក្រុង ឬ ជនបទ និង
   ឆ. លំនៅឋានដែលមានភាពសមស្របតាមបែបវប្បធម៌។

៩. គណៈកម្មាធិការអន្តរក្រសួង និង អាជ្ញាធរមូលដ្ឋានដែលពាក់ព័ន្ធគប្បីធានាថាសុវត្ថិភាពលំនៅឋាន នៅកន្លែងតាំងទីលំនៅថ្មីដែលបានកំណត់ដោយរួមបញ្ចូលធាតុសំខាន់ៗនៃលំនៅឋានសមរម្យ ដូចខាងក្រោម៖
   ក. ឯកជនភាព និង សុវត្ថិភាពលំនៅឋានខ. ការចូលរួមរបស់សមាជិកគ្រួសារដែលរងផលប៉ះពាល់នៅក្នុងការសម្រេចចិត្តអំពីបញ្ហាដែលប៉ះពាល់ដល់សុវត្ថិភាពនៃការកាន់កាប់ និង កម្រិតជីវភាពរស់នៅសមរម្យ
   គ. សមាជិកគ្រួសារដែលរងផលប៉ះពាល់នៅកន្លែងតាំងទីលំនៅថ្មី ត្រូវបានការការពារប្រឆាំងនឹងអំពើហិង្សា និង
   ឃ. បុគ្គលដែលរងផលប៉ះពាល់ទទួលបានដំណោះស្រាយចំពោះការរំលោភបំពានណាមួយ ដែលពួកគេបានទទួលរង។

# ៤. ការអនុវត្តការបណ្តេញចេញ

១. មន្ត្រីរដ្ឋាភិបាល ឬ តំណាងរបស់ពួកគេត្រូវតែនៅលើទីតាំងក្នុងអំឡុងពេលបណ្តេញចេញ។ ពួកគេត្រូវតែណែនាំខ្លួនពួកគេទៅកាន់ជនដែលត្រូវបណ្តេញចេញ និង បង្ហាញសេចក្តីអនុញ្ញាតជាផ្លូវការសម្រាប់ការបណ្តេញចេញ។ ការបណ្តេញចេញដែលត្រូវបានអនុវត្តស្របតាមសេចក្តីសម្រេចរបស់តុលាការមានសមត្ថកិច្ច គប្បីត្រូវបានត្រួតពិនិត្យដោយព្រះរាជអាជ្ញាដែលពាក់ព័ន្ធ និង អនុវត្តដោយមន្ត្រីនគរបាលយុត្តិធម៌ ដូចបានកំណត់នៅក្នុងមាត្រា ៦០(១) និង មាត្រា ៦០(២) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។ មិនគួរប្រើប្រាស់កងកម្លាំងយោធា និង កងកម្លាំងនគរបាលក្រៅផ្លូវការដើម្បីអនុវត្តការបណ្តេញចេញនោះទេ។
២. អ្នកអង្កេតការណ៍អព្យាក្រឹត រួមទាំងអង្គការសង្គមស៊ីវិល អ្នកអង្កេតការណ៍ប្រចាំតំបន់ និង អន្តរជាតិ គប្បីទទួលបានការអនុញ្ញាតអោយចូលរួមតាមការស្នើសុំ ដើម្បីធានានូវតម្លាភាព និង អនុលោមភាពតាម បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិក្នុងអំឡុងពេលនៃការបណ្តេញចេញណាមួយ។
៣. ការបណ្តេញចេញមិនត្រូវអនុវត្តក្នុងលក្ខណៈដែលរំលោភបំពានលើសេចក្តីថ្លៃថ្នូរ និង សិទ្ធិមនុស្សចំពោះការរស់រានមានជីវិត និង សន្តិសុខរបស់បុគ្គលដែលរងផលប៉ះពាល់នោះទេ។ គ្មាននណាម្នាក់ រួមទាំង ស្ត្រី បុរស អ្នកស្រឡាញ់ភេទដូចគ្នា និង មនុស្សភេទទីបីផ្សេងទៀត អាចជាកម្មវត្ថុទទួលរងអំពើហិង្សា និង ការរើសអើងផ្អែកលើយេនឌ័រ ក្នុងអំឡុងនៃការបណ្តេញចេញនោះទេ ហើយសិទ្ធិរបស់កុមារគប្បីត្រូវបានការពារ។
៤. រាល់ការប្រើប្រាស់កម្លាំងរបស់នគរបាលយុត្តិធម៌ ដែលកំពុងតែអនុវត្តការបណ្តេញចេញត្រូវតែគោរពគោលការណ៍នៃភាពចាំបាច់ និង ភាពសមាមាត្រ ព្រមទាំងគោលការណ៍ជាមូលដ្ឋានស្តីពីការប្រើកម្លាំង និង អាវុធដោយមន្ត្រីអនុវត្តច្បាប់។

៥. ការបណ្តេញចេញមិនត្រូវធ្វើឡើងក្នុងអាកាសធាតុមិនល្អ នៅពេលយប់ ក្នុងអំឡុងពេលមានពិធីបុណ្យ ឬ នៅថ្ងៃឈប់សម្រាកតាមបែបសាសនា ក្នុងអំឡុងពេលមានជំងឺរាតត្បាតសកល មុនពេលបោះឆ្នោត ឬ ក្នុងអំឡុងពេល ឬ មុនពេលប្រឡងនៅសាលារៀន។
៦. គ្មាននរណាម្នាក់ត្រូវទទួលរងការវាយប្រហារដោយផ្ទាល់ ឬ ដោយមិនរើសមុខ ឬ ទង្វើហិង្សាដទៃទៀត ជាពិសេសហិង្សាលើអ្នកដែលស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះ ឬ ការដកហូតទ្រព្យសម្បត្តិ ឬ ភោគៈ ដែលជាលទ្ធផលនៃការកម្ទេចចោល ការបង្កអគ្គិភ័យ និង ទម្រង់ផ្សេងទៀតនៃការបំផ្លាញដោយចេតនា ការមិនអើពើ ឬ ទម្រង់ណាមួយនៃការដាក់ទណ្ឌកម្មជាសមូហភាពនោះទេ។ ទ្រព្យសម្បត្តិ និង ភោគៈដែលត្រូវទុកចោលដោយមិនស្ម័គ្រចិត្ត គប្បីត្រូវបានការពារ ប្រឆាំងនឹងការបំផ្លាញ និង ការដកហូតដោយខុសច្បាប់ ការកាន់កាប់ ឬ ការប្រើប្រាស់តាមអំពើចិត្ត និង មិនស្របច្បាប់។
៧. អ្នកដែលត្រូវបានបណ្តេញចេញមិនគួរត្រូវបានតម្រូវឱ្យរុះរើលំនៅឋានផ្ទាល់ខ្លួន ឬសំណង់ផ្សេងទៀតឡើយ។ ជម្រើសដែលត្រូវផ្តល់ជូនអោយអ្នកដែលរងផលប៉ះពាល់ ត្រូវសង្គ្រោះទ្រព្យសម្បត្តិ និងនិង សម្ភារៈសាងសង់។

# ៥. សេវាដែលនឹងត្រូវផ្តល់ជូនក្រោយពេលបណ្តេញចេញ

១. គណៈកម្មាធិការអន្តរក្រសួង និង អនុគណៈកម្មាធិការរបស់ខ្លួន គប្បីផ្តល់សំណងសមរម្យ និង កន្លែងស្នាក់នៅជំនួសឱ្យបានគ្រប់គ្រាន់ ឬ សំណងនៅពេលដែលអាចធ្វើទៅបាន ភ្លាមៗនៅពេលមានការ បណ្តេញចេញ លើកលែងតែក្នុងករណីប្រធានស័ក្តិ។
២. ក្រសួងសុខាភិបាល តាមរយៈមណ្ឌលសុខភាព ឃុំ មន្ទីរពេទ្យបង្អែកស្រុក និង/ឬ ខេត្ត គប្បីត្រួតពិនិត្យការផ្តល់ការថែទាំផ្នែកវេជ្ជសាស្ត្រ និង យកចិត្តទុកដាក់ចំពោះជនដែលត្រូវបានបណ្តេញចេញ ដែលបានរងរបួស និង មានជំងឺ ស្ត្រីមានផ្ទៃពោះ ក៏ដូចជាជនពិការ ជនពិការ ដើម្បីអាចអនុវត្តបានពេញលេញ និង ជាមួយការពន្យារពេលតិចបំផុតតាមដែលអាចធ្វើទៅបាន ដោយគ្មានការបែងចែកដោយផ្អែកលើមូលហេតុដែលមិនពាក់ព័ន្ធនឹងផ្នែកវេជ្ជសាស្ត្រ។ នៅពេលដែលចាំបាច់ អ្នកដែលត្រូវបានបណ្តេញចេញ គប្បីបានទទួលសេវាចិត្តសាស្ត្រ និង សង្គមកិច្ច។ គប្បីមានការយកចិត្តទុកដាក់ជាពិសេសលើៈ
   ក. តម្រូវការផ្នែកសុខភាពរបស់ស្ត្រី និង កុមារី រួមទាំង ការជួបជាមួយអ្នកផ្តល់ការថែទាំសុខភាពស្ត្រី ប្រសិនបើចាំបាច់ និង ទទួលបានសេវានានាដូចជា ការថែទាំសុខភាពផ្លូវភេទ និង ការបន្តពូជ និង ការប្រឹក្សាយ៉ាងសមស្រប សម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទ និង អំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ
   ខ. តម្រូវការសុខភាពខុសៗគ្នារបស់ជនទាំងឡាយដែលស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះ រួមទាំង កុមារ មនុស្សចាស់ ជនពិការ និង អ្នកដែលមានសុខភាពមិនល្អ
   គ. ធានាថា មិនរំខានដល់ការព្យាបាលជំងឺដែលកំពុងតែដំណើរការ ដោយសារតែការបណ្តេញចេញ ឬ ការផ្លាស់ទីលំនៅនោះទេ និង
   ឃ. ការបង្ការជំងឺឆ្លងតាមរយៈការទាក់ទងគ្នា និង ជំងឺឆ្លងតាមរយៈភ្នាក់ងារចម្លងរោគ រួមទាំង មេរោគអេដស៍/អេដស៍ផងដែរ នៅកន្លែងផ្លាស់ទីលំនៅ។
៣. សមាជិកគ្រួសារធំ ឬ សហគមន៍តែមួយ មិនគួរត្រូវបានបំបែកចេញពីគ្នា ដោយសារតែការបណ្តេញចេញនោះទេ។
៤. គោលនយោបាយស្តារឡើងវិញ ត្រូវរួមបញ្ចូលកម្មវិធីនានាដែលបង្កើតឡើងសម្រាប់ស្ត្រី និង ក្រុមដែលគេមិនអើពើ និង ក្រុមងាយរងគ្រោះ ដើម្បីធានាចំពោះការទទួលបានស្មើៗគ្នានូវសិទ្ធិមនុស្សក្នុងការមានលំនៅឋាន, ស្បៀងអាហារ, ទឹក, សុខភាព, ការអប់រំ ការងារ, សន្តិសុខមនុស្ស, សុវត្ថិភាពលំនៅឋាន, ការរួចផុតពីការប្រព្រឹត្តដោយឃោរឃៅអមនុស្សធម៌ ឬ មាក់ងាយ, មជ្ឈដ្ឋានដែលមានសុវត្ថិភាព ស្អាត និង មានសុខភាពល្អ និង សេរីភាពក្នុងការផ្លាស់ទី។ គណៈកម្មាធិការអន្តរក្រសួងគប្បីធានាថាកិច្ចខិតខំប្រឹងប្រែងផ្តល់សេវាទាំងនេះត្រូវបានសម្របសម្រួល។
៥. បុគ្គល ក្រុម ឬ សហគមន៍ដែលទទួលរងផលប៉ះពាល់ដោយសារការបណ្តេញចេញ មិនគួរទទួលរងការបំពានលើសិទ្ធិមនុស្សរបស់ពួកគេនោះទេ រួមទាំងសិទ្ធិរបស់ពួកគេក្នុងការសម្រេចបាននូវវឌ្ឍនភាពនៃសិទ្ធិទទួលបានលំនៅឋានសមរម្យ។ ចំណុចនេះអនុវត្តស្មើៗគ្នាចំពោះសហគមន៍នានាដែលជាម្ចាស់កន្លែងផ្លាស់ទីលំនៅ។
៦. ជនគ្រប់រូបដែលត្រូវបានគំរាមកំហែងដោយ ឬ ទទួលរងនូវការបណ្តេញចេញដោយបង្ខំ មានសិទ្ធិទទួលបានដំណោះស្រាយទាន់ពេលវេលា។ ដំណោះស្រាយដែលសមស្របរួមមានៈ
   ក. សវនាការដ៏យុត្តិធម៌
   ខ. ការទទួលបានការប្រឹក្សាផ្នែកច្បាប់ ឬ ជំនួយផ្នែកច្បាប់
   គ. សំណងសមរម្យ និង យុត្តិធម៌
   ឃ. បដិទាន និង ការត្រឡប់មកវិញ និង
   ង. ការតាំងទីលំនៅថ្មី ។

   ដំណោះស្រាយគួរអនុលោមតាមគោលការណ៍ជាមូលដ្ឋាន និង គោលការណ៍ណែនាំអំពីសិទ្ធិទទួលបានដំណោះស្រាយ និង សំណងសម្រាប់ជនរងគ្រោះដោយសារបំពានលើសិទ្ធិមនុស្សអន្តរជាតិយ៉ាងធ្ងន់ធ្ងរ និង ការបំពានលើច្បាប់មនុស្សធម៌អន្តរជាតិយ៉ាងធ្ងន់ធ្ងរ។

## ៥.១. គោលការណ៍ណែនាំសម្រាប់ការកំណត់សំណងដោយយុត្តិធម៌

១. នៅពេលដែលការបណ្តេញចេញ មិនអាចជៀសវាងបាន និង មានភាពចាំបាច់ចំពោះការលើកកម្ពស់សុខមាលភាពទូទៅ សំណងសមរម្យ និង យុត្តិធម៌ សមស្របសម្រាប់ការខាតបង់ទ្រព្យសម្បត្តិ ឬ ទំនិញផ្ទាល់ខ្លួន ជាក់ស្តែង ឬ ទ្រព្យសម្បត្តិ ឬ ទំនិញដទៃទៀត រួមទាំងសិទ្ធិ ឬ ផលប្រយោជន៍លើទ្រព្យសម្បត្តិផងដែរ គប្បីត្រូវបានធានា។ គណៈកម្មាធិការអន្តរក្រសួង និង អនុ-គណៈកម្មាធិការរបស់ខ្លួនគប្បីទទួលខុសត្រូវចំពោះគ្រប់បញ្ហាទាំងអស់ដែលទាក់ទងនឹងសំណង។ សំណងគប្បីត្រូវបានផ្តល់ជូនសម្រាប់ការខូចខាតណាមួយ ដែលអាចវាយតម្លៃបានតាមបែបសេដ្ឋកិច្ច តាមភាពសមស្រប និង សមាមាត្រទៅនឹងទម្ងន់នៃការរំលោភបំពាន និង កាលៈទេសៈរបស់ករណីនីមួយៗ ដូចជា៖
   - ក. ការបាត់បង់ជីវិត ឬ អវយវៈ
   - ខ. ការប៉ះទង្គិចផ្លូវកាយ ឬ ផ្លូវចិត្ត
   - គ. ការបាត់បង់ឱកាស រួមទាំង ការងារ ការអប់រំ និង អត្ថប្រយោជន៍សង្គមកិច្ចផងដែរ
   - ឃ. ការខូចខាតធ្ងន់ធ្ងរ និង ការបាត់បង់ប្រាក់ចំណូល រួមទាំង ការបាត់បង់សក្តានុពលក្នុងការស្វែងរកប្រាក់ចំណូលផងដែរ
   - ង. ការខាតបង់ ឬ ការខូចខាតដែលមិនទាក់ទងនឹងផ្នែកសេដ្ឋកិច្ច និង
   - ច. សោហ៊ុយដែលចាំបាច់សម្រាប់ជំនួយផ្នែកច្បាប់ ឬ អ្នកជំនាញ ឱសថ និង សេវាព្យាបាលជំងឺ និង សេវាចិត្តសាស្ត្រ និង សង្គមកិច្ច។

២. សំណងជាសាច់ប្រាក់មិនគួរជំនួសឱ្យសំណងជាក់ស្តែងនៅក្នុងទម្រង់ជាដីធ្លី និង ធនធានទ្រព្យសម្បត្តិទូទៅនោះទេ។ នៅពេលដែលមានការយកដីធ្លី ជនដែលត្រូវគេបណ្តេញចេញ គប្បីទទួលបានសំណងជាដីធ្លីដែលមានគុណភាព ទំហំ និង តម្លៃសមមាត្រគ្នា ឬ ប្រសើរជាងមុន។

៣. ជនដែលត្រូវគេបណ្តេញចេញគ្រប់រូប ដោយមិនគិតថាតើពួកគេមានប័ណ្ណកម្មសិទ្ធិលើទ្រព្យសម្បត្តិរបស់ពួកគេ ឬ អត់នោះទេ គប្បីមានសិទ្ធិទទួលបានសំណងសម្រាប់ការបាត់បង់ ការសង្គ្រោះ និង ការដឹកជញ្ជូនទ្រព្យសម្បត្តិរបស់ពួកគេ ដែលបានទទួលរងផលប៉ះពាល់ រួមទាំង លំនៅឋាន និង ដីធ្លីដើម ដែលត្រូវបានបាត់បង់ ឬ រងការខូចខាតនៅក្នុងដំណើរការនេះ។ ការពិចារណាអំពីកាលៈទេសៈនៃករណីនីមួយៗ ត្រូវតែអនុញ្ញាតឱ្យមានការផ្តល់សំណងសម្រាប់ការបាត់បង់ទាក់ទងនិងការកាន់កាប់អចលនៈទ្រព្យក្រៅផ្លូវការ ដូចជា លំនៅឋានអាណាធិបតេយ្យ ការបរបាញ់សត្វ ការនេសាទ និង សិទ្ធិប្រមូលយកធនធាន។

៤. ស្ត្រី និង បុរសដែលជាស្វាមី/ភរិយាត្រូវតែជាអ្នកទទួលផលរួមគ្នាលើកញ្ចប់សំណងទាំងអស់។ ស្ត្រីនៅលីវ និង ស្ត្រីមេម៉ាយគប្បីមានសិទ្ធិទទួលបានសំណងផ្ទាល់ខ្លួនរបស់ពួកគេ។

៥. ចំពោះវិសាលភាពដែលមិនត្រូវបានគ្របដណ្តប់ដោយជំនួយសម្រាប់ការផ្លាស់ទីលំនៅ ការវាយតម្លៃអំពីការខូចខាតផ្នែកសេដ្ឋកិច្ច គួរតែគិតគូរដល់ការខាតបង់ និង សោហ៊ុយចំណាយនានា ឧទាហរណ៍៖ ការបាត់បង់ដីធ្លី និង ការខូចខាតសម្ភារៈ ផ្ទះសម្បែង ហេដ្ឋារចនាសម្ព័ន្ធ ការដាក់បញ្ចាំ ឬ ការផាកពិន័យលើបំណុលផ្សេងទៀត លំនៅឋានបណ្តោះអាសន្ន ថ្លៃសេវារដ្ឋបាល និង សេវាផ្លូវច្បាប់ លំនៅឋានជំនួស ការបាត់បង់ប្រាក់ឈ្នួល និង ប្រាក់ចំណូល បាត់បង់ឱកាសទទួលបានការអប់រំ ការថែទាំសុខភាព និង ការព្យាបាលជំងឺ សោហ៊ុយចំណាយសំរាប់ការដឹកជញ្ជូន (ជាពិសេស ក្នុងករណីផ្លាស់ទីលំនៅទៅឆ្ងាយពីប្រភពចិញ្ចឹមជីវិត)។ ដីធ្លី ផ្ទះសម្បែង ក៏ជាប្រភពនៃជីវភាពដែលត្រូវបានផ្តល់ជូនដល់អ្នកដែលត្រូវបានបណ្តេញចេញ ការវាយតម្លៃអំពីផលប៉ះពាល់ និង ការខាតបង់ ត្រូវតែគិតគូរបូកសរុបតម្លៃនៃការខាតបង់ផ្នែកអាជីវកម្ម បរិក្ខារ/សារពើភ័ណ្ឌ ការចិញ្ចឹមសត្វ ការដាំដុះដើមឈើ/ផលដំណាំ និង ប្រាក់ឈ្នួល/ប្រាក់ចំណូលដែលទទួលបានតាមរយៈការធ្វើការនៅក្នុងវិស័យផ្លូវការ និង មិនផ្លូវការ ដែលត្រូវបានបាត់បង់/ថយចុះ។

## ៥.២. បដិទាន និង ការវិលត្រឡប់មកវិញ

១. នៅពេលដែលកាលៈទេសៈអនុញ្ញាត ដូចជា នៅពេលដែលសម្បទានដីសេដ្ឋកិច្ចដែលបានបណ្តាលឱ្យមានការបណ្តេញចេញនោះ ត្រូវបានលុបចោល ឬ បោះបង់ចោល រាជរដ្ឋាភិបាលកម្ពុជាគប្បីផ្តល់អាទិភាពដល់ការវិលត្រឡប់របស់ក្រុម និង សហគមន៍ដែលត្រូវបានបណ្តេញចេញ ទៅកាន់ទីតាំងដើមរបស់ពួកគេវិញ ហើយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ត្រូវតែធានាចំពោះសុវត្ថិភាពនៃការកាន់កាប់ ក្រោយពេលវិលត្រឡប់របស់ពួកគេ។ ទោះបីជាយ៉ាងណាក៏ដោយ បុគ្គល ក្រុម និង សហគមន៍ទាំងនោះមិនត្រូវបានបង្ខំឱ្យត្រឡប់ទៅផ្ទះ ដីធ្លី ឬ កន្លែងដើមរបស់ពួកគេវិញ ដោយផ្ទុយពីឆន្ទៈរបស់ពួកគេនោះទេ។

២. នៅពេលដែលការវិលត្រឡប់មកវិញ អាចធ្វើទៅបាន ឬ ការតាំងទីលំនៅដែលសមរម្យ ដែលអនុលោមតាមគោលការណ៍ណែនាំទាំងនេះមិនត្រូវបានផ្តល់ជូនទេនោះ អាជ្ញាធរមានសមត្ថកិច្ចគប្បីបង្កើតលក្ខខណ្ឌ និង ផ្តល់មធ្យោបាយនានា រួមទាំងមធ្យោបាយផ្នែកហិរញ្ញវត្ថុផងដែរ សម្រាប់ការវិលត្រឡប់ដោយស្ម័គ្រចិត្ត ប្រកបដោយសុវត្ថិភាព និង សន្តិសុខ និង សេចក្តីថ្លៃថ្នូរ ទៅកាន់ផ្ទះ ឬ លំនៅឋានធម្មតារបស់ពួកគេវិញ។ អាជ្ញាធរពាក់ព័ន្ធគួរជួយសម្រួលដល់ការធ្វើសមាហរណកម្ម នៃអ្នកដែលបានបញ្ជូនត្រលប់មកវិញ និង ខិតខំប្រឹងប្រែងធានាថាមានការចូលរួមយ៉ាងពេញលេញពីសំណាក់ជន ក្រុម និង សហគមន៍ដែលទទួលរងផលប៉ះពាល់ក្នុងការធ្វើផែនការ និង ការគ្រប់គ្រងដំណើរការក្នុងការវិលត្រឡប់មកវិញ។ អាចនឹងតម្រូវឱ្យមានវិធានការពិសេសៗដើម្បីធានាចំពោះការចូលរួមប្រកប ដោយសមភាព និង យ៉ាងមានប្រសិទ្ធភាពរបស់ស្ត្រីនៅក្នុងដំណើរការវិលត្រឡប់ ឬ ដំណើរការផ្តល់បដិទាន ដើម្បីយកឈ្នះលើភាពលម្អៀងរបស់គ្រួសារ សហគមន៍ ស្ថាប័ន រដ្ឋបាល ច្បាប់ ឬ ភាពលម្អៀងផ្នែកយេនឌ័រដទៃទៀត ដែលរួមចំណែកដល់ការរើសអើង ឬ ការផាត់ស្ត្រីចេញ។

៣. អាជ្ញាធរពាក់ព័ន្ធមានភារកិច្ច និង ទំនួលខុសត្រូវក្នុងការជួយដល់បុគ្គល ក្រុម ឬ សហគមន៍ដែលត្រឡប់ទៅវិញឱ្យទទួលបានមកវិញក្នុងកម្រិតអតិបរមា តាមដែលអាចធ្វើបាន នូវទ្រព្យសម្បត្តិ និង ភោគៈ ដែលពួកគេបានបន្សល់ទុក ឬ ត្រូវបានដកហូតនៅពេលបណ្តេញចេញ។ វិធានការដោះស្រាយវិវាទលើសិទ្ធិកាន់កាប់គួរត្រូវបានផ្តល់ជូន។

៤. នៅពេលដែលការត្រឡប់ទៅកាន់កន្លែងរស់នៅកាលពីមុនវិញ និង ការយកមកវិញនូវទ្រព្យសម្បត្តិ និង ភោគៈមិនអាចធ្វើទៅបានទេនោះ អាជ្ញាធរមានសមត្ថកិច្ចត្រូវតែផ្តល់ជូនជនរងគ្រោះនៃការបណ្តេញចេញដោយបង្ខំ ឬ ជួយដល់ពួកគេឱ្យទទួលបានសំណងសមរម្យ ឬ ទម្រង់ផ្សេងទៀតនៃការជួសជុលសំណងដោយមានភាពយុត្តិធម៌។

## ៥.៣. សុវត្ថិភាពនៃការកាន់កាប់

១. គណៈកម្មាធិការអន្តរក្រសួង និង អនុគណៈកម្មាធិការរបស់ខ្លួន តាមរយៈក្រសួងរៀបចំដែនដី នគរូប-នីយកម្ម និង សំណង់ គប្បីធានាថា បន្ទាប់ពីបានស្នាក់នៅ នៅកន្លែងតាំងទីលំនៅថ្មីអស់រយៈពេលប្រាំឆ្នាំជាបន្តបន្ទាប់ សមាជិកគ្រួសារដែលបានតាំងទីលំនៅថ្មីអាចទទួលបានប្លង់រឹង(ប័ណ្ណកម្មសិទ្ធិ)លើដីធ្លីដែលពួកគេបានទទួលក្នុងអំឡុងពេលតាំងទីលំនៅថ្មីនោះ។

២. ក្នុងការកំណត់អំពី "ការស្នាក់នៅជាបន្តបន្ទាប់" គណៈកម្មាធិការអន្តរក្រសួង និង អនុគណៈកម្មា-ធិការរបស់ខ្លួនគប្បីគិតគូរដល់ការកែលម្អលំនៅឋាន និង ដីធ្លីដែលត្រូវបានប្រគល់ជូន និង មិនត្រូវពិចារណាតែអំពីវត្តមានរបស់សមាជិកគ្រួសារ ដែលបានតាំងទីលំនៅថ្មីនៅក្នុងកន្លែងតាំងទីលំនៅថ្មីនោះទេ។

៣. អាជ្ញាធរមូលដ្ឋានទទួលខុសត្រូវលើការកត់ត្រារយៈពេលដែលជនតាំងទីលំនៅថ្មី បានស្នាក់នៅកន្លែងតាំងទីលំនៅថ្មី និង គប្បីគាំទ្រដល់ការដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដោយគ្រួសារទាំងនេះ។

៤. បុគ្គលដែលបានតាំងទីលំនៅថ្មី ដែលបានស្នាក់នៅកន្លែងតាំងទីលំនៅថ្មីអស់រយៈពេលលើសពី ៥ឆ្នាំ និង អ្នកដែលនៅតែមិនទទួលបានប្លង់រឹង (ប័ណ្ណកម្មសិទ្ធិ) គប្បីត្រូវបានផ្តល់ជូននូវអាទិភាពក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដោយគណៈកម្មការសុរិយោដី។

៥. សិទ្ធិឯករាជ្យរបស់ស្ត្រីក្នុងការទទួលបានសុវត្ថិភាពនៃការកាន់កាប់ ដោយមិនគិតអំពីគ្រួសារ ឬ ស្ថានភាពនៃទំនាក់ទំនងរបស់ពួកគេទេនោះ គប្បីត្រូវបានទទួលស្គាល់ដោយគណៈកម្មការសុរិយោដី និង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់។

## ៥.៤. ការដោះស្រាយវិវាទ

១. រាជរដ្ឋាភិបាលកម្ពុជាគប្បីផ្តល់យន្តការបណ្តឹងតវ៉ាក្រៅប្រព័ន្ធតុលាការប្រកបដោយប្រសិទ្ធភាព និង សមស្របជាមួយនឹងយន្តការតាមប្រព័ន្ធតុលាការ ដែលជាផ្នែកមួយនៃប្រព័ន្ធដោះស្រាយការបំពានលើសិទ្ធិមនុស្ស ដែលផ្អែកលើរដ្ឋ ។

២. ដើម្បីធានាបាននូវប្រសិទ្ធភាពនៃយន្តការបណ្តឹងតវ៉ាក្រៅប្រព័ន្ធតុលាការ ទាំងយន្តការដែលផ្អែកលើរដ្ឋ និង មិនមែនរដ្ឋ គួរតែមានៈ

ក. ភាពស្របច្បាប់ៈ អនុញ្ញាតអោយមានការជឿទុកចិត្តពីក្រុមភាគីពាក់ព័ន្ធ ថាតើពួកគេមានបំណងប្រើប្រាស់យន្តការនោះ និង មានគណនេយ្យភាពចំពោះការអនុវត្តដំណើរការបណ្តឹងដោយយុត្តិធម៌

ខ. ភាពអាចប្រើប្រាស់បានៈ ក្រុមភាគីទាំងពាក់ព័ន្ធទាំងអស់បានដឹងថាតើពួកគេមានបំណងប្រើប្រាស់យន្តការនោះនិង ផ្តល់ជំនួយយ៉ាងសមរម្យដល់អ្នកដែលអាចប្រឈមមុខនឹងឧបសគ្គជាក់លាក់ក្នុងការប្រើប្រាស់យន្តការនោះ

គ. អាចប៉ាន់ប្រមាណទុកមុនបានៈ ផ្តល់នូវនីតិវិធីច្បាស់លាស់ និង មានព័ត៌មានគ្រប់គ្រាន់ រួមជាមួយការចង្អុលបង្ហាញអំពីរយៈពេលសម្រាប់ដំណាក់កាលនីមួយៗ ភាពច្បាស់លាស់អំពីប្រភេទដំណើរការ និង លទ្ធផលដែលអាចស្វែងរកបាន និង មធ្យោបាយត្រួតពិនិត្យការអនុវត្ត

ឃ. មានសមធម៌ៈ ព្យាយាមធានាថា ភាគីដែលបានដាក់បណ្តឹងតវ៉ា អាចទទួលបាននូវប្រភពព័ត៌មានសមហេតុផល ដំបូន្មាន និង ភាពជំនាញចាំបាច់ដើម្បីចូលរួមនៅក្នុងដំណើរការបណ្តឹងតវ៉ាដោយយុត្តិធម៌ ដោយមានព័ត៌មានគ្រប់គ្រាន់ និង គោរពនូវលក្ខខណ្ឌ។

ង. មានតម្លាភាពៈ ផ្តល់ព័ត៌មានដល់ភាគីនៃបណ្តឹងតវ៉ាអំពីវឌ្ឍនភាពនៃបណ្តឹង និង ផ្តល់ព័ត៌មានគ្រប់គ្រាន់អំពីការអនុវត្តនៃយន្តការ ដើម្បីកសាងទំនុកចិត្តលើប្រសិទ្ធភាពរបស់យន្តការ និង បំពេញផលប្រយោជន៍សាធារណៈនៃបណ្តឹងនោះ

ច. ស្របគ្នានឹងសិទ្ធិៈ ធានាថា លទ្ធផល និង ដំណោះស្រាយ គឺស្របគ្នានឹងសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ

ឆ. ប្រភពនៃការរៀនសូត្រជាបន្តបន្ទាប់ៈ ប្រើប្រាស់វិធានការដែលពាក់ព័ន្ធដើម្បីកំណត់មេរៀនសម្រាប់កែលម្អយន្តការ និង ទប់ស្កាត់បណ្តឹងតវ៉ា និង សេចក្តីអន្តរាយនាពេលអនាគត

ជ. យន្តការនៅកម្រិតប្រតិបត្តិការគួរផ្អែកលើការចូលរួម និង ការសន្ទនាៈ ការប្រឹក្សាយោបល់ជាមួយក្រុមភាគីពាក់ព័ន្ធដែលពួកគេមានបំណងប្រើប្រាស់យន្តការលើការរៀបចំ និង ការអនុវត្តរបស់ពួកគេ និង ផ្តោតលើការសន្ទនាដែលជាមធ្យោបាយ ដោះស្រាយបណ្តឹងតវ៉ា។

## ៦. ការត្រួតពិនិត្យ ការវាយតម្លៃ និង ការតាមដានបន្ត

១. ចំនួន ប្រភេទ និង ផលវិបាករយៈពេលវែងនៃការបណ្តេញចេញ រួមទាំង ការបណ្តេញចេញដោយបង្ខំផងដែរ គប្បីត្រូវបានត្រួតពិនិត្យដោយគណៈកម្មាធិការអន្តរក្រសួង និង អនុគណៈកម្មាធិការរបស់ខ្លួន។ ការត្រួតពិនិត្យបែបនេះគប្បីអនុញ្ញាតឱ្យមានការចូលរួមពីសំណាក់បុគ្គល ក្រុម និង សហគមន៍ដែលរងផលប៉ះពាល់ដោយសារការបណ្តេញចេញ។ ការតាមដានរបាយការណ៍ និង ការរកឃើញត្រូវតែផ្សព្វផ្សាយជាសាធារណៈដើម្បីលើកកម្ពស់ការអភិវឌ្ឍទម្លាប់អនុវត្តល្អបំផុត និង បទពិសោធន៍ក្នុងការដោះស្រាយបញ្ហាដែលទទួលបានផ្អែកលើការរៀនសូត្រកន្លងមក ។

២. គណៈកម្មាធិការអន្តរក្រសួង គប្បីតាមដានហេតុការណ៍នៃការបណ្តេញចេញដោយបង្ខំ និង អនុលោមភាពតាមគោលការណ៍ណែនាំទាំងនេះ និង បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

៣. គណៈកម្មាធិការអន្តរក្រសួងគប្បីគាំទ្រ និង គិតគូរដល់ការស្រាវជ្រាវអំពីសិទ្ធិមានលំនៅឋានសមរម្យនៅប្រទេសកម្ពុជា ដែលអនុវត្តដោយភាគីពាក់ព័ន្ធដទៃទៀត។

UNITED NATIONS
**HUMAN RIGHTS**
OFFICE OF THE HIGH COMMISSIONER
*Cambodia*


ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ
ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា



ខែកុម្ភៈ ឆ្នាំ២០២២



OHCHRCambodia
OHCHR_Cambodia
https://cambodia.ohchr.org
cambodia@ohchr.org